**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Feb-2013, 14:51
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោកនួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## បណ្ដឹងសាទុក្ខភ្លាមប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្ដីនួនជា**
Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
Joshua ROSENSWEIG
Sofie HOGESTOL
Renee DE GEUS

**ចម្លងជូន:**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង
Andrew CAYLEY

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជអង្គ
Elisabeth SIMONNEAU-FORT

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៣៥, ១០៤, ១០៥ និង ១០៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិធាន)[1] មេធាវីការពារក្តីជនជាប់ចោទ នួន ជា (មេធាវីការពារក្តី) ស្នើសុំដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ (សេចក្តីសម្រេចដែលរងការជំទាស់)[2]។ ផ្អែកតាមសំអាងហេតុដូចបានលើកឡើងនៅផ្នែកខាងក្រោម មេធាវីការពារក្តីសូមលើកទឡ្ហីករណ៍ថា (១) បណ្តឹងសាទុក្ខអាចទទួលយកបាន (២) សេចក្តីសម្រេចដែលរងការជំទាស់គឺមិនមានភាពត្រឹមត្រូវតាមផ្លូវច្បាប់ទេ និង (៣) អង្គជំនុំជម្រះតុលាការកំពូល អាច និងគួរតែប្រើប្រាស់ឆន្ទានុសិទ្ធិផ្ទាល់ខ្លួន ដើម្បីដោះស្រាយកំហុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូង។

## II. ប្រវត្តិនីតិវិធី

2. កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់សំណើសុំមួយ អនុលោមតាមវិធាន ៣៥ ដើម្បីជាការឆ្លើយតបទៅនឹងការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេត Laurent Kasper Ansermet (សំណើដើម)[3]។ នៅក្នុងសំណើនេះ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា ការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេត Laurent Kasper Ansermet គឺជាភ័ស្តុតាងបន្ថែមទៀតដែលបង្ហាញពីកម្រិតដែលការជ្រៀតជ្រែកផ្នែកនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា) បានប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីនៅក្នុងគ្រប់សំណុំរឿងទាំងអស់នៅ អ.វ.ត.ក។ ហេតុដូចនេះ ទើបមេធាវីការពារក្តីស្នើសុំឱ្យមាន "ការស៊ើបអង្កេតពេញលេញទៅលើឥទ្ធិពលនៃការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាល ទៅលើភាពត្រឹម

---

[1] *សូមមើល* វិធានផ្ទៃក្នុងរបស់អ.វ.ត.ក (វិសោធនកម្មលើកទី ៨) ដែលបានធ្វើវិសោធនកម្មកាលពីថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១។

[2] *សូមមើល* ឯកសារលេខ E-189/3 "សេចក្តីសម្រេចលើសំណើសុំឱ្យមានវិធានការបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ERN 00859224-00859231 ("សេចក្តីសម្រេចដែលរងការជំទាស់")។

[3] *សូមមើល* ឯកសារលេខ E-189 "សំណើសុំឱ្យមានវិធានការជាបន្ទាន់ដោយអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៣៥" ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ERN 00803004-00803019 ("សំណើ")។

ត្រូវនៃសំណុំរឿង ០០២" និង "ការផ្អាកកិច្ចដំណើរការនីតិវិធីរង់ចាំលទ្ធផលនៃការស៊ើបអង្កេតពេញលេញសិន"[4]។ នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ ព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងសំណើដើមនេះ[5]។

3. បន្ទាប់ពីរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំណើដើមរបស់យើងអស់រយៈពេលជិតប្រាំមួយខែរួចមក មេធាវីការពារក្តីបានដាក់បណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល អនុលោមតាមវិធាន ១០៤(៤)(ឃ)[6] ដោយបានលើកទឡ្ហីករណ៍ថា ការដែលអង្គជំនុំជម្រះសាលាដំបូងមិនបានចេញសេចក្តីសម្រេចទៅលើសំណើដើម នៅក្នុងអំឡុងពេលវេលាដ៏សមស្របនោះ គឺមានន័យស្មើនឹងការបដិសេធតាមការសន្មត (បណ្តឹងសាទុក្ខលើការសន្មត)[7]។ ជាចុងក្រោយអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចទៅលើសំណើដើមរបស់យើង កាលពីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២[8] គឺមុនពេលដែលអង្គជំនុំជម្រះតុលាការកំពូលមានឱកាសសម្រេចទៅលើបណ្តឹងសាទុក្ខលើការសន្មត។ នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចមួយ (សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ) ដោយច្រានចោលបណ្តឹងសាទុក្ខលើការសន្មតថាជាអាសាបង់ ប៉ុន្តែ "មិនមានការប៉ះពាល់ដល់សិទ្ធិរបស់មេធាវីការពារក្តីក្នុងការដាក់បណ្តឹងសាទុក្ខបន្តទៀតដោយអនុលោមតាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុងទៅលើមូលដ្ឋាននៃសំអាងហេតុរបស់អង្គជំនុំជម្រះជាលាយលក្ខណ៍អក្សរ ចំពោះការបដិសេធលើសំណើនេះ"[9] ឡើយ។

---

[4] *សូមមើល*សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៨។

[5] *សូមមើល* ឯកសារលេខ **E-189/1** "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ នួន ជា ដែលស្នើសុំឱ្យចាត់វិធានការជាបន្ទាន់ ដោយអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២

[6] *សូមមើល* ឯកសារលេខ E-189/2/1 "បណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធតាមការសន្មតនៃសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់អនុលោមតាមវិធាន៣៥" ថ្ងៃទី ១០ ខែ តុលាការ ឆ្នាំ ២០១២ ERN 00855149-00855151។

[7] *សូមមើលដូចខាងលើដែរ* កថាខណ្ឌ១-៤, ៦។

[8] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់។

[9]ឯកសារលេខ**E-189/2/3** "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា"ប្រឆាំងនឹងការបដិសេធជាក់ស្តែងដោយមិនបានសម្រេចលើសំណើសុំឱ្យធ្វើចំណាត់ការជាបន្ទាន់តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង" ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ERN 00865011-00865013កថាខណ្ឌ៦ ("សេចក្តីសម្រេច អ.ជ.ត.ក")។

4. សេចក្តីសម្រេចដែលរងការជំទាស់ បានបដិសេធចោលសំណើសុំទាំងអស់នៅក្នុងបណ្តឹងដើម ព្រមទាំងបានព្រមានដល់មេធាវីការពារក្តី "ថា កំហុសឆ្គងទៅថ្ងៃខាងមុខរបស់មេធាវីអន្តរជាតិការពារក្តី នួន ជា ដូចជាការដាក់សារណាច្រំដែល ឬការចោទប្រកាន់ពុំមានភស្តុតាងដែលមានចរិតជាការរើសអើងមកលើសមាជិកនៃអង្គជំនុំជម្រះសាលាដំបូង អាចជាមូលដ្ឋាននៃការដាក់ទណ្ឌកម្មដោយអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង"[10]។

## III. ច្បាប់ជាធរមាន

### ក. ភាពអាចទទួលយកបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដែលធ្វើឡើង អនុលោមតាម វិធាន ៣៥ នៃវិធានផ្ទៃក្នុង

5. ដូចមានចែងនៅក្នុងវិធាន១០៤(៤)នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនានាក្រោមវិធាន៣៥(៦) ត្រូវបានបើកផ្លូវប្តឹងសាទុក្ខភ្លាមៗ[11]។ បណ្តឹងសាទុក្ខបែបនេះត្រូវតែ "បញ្ជាក់ពីមូលដ្ឋានគាំទ្របណ្តឹងសាទុក្ខ និងទឡ្ហីករណ៍នានា"[12] និង"បង្ហាញផងដែរអំពីមូលដ្ឋាន ឬខ្លឹមសារនៃសេចក្តីសម្រេច [នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង] ដែលខ្លួនជំទាស់"[13]។ បន្ថែមពីលើនេះ បណ្តឹងសាទុក្ខដូចមានចែងនៅក្នុងវិធាន១០៤(៤)នៃវិធានផ្ទៃក្នុង ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនោះ[14]។

### ខ. សំណើសុំអនុលោមតាមវិធាន ៣៥

6. អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចតាមអាជ្ញាព្រឹត្តិបំផុតចំនួនពីរលើសំណើសុំអនុលោមតាមវិធាន ៣៥ គឺ "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបណ្តឹងជិតចិត្តលោកស្រីចៅក្រម Silvia

---

[10] *សូមមើល*សេចក្តីសម្រេចដែលរងការជំទាស់ ទំព័រ៨។

[11] *សូមមើល*វិធាន១០៤(៤)(ឃ)នៃវិធានផ្ទៃក្នុង។

[12] *សូមមើល*វិធាន១០៥(២)នៃវិធានផ្ទៃក្នុង។

[13] *សូមមើល*វិធាន១០៥(៤)នៃវិធានផ្ទៃក្នុង។

[14] *សូមមើល*វិធាន១០៧(១)នៃវិធានផ្ទៃក្នុង។

Cartwright"[15] និង "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ"[16]។ សេចក្តីសម្រេចទាំងពីរនេះនឹងត្រូវលើកយកជាសំអាងនៅក្នុងសំណើសុំទាំងមូល។

## IV. ឧត្តរកម្ម និងមូលដ្ឋាននៃបណ្តឹងសាទុក្ខ

### ក. បណ្តឹងសាទុក្ខអាចទទួលយកបាន

7. ដោយសារតែសេចក្តីសម្រេចដែលរងការជំទាស់ ធ្វើឡើងផ្អែកតាមវិធាន ៣៥(៦) ដូចនេះសេចក្តីសម្រេចនេះបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ ដូចមានចែងនៅក្នុងវិធាន ១០៤(៤)(ឃ)[17]។ បន្ថែមពីលើនេះ ការដាក់បណ្តឹងសាទុក្ខភ្លាមៗ ធ្វើឡើងស្របតាមលក្ខណវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ១០៥(២) និង(៤)[18] ហើយបណ្តឹងសាទុក្ខនេះ "បានដាក់ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនោះ"[19]។ អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខនេះអាចទទួលយកបាន និងត្រូវបានដាក់ទាន់ពេលវេលា។

### ខ. អង្គជំនុំជម្រះសាលាដំបូងរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន និង/ឬភ័ន្តច្រឡំអង្គហេតុ ឬអង្គច្បាប់

i <u>ការខកខានមិនបានពិចារណា និង/ឬដោះស្រាយលើខ្លឹមសារនៃសំណើសុំ</u>

8. អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន និង/ឬ បានភ័ន្តច្រឡំអង្គច្បាប់

---

[15]ឯកសារលេខ E-137/5/1/3"សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបណ្តឹងជំទាស់លើចៅក្រម Silvia Cartwright" ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ERN 00797036-00797045 "បណ្តឹងសាទុក្ខរបស់លោក អៀង សារី នៅចំពោះមុខ អ.ជ.ត.ក"។

[16]*សូមមើល* ឯកសារលេខE-116/1/7 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ" ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ")។

[17] *សូមមើល* វិធាន ១០៤(៤)។

[18] *សូមមើល* វិធាន ១០៥(២) និង(៤)។ សំណើសុំភ្លាមៗ លើកឡើងអំពីមូលដ្ឋាននៃបណ្តឹងសាទុក្ខ និងកំណត់អំពីសំអាងហេតុនៅក្នុងសេចក្តីសម្រេចដែលខ្លួនជំទាស់។

[19] *សូមមើល* វិធាន ១០៧(១)។

ដោយសារមិនបានពិចារណាឲ្យបានគ្រប់គ្រាន់លើពាក្យសុំរបស់មេធាវីការពារក្តី។

*ការខកខានមិនបានពិចារណា និង/ឬដោះស្រាយខ្លឹមសារនៃ“កំណត់សម្គាល់”*

9. អង្គជំនុំជម្រះសាលាដំបូងបានខកខានទាំងស្រុងក្នុងការពិចារណា និង/ឬដោះស្រាយខ្លឹមសារសំខាន់នៃ “កំណត់សម្គាល់” ដែលជាចំណុចសំខាន់នៃសំណើសុំអនុលោមតាមវិធាន ៣៥[20]។

10. ខ្លឹមសារនៃកំណត់សម្គាល់ដែលលើកឡើងដោយ Kasper-Ansermet គឺជាផ្នែកសំខាន់នៃការលើកឡើងរបស់មេធាវីការពារក្តីនៅក្នុងសំណើសុំរបស់ខ្លួន ហើយជាក់ស្តែងគឺជាការជំរុញផ្ទាល់ចំពោះការដាក់សារណារបស់មេធាវីការពារក្តី។ ហេតុដូចនេះ កំណត់សម្គាល់នេះគឺជាចំណុចសំខាន់នៃសំណើសុំ និងត្រូវបានលើកយកមកពិភាក្សានៅក្នុងបន្ទាត់ដំបូងនៃផ្នែកទទ្ទឹករណ៍៖ “ការលាលែងចេញពីតំណែងរបស់ចៅក្រមបម្រុងអន្តរជាតិ Kasper-Ansermet និងកំណត់សម្គាល់របស់គាត់គឺជាភស្តុតាងយ៉ាងច្បាស់ក្រឡែតដែលបង្ហាញថាគ្មានមន្ត្រីកម្ពុជាណាម្នាក់នៅ អ.វ.ត.ក អាចអនុវត្តប្រឆាំងទៅនឹងរបៀបវារៈផ្នែកតុលាការរបស់រដ្ឋាភិបាលកម្ពុជាបានឡើយ”[21]។ កំណត់សម្គាល់ត្រូវបានយកមកពិភាក្សាបន្ថែមលម្អិតជាច្រើននៅក្នុងផ្នែក “អង្គហេតុពាក់ព័ន្ធ” នៃសំណើនេះ[22] ហើយខ្លឹមសារទាំងស្រុងនៃកំណត់សម្គាល់នេះត្រូវបានប្រើប្រាស់ដោយលើកយោងទៅឯកសារនោះ[23]។ ជាចុងក្រោយ កំណត់សម្គាល់គឺជាចំណុចសំខាន់នៅក្នុងសំណើសុំ ដែលស្នើសុំឲ្យមានការទទួលស្គាល់នូវការរងព្យសនកម្ម[24]។ ពាក្យពេចន៍នៃសំណើសុំ៖ កំណត់សម្គាល់គឺ “ជាការចោទប្រកាន់យ៉ាងដំណំដែលមិនអាចប្រកែកបានដល់ស្ថាប័នមួយដែលត្រូវបានអន្តរាយ និងអាប់យស។ និយាយឲ្យខ្លី កំណត់សម្គាល់នេះគឺស្មើនឹងដីកាដំណោះស្រាយលើការលេងសើចដែលមានកំហុសធ្ងន់ធ្ងររបស់កម្ពុជាជាមួយនឹងយុត្តិធម៌អន្តរជាតិ”[25]។

---

[20] *សូមមើល*សំណុំរឿង ០០៣ និង ០០៤ ឯកសារលេខD38 “កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើជូនភាគី ស្តីអំពីភាពមិនអាចដំណើរការបានដ៏ធ្ងន់ធ្ងរ ដែលរារាំងការបំពេញកិច្ចស៊ើបសួរឲ្យបានសមស្របក្នុងសំណុំរឿង០០៣ និងសំណុំរឿង ០០៤” ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ ERN 00791885-00791898 (“កំណត់សម្គាល់”)។

[21] *សូមមើល* សំណើសុំ កថាខណ្ឌ១៩ (គូសបញ្ជាក់បន្ថែម)។

[22] *សូមមើល* សំណើសុំ កថាខណ្ឌ៩-១១។

[23] *សូមមើល* សំណើសុំ កថាខណ្ឌ១១។

[24] *សូមមើល* សំណើសុំ កថាខណ្ឌ២៨។

[25] *សូមមើល* សំណើសុំ កថាខណ្ឌ១១។

11. ហេតុដូចនេះ ខ្លឹមសាររបស់កំណត់សម្គាល់ គឺជាផ្នែកសំខាន់នៃសំណើសុំ។ ដោយសារតែកំណត់សម្គាល់គឺជាការបញ្ជាក់*ដោយផ្ទាល់មួយ* ពីចៅក្រមអន្តរជាតិ និងឯករាជ្យ យើងអាចដឹងច្បាស់ពីជំហរមេធាវីការពារក្តីជាយូរមកហើយដែលថា បុគ្គលិកជាតិនៅតុលាការនេះ រួមទាំងចៅក្រមផងដែរ មិនអាចអនុវត្តមុខងាររបស់ខ្លួនដោយឯករាជ្យដោយមិនគោរពតាមគោលបំណង និងសេចក្តីបង្គាប់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានោះទេ[26]។

12. ហេតុដូច្នេះ សារៈសំខាន់នៃកំណត់សម្គាល់ចំពោះសំណើសុំ ទឡ្ហីករណ៍ និងសារណារបស់មេធាវីការពារក្តី មានលក្ខណៈច្បាស់លាស់។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីសម្រេចដែលរងការជំទាស់ គ្រាន់តែ*លើកឡើង* អំពីកំណត់សម្គាល់ត្រង់ចំណុចសង្ខេបទឡ្ហីករណ៍របស់មេធាវីការពារក្តីនៅកថាខណ្ឌ៤[27] ហើយខកខានមិនបានពិនិត្យមើលឡើងវិញទៅលើកំណត់សម្គាល់ ឬខ្លឹមសាររបស់កំណត់សម្គាល់ ផ្អែកតាមវិធីសាស្ត្រ បែបបទ ឬទម្រង់ នៅក្នុងផ្នែកសេសសល់នៃសេចក្តីសម្រេច។ ដោយសារតែកំណត់សម្គាល់ ជាពិសេស *ខ្លឹមសារ* នៃកំណត់សម្គាល់ (បង្ហាញអំពីភាពបែកបាក់នៅក្នុងតុលាការរវាងផ្នែកជាតិ-អន្តរជាតិ ដោយផ្នែកជាតិធ្វើតាមគោលជំហរផ្លូវការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដូចដែលមេធាវីការពារក្តីតែងតែអះអាងអំពីករណីនេះ) បង្កើតបានជាផ្នែកសំខាន់ និងមិនអាចកាត់ផ្តាច់បាននៃសំណើសុំ ដូចនេះការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនបានដោះស្រាយលើបញ្ហានេះ គឺជាការរំលោភបំពានយុត្តាធិការ។ និយាយម្យ៉ាងវិញទៀត ការខកខាននេះ គឺជាការភ័ន្តច្រឡំអង្គច្បាប់ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តតួនាទីរបស់ខ្លួនក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់ក្នុងសេចក្តីសម្រេចរបស់ខ្លួន ពោលគឺអង្គជំនុំជម្រះមិនបានរៀបរាប់ទាល់តែសោះអំពីហេតុអ្វីបានជាកំណត់សម្គាល់មិនជាប់ពាក់ព័ន្ធ ក្នុងការពិចារណាលើសំណើដែលស្នើសុំដោយមេធាវីការពារ

[26] ទោះបីជាកំណត់សម្គាល់ រិះគន់ស្មើរតែទាំងស្រុងលើចំណាត់ការរបស់ចៅក្រម យូ ប៊ុនឡេង និងមន្ត្រីជាតិរបស់គាត់ក៏ដោយ ក៏ប៉ុន្តែសារណារបស់មេធាវីការពារក្តីបានលលើកឡើងថា ចំណាត់ការទាំងនេះ គឺជាការបង្ហាញឱ្យឃើញដោយផ្ទាល់នូវគោលបំណងរបស់រាជរដ្ឋាភិបាលទាក់ទិននឹងសំណុំរឿង០០៣/០០៤ ដោយចងចាំអំពីជំហរម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងជាពិសេសលោក ហ៊ុន សែន តែងតែប្រើប្រាស់នៅក្នុងបញ្ហានេះ។ (*សូមមើលផងដែរ* សំណើសុំ)។ ថាតើអ្នកណាដែលយល់ព្រមជាមួយការវាយតម្លៃរបស់មេធាវីការពារក្តីលើបញ្ហាទាំងនេះ គឺជារឿងផ្សេងទៀត។ បញ្ហានៅទីនេះ ឋិតនៅត្រង់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានលើកឡើងទឡ្ហីករណ៍ និងបញ្ហានានានោះទេ។

[27] *សូមមើល* សំណើសុំ កថាខណ្ឌ ៤ ("សមាជិកអន្តរជាតិរបស់មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យមានការទទួលស្គាល់នូវការរងព្យសនកម្មពីលិខិតសុំលាលែងពីមុខតំណែងរបស់ចៅក្រម KASPER-ANSERMET [...]")។

ក្តី។

*ការខកខានមិនបានលើកឡើងអំពីមូលហេតុ អង្គហេតុ និងកាលៈទេសៈជុំវិញការលាលែងតំណែងរបស់ចៅក្រម Kasper-Ansermet*

13. ដើម្បីធ្វើឱ្យប្រាកដច្បាស់ សេចក្តីសម្រេចបានលើកឡើងដោយសង្ខេបអំពីការលាឈប់របស់ Kasper-Ansermet (ដាច់ដោយឡែកពីខ្លឹមសារនៃកំណត់សម្គាល់) នៅក្នុងពីរបីចំណុច[28]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការលើកឡើងនូវអង្គហេតុពាក់ព័ន្ធ ពោលគឺមូលហេតុ និង អង្គហេតុ និងកាលៈទេសៈជុំវិញការលាលែងពីតំណែង ដូចដែលបានលើកឡើងនៅក្នុងសំណើសុំ[29] និងបន្ថែមពីលើនេះ ពិតជាបានធ្វើឱ្យជំហររបស់មេធាវីការពារក្តីមានលក្ខណៈសាមញ្ញពេក។ ការលើកឡើងដំបូងអំពីការលាលែងពីមុខតំណែង មាននៅក្នុងកថាខណ្ឌទី ៣ នៅពេលដែល អង្គជំនុំជម្រះសាលាដំបូងសង្ខេបមិនដោយត្រឹមត្រូវអំពីទឡ្ហីករណ៍របស់មេធាវីការពារក្តី៖ "សមាជិកអន្តរជាតិនៃមេធាវីការពារជនជាប់ចោទ នួន ជា លើកឡើងថា ការលាលែងរបស់ចៅក្រម Laurent KASPER-ANSERMET ពីមុខតំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង សបញ្ជាក់ថា មន្ត្រីកម្ពុជានៅ អ.វ.ត.ក បានទទួលរងឥទ្ធិពលពីរដ្ឋាភិបាល និង ពុំមានសមត្ថភាពដើម្បីបំពេញតួនាទីប្រកបដោយឯករាជ្យបានឡើយ"[30]។ ជាការពិត ជំហររបស់មេធាវីការពារក្តី មិនមែនគ្រាន់តែថា*ការលាលែងពីតំណែងរបស់* ចៅក្រម Kasper-Ansermet បានបង្ហាញអ្វីៗទាំងអស់នោះទេ។ ប៉ុន្តែ វាគឺជា*មូលហេតុ និងកាលៈទេសៈ និងអង្គហេតុជុំវិញការលាលែងពីតំណែង* (ដែលបានរៀបរាប់យ៉ាងច្រើននៅក្នុងសំណើសុំ) ដែលនាំឱ្យមានការដាក់ឯកសាររបស់មេធាវីការពារក្តី[31]។ ដូច្នេះអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានលើកឡើងអំពីខ្លឹមសារនៃសារណារបស់មេធាវីការពារក្តី ដូច្នេះមិនអាចដោះស្រាយលើខ្លឹមសារនៃសារណារបស់មេធាវីការពារក្តីបានឡើយ។

---

[28] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២, ៤, ៨, ១០។

[29] *សូមមើល* សំណើសុំ កថាខណ្ឌ ៦-១៥។

[30] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣។

[31] ជាការពិត កថាខណ្ឌ១៩នៃសំណើសុំ ដែលលើកឡើងជាសំអាងយ៉ាងច្បាស់ដោយអង្គជំនុំជម្រះសាលាដំបូង មិនមែនគ្រាន់តែនិយាយអំពីការលាលែងពីមុខតំណែងរបស់គាត់នោះទេ ប៉ុន្តែអំពីការលាលែងពីមុខតំណែង*និង*កំណត់សម្គាល់។ *សូមមើល* សំណើសុំ កថាខណ្ឌ១៩។

14. នៅក្នុងកថាខណ្ឌ៨ អង្គជំនុំជម្រះសាលាដំបូងបានជ្រើសយកវិធីសាស្ត្រដូចគ្នា ដោយបានលើកឡើងថា៖ "ថ្វីបើមានការព្យាយាមដើម្បីចាត់ទុកថា ការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង KASPER-ANSERMET ពីកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ជាកាលៈទេសៈថ្មីមួយដែលស័ក្តិសមទទួលបានការអន្តរាគមន៍របស់អង្គជំនុំជម្រះក្នុងការជំនុំជម្រះលើសំណុំរឿង ០០២ ក៏ដោយ [...]"[32]។ ជាថ្មីម្តងទៀត មេធាវីការពារក្តីមិនដែលចាត់ទុកការលាលែងពីតំណែងបែបនេះថាជាកាលៈទេសៈថ្មីមួយនោះទេ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបកស្រាយខុសចំពោះគោលជំហររបស់មេធាវីការពារក្តី ដែលជាឧបាយកលគេចវេសពីខ្លឹមសារសំខាន់ដែលមាននៅក្នុងសំណើសុំ[33]។ ទង្វើនេះគឺជាការបំពានលើឆន្ទានុសិទ្ធិ ដូច្នេះសេចក្តីសម្រេចត្រូវតែបដិសេធចោលដោយសារមូលហេតុដែលបានលើកឡើងនេះ ឬម្យ៉ាងវិញទៀត ទង្វើនេះគឺជាការភ័ន្តច្រឡំអង្គច្បាប់ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តតួនាទីរបស់ខ្លួនក្នុងការផ្តល់នូវសំអាងហេតុគ្រប់គ្រាន់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ពីព្រោះតែអង្គជំនុំជម្រះមិនបានពន្យល់ថាតើហេតុអ្វីបានជាអង្គហេតុ និងកាលៈទេសៈជុំវិញការលាលែងពីតំណែងរបស់ Kasper-Ansermet មិនមានភាពពាក់ព័ន្ធ ក្នុងការពិចារណាសំណើសុំដែលស្នើសុំដោយមេធាវីការពារក្តី។

---

[32] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨។

[33] ជាចុងក្រោយ នៅក្នុងកថាខណ្ឌ១០ អង្គជំនុំជម្រះសាលាដំបូង បានបញ្ចូលនូវភាពសាមញ្ញដែលនេះជាថ្មីម្តងទៀត ដែលអង្គជំនុំជម្រះបានលើកឡើងថា សំណើសុំ "ខកខានពុំបានបញ្ជាក់ច្បាស់លាស់ ឬបង្ហាញភស្តុតាងអំពីផលប៉ះពាល់ទៅលើការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅក្នុងសំណុំរឿង ០០២/០១ ដោយសារការលាឈប់របស់ចៅក្រម KASPER-ANSERMET ពីកិច្ចស៊ើបសួរតាមផ្លូវតុលាការលើសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ឡើយ"។ ជាថ្មីម្តងទៀត មេធាវីការពារក្តីមិនមែនជំទាស់អំពីការលាលែងពីតំណែងបែបនេះនោះទេ។ ជាសំខាន់ ជើងទំព័រ២១ នៃកថាខណ្ឌនេះ គឺជាភ័ស្តុតាងតែមួយគត់នៃការពិចារណា*សំខាន់*ណាមួយនៃ "អង្គហេតុ"នៃប្រភេទណាមួយនៅក្នុងសេចក្តីសម្រេច ដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២ របស់ចៅក្រម Kasper-Ansermet ដែលលើកឡើងអំពីការជ្រៀតជ្រែករបស់បុគ្គលិកនៅក្នុងសំណុំរឿង០០៣ និង០០៤ និងបានចេញសេចក្តីសម្រេចដែលមានសំអាងហេតុត្រង់ចំណុចថាតើហេតុអ្វីបានជាអង្គហេតុ*ទាំងនោះ* មិនបានទទួលនូវចំណាត់ការបន្ថែមណាមួយដោយអង្គជំនុំជម្រះសាលាដំបូង។ ទោះបីជាមេធាវីការពារក្តី មិនបានលើកយកជើងទំព័រនេះជាបញ្ហា ប៉ុន្តែវាបានប្រាប់ថា ការពិភាក្សាដោយមានសំអាងហេតុដែលមានតែមួយគត់នៃ*កាលៈទេសៈអង្គហេតុពិតប្រាកដ* ទាក់ទងនឹងសេចក្តីប្រកាសព័ត៌មាន ដែលមិនបានទាំងក្លាយជាផ្នែកនៃសំណើសុំ (ដោយសារតែសេចក្តីប្រកាសព័ត៌មាន ត្រូវបានផ្សព្វផ្សាយក្រោយកាលបរិច្ឆេទដាក់នៃការដាក់សំណើសុំ)។

ii. <u>ការរកឃើញនៃ "ភាពច្រំដែល" គឺជាការរំលោភបំពានយុត្តាធិការ ឬការភ័ន្តច្រឡំអង្គច្បាប់</u>

*សំណើសុំមិនមែន "ច្រំដែលត្រួតគ្នាស្មើរតែទាំងស្រុង"នោះទេ*

15. សេចក្តីសម្រេចគឺមានកំហុសស្រដៀងគ្នាដោយនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលបានលើកឡើងថា "សំណើសុំរបស់ នួន ជា នេះ គឺជាសំណើសុំ*ច្រំដែលត្រួតគ្នាស្មើរតែទាំងស្រុង* ជាមួយសំណើមុនៗដែល នួន ជា ធ្លាប់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"[34]។ សំអាងហេតុនេះគួរឲ្យឆ្ងល់ និងបង្ហាញឲ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនទាំងបានអានសំណើសុំផង។ ដើម្បីឲ្យប្រាកដច្បាស់ មេធាវីការពារក្តីសង្ឃឹមថា អង្គជំនុំជម្រះសាលាដំបូងនឹងចូលរួមបន្តិចបន្តួចថែមទៀត នៅពេលដែលត្រូវបានតទល់គ្នាតាមរយៈការវាយប្រហារប្លែកខុសពីធម្មតាដែលមិនធ្លាប់មានពីមុន ពីសំណាក់ចៅក្រមជំនុំជម្រះ ទៅលើសុចរិតភាពរបស់តុលាការ[35]។ ប៉ុន្តែសំខាន់ជាងនេះ បើផ្អែកតាមទស្សនៈម្ចាស់បណ្តឹងឧទ្ធរណ៍ ការចោទប្រកាន់របស់អង្គជំនុំសាលាដំបូងអំពីភាពច្រំដែល គ្រាន់តែការចោទប្រកាន់មិនសមហេតុផល៖ ជាការពិត កថាខណ្ឌចំនួន ៤ (*បួន*) ក្នុងចំណោម*កថាខណ្ឌចំនួន ២៨* របស់សំណើសុំ បានសង្ខេបអំពីការខិតខំប្រឹងប្រែងរបស់មេធាវីការពារក្តី*ពីមុនៗ*[36]។ ផ្នែកដែលនៅសេសសល់ និងចំណុចសំខាន់នៃសំណើសុំ គឺផ្តោតទៅលើការលើកឡើងអំពីអង្គហេតុ និងកាលៈទេសៈនានា ទាក់ទិននឹងការលាលែងពីតំណែងរបស់ Kasper-Ansermet[37] សំណើសុំលើអង្គច្បាប់[38] និងទឡ្ហីករណ៍ ដែលផ្អែកលើកាលៈទេសៈនៃការលាលែងពីតំណែងរបស់ចៅក្រម Kasper-Ansermet[39]។ ចំណុចទាំងនេះធ្វើឲ្យសំណើសុំនេះខុសគ្នាឆ្ងាយពីការលើកឡើងដែលថា "ច្រំដែលត្រួតគ្នាស្មើរតែទាំងស្រុង"។

---

[34] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៨ (គូសបញ្ជាក់បន្ថែម)។

[35] វាធ្វើឲ្យនឹកឃើញឡើងវិញនូវសំដីរបស់លោកចៅក្រម Kasper-Ansermet ដូចដែលបានដកស្រង់នៅក្នុងសំណើសុំ៖ "ការប្រឈមមុខជាមួយអរិភាពនៃចៅក្រមកម្ពុជា **ភាពស្ងប់ស្ងៀមនៃសហសេវិកអន្តរជាតិ** និងរដ្ឋបាលឥតខ្វល់មួយ ដូចនេះខ្ញុំមានអារម្មណ៍ងឿងឆ្ងល់"។ (Julia Wallace "ពីភ្នំពេញដោយក្តីស្រលាញ់" *តុលាការយុត្តិធម៌អន្តរជាតិ* ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ (គូសបញ្ជាក់បន្ថែម))។

[36] សំណើសុំ កថាខណ្ឌ២-៥ ដែលមានចំណងជើងថា៖ "កិច្ចប្រឹងប្រែងលើកមុនដោយមេធាវីការពារក្តី"។

[37] *សូមមើល* សំណើសុំ កថាខណ្ឌ១, ៦-១៥។

[38] *សូមមើល* សំណើសុំ កថាខណ្ឌ១៦-១៨។

[39] *សូមមើល* សំណើសុំ កថាខណ្ឌ១៩-២៦។

16. ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សំណើសុំមានលក្ខណៈ "ច្រំដែលត្រួតគ្នាស្ទើរតែទាំងស្រុង" ដែលយកធ្វើជាមូលដ្ឋាន(យ៉ាងហោចណាស់នៅក្នុងផ្នែកខ្លះ) នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដើម្បីបដិសេធចោលសំណើសុំ[40] គឺច្បាស់ជាការរំលោភបំពានលើឆន្ទានុសិទ្ធិ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានបកស្រាយខុសយ៉ាងច្បាស់ក្រឡែកលើសំណើសុំ ឬការភ័ន្តច្រឡំអង្គហេតុ ឬការយល់ខុសអំពី "*ភាពច្រំដែល*" ហើយដូច្នេះជាការភ័ន្តច្រឡំអង្គច្បាប់[41]។ ទោះក្នុង

---

[40] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៨។ ដោយសារកថាខណ្ឌ៨ដែលប្រើពាក្យពេចន៍ "ច្រំដែលត្រួតគ្នាស្ទើរតែទាំងស្រុង" គឺជាផ្នែកមួយនៃសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដូចនេះយើងត្រូវតែចាត់ទុកវាជាផ្នែកនៃមូលដ្ឋានរបស់សេចក្តីសម្រេច ដើម្បីបដិសេធចោលសំណើសុំទាំងអស់។

[41] ប៉ុន្តែនៅមានហេតុផលមួយទៀតដែលថាតើហេតុអ្វីបានជាការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពច្រំដែល គឺពុំមានមូលដ្ឋានច្បាស់លាស់។ ជាមូលដ្ឋាននៃការសម្រេចរបស់ខ្លួនអំពីភាពច្រំដែលដែលខ្លួនបានធ្វើ អង្គជំនុំជម្រះសាលាដំបូងពុំបានត្រឹមតែលើកឡើងដោយភាន់ច្រឡំថា "តាមការពិត សំណើនេះស្ទើរតែមានភាពច្រំដែលទាំងស្រុងជាមួយសំណើមុនៗដែលមេធាវីការពារក្តីបានធ្វើនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" (សូមមើលខាងលើ) អង្គជំនុំជម្រះ *បានបន្ថែម* ថាសារណាមុនៗទាំងនោះ "ត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល" (សំណើ កថាខណ្ឌ ៨)។ ដើម្បី គាំទ្រការសម្រេចនោះ អង្គជំនុំជម្រះសាលាដំបូងសំអាងលើនីតិវិធីផ្សេងគ្នាចំនួន ៣ ដែលមេធាវីការពារក្តី នួន ជា បានផ្តួច ផ្តើម។ បើទោះបីជាដូច្នេះក្តី នៅពេលដាក់សំណើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំបានសម្រេចជាស្ថាពរលើនីតិវិធីចំនួន ២ ក្នុងចំ ណោមនីតិវិធីទាំង៣នេះឡើយ (ឯកសារលេខ E-116/1/7 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ", ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២) ឬថែមទាំងដោយអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់ផង (សូមមើលឯកសារ E-176/2 "សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២)។ ហេតុដូច្នេះ ការសង្កេតរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាសំណើទាំងនេះ"ត្រូវបានបដិសេធ" ដោយអង្គជំនុំជម្រះតុលាការកំពូលគឺនាំឱ្យមានការភាន់ច្រឡំ និងពុំអាចមានសារៈសំខាន់អ្វីទាំងអស់ នៅពេលវាយតម្លៃអំពីភាពច្រំដែលនៃការដាក់ឯកសាររបស់ នួន ជា។ ជាការពិត នៅពេលដាក់សំណើនេះ មេធាវីការពារក្តី នួន ជា ពុំមានមធ្យោបាយដើម្បីដឹងអំពីគោលជំហររបស់ អ.ជ.ត.ក លើបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងនេះឡើយ។ ការដាក់ឯកសារទីបីរបស់ នួន ជា ដែលជាដើមចមនៃអំណះអំណាងរបស់ អ.ជ.ស.ជ អំពីភាពច្រំដែលគឺជា (*សូមមើល* ឯកសារលេខ E131/2. "សំណើសុំផ្អាកការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តី", ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១, ERN: 00749600-00749612)។ ឯកសារចំនួន ១២ ទំព័រដែលមានសំអាងហេតុយ៉ាងច្រើនដែលផ្អែកលើកាលៈទេសៈជុំវិញការលាលែងតំណែងរបស់ចៅក្រម Blunk ត្រូវបានសម្រេចក្នុងទម្រង់ជាអនុស្សរណៈចំនួន ១ ទំព័រដែលពុំមានសំអាងហេតុពេញលេញទាល់តែសោះ (*សូមមើល* ឯកសារលេខ **E-131/2/1** "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើរបស់ជនជាប់ចោទ នួន ជា ដែលស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ ជាបណ្តោះអាសន្ន (ឯកសារ E131/2)" ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១) ដែលបានខកខានពុំបានលើកឡើងអំពី *ខ្លឹមសារ* នៃសំណើសុំផ្អាកនេះ ពិសេសជាងបណ្តឹងសាទុក្ខភ្លាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

វិធីណាមួយក៏ដោយ សេចក្តីសម្រេចនេះត្រូវតែបដិសេធចោលដោយផ្អែកលើមូលដ្ឋាននេះ[42]។

*ការដកស្រង់សារណាពីមុនៗ*

17. ដើម្បីឱ្យប្រាកដច្បាស់ សំណើសុំបានយោងត្រង់ៗលើ*ពាក្យពេចន៍*នៃសំណើសុំដែលបានដាក់ពីមុនៗមួយចំនួន ដាក់ស្តែងនៅក្នុងកថាខណ្ឌ ២៣។ ទោះបីជាយ៉ាងណាក៏ដោយ *ភាពប្លែក* នៃការអនុវត្តនេះ ហាក់ដូចជាមិនបានធ្វើឱ្យសមាជិករបស់អង្គជំនុំជម្រះសាលាដំបូងចាប់អារម្មណ៍ឡើយ។ ពាក្យពេចន៍ដែលដកស្រង់ចេញមកពីសំណើសុំផ្អាកពីមុន[43]។ ភាពប្លែកទាំងនេះ អាចឃើញជាក់ស្តែងដែលថា សំណើសុំផ្អាកនេះត្រូវបានដាក់ដើម្បីឆ្លើយតបទៅនឹងការលាលែងពីតំណែង*ផ្សេងមួយទៀត* របស់សហចៅក្រមស៊ើបអង្កេតម្នាក់ផ្សេងទៀត (ចៅក្រម Blunk) រយៈពេលប្រាំមួយខែ *មុនពេល*ដាក់សំណើសុំភ្លាមៗ ដែលជាការលាលែងពីមុខតំណែងដោយសារតែការជ្រៀតជ្រែកឥតឈប់ឈរពីសំណាក់រាជរដ្ឋាភិបាល[44]។ ការលើកឡើងច្រំដែលៗនៃ*ពាក្យពេចន៍ដូចគ្នា* បានជួយ

---

នេះគឺកាលៈ ទេសៈជុំវិញការលាលែងពីតំណែងរបស់ចៅក្រម Blunk ។ ដោយហេតុថា "អនុស្សរណៈ" នេះពុំបើកផ្លូវប្តឹងសាទុក្ខ អ.ជ.ត.ក ពុំបានសម្រេចលើអនុស្សរណៈនេះឡើយ ហើយដូច្នេះទើបបានជា អ.ជ.ត.ក ពុំបាន "បដិសេធ" អនុស្សរណៈនេះ។ ជារួម ការសម្រេចតាមទិដ្ឋភាពច្បាប់ជាស្ថាពរតែមួយគត់ដែលមាននៅពេលមេធាវីការពារក្តីបានដាក់សំណើរបស់ខ្លួនកាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ គឺជាអនុស្សរណៈមួយទំព័រដែលមានវិការៈ ដែលពុំបានលើកឡើងទាល់តែសោះអំពីខ្លឹមសារនៃទឡ្ហីករណ៍របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងការលាលែងពីតំណែងរបស់ចៅក្រម Blunk។ ជាការពិត ប្រសិនបើការប្រើប្រាស់អនុស្សរណៈ E131/2/1 របស់អង្គជំនុំជម្រះសាលាដំបូងជួយបង្ហាញអំពីអ្វីមួយ អង្គជំនុំជម្រះសាលាដំបូងមាននិន្នាការច្រំដែលម្តងហើយម្តងទៀតក្នុងការបដិសេធពុំចូលពាក់ព័ន្ធជាដុំកំភួន (និងតាមរយៈសេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវ) ជាមួយកាលៈទេសៈដែលសំខាន់គួរសមដែលចៅក្រមបរទេសជាបន្តបន្ទាប់បានលាឈប់ពី អ.វ.ត.ក ដោយសារការជ្រៀតជ្រែករបស់រដ្ឋាភិបាល។ អនុស្សរណៈនេះពុំសូវមានប្រយោជន៍ដើម្បីគាំទ្រដល់អំណះអំណាងដែលថាមេធាវីការពារក្តីកំពុងដាក់សំណើច្រំដែលឡើយ។

[42] បន្ថែមពីលើនេះ សេចក្តីសម្រេចធ្វើឱ្យឃើញច្បាស់ថា សេចក្តីសម្រេចមិនបានពិចារណាអំពីអង្គហេតុ ដែលមាន ឬត្រូវបានយោងនៅក្នុងសំណើសុំរបស់មេធាវីការពារក្តីពីមុនៗនោះទេ។ ដោយសារតែអង្គហេតុទាំងនេះផ្តល់ឱ្យនូវបរិបទពាក់ព័ន្ធ និងមិនអាចជំទាស់បាន ដូចនេះទង្វើនេះត្រូវបានចាត់ទុកថាជាការរំលោភបំពានឆន្ទានុសិទ្ធិ ឬការភ័ន្តច្រឡំអង្គច្បាប់ផងដែរ។

[43] ឯកសារលេខ **E-131/2** "សំណើសុំផ្អាកការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តី" ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ERN 00749600-00749612 ("សំណើសុំផ្អាក")។

[44] ជាការពិត សំណើសុំបានជួយរៀបរាប់ជាច្រើននៅក្នុងជើងទំព័រ ៧៧។

បង្ហាញឲ្យឃើញថា មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើល[45] ក្នុងរយៈពេលប្រាំមួយខែនេះ *មិនមានអ្វីផ្លាស់ប្តូរនោះទេ* នៅអ.វ.ត.ក។ ជាការពិត ពាក្យពេចន៍ និងទឡ្ហីករណ៍ដែលលើកឡើងនៅក្នុងសំណើសុំផ្អាក គឺមានសុពលភាព និងមិនត្រូវបានដោះស្រាយជារៀងរហូត។ ភាពខុសគ្នារវាងឯកសារទាំងពីរនេះ គឺថា ភាសាដូចគ្នានេះ *កាន់តែមានទម្ងន់* នៅពេលដាក់សំណើសុំ ប៉ុន្តែបច្ចុប្បន្ននេះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ*ផ្សេងមួយរូបទៀត* បានសម្រេចឈប់បំពេញតួនាទីរបស់ខ្លួនដោយផ្អែកលើមូលដ្ឋាននៃការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលដែលមិនអាចអត់ឱនឲ្យបាន។

iii <u>ការខកខានមិនអនុវត្តតាមនីតិវិធី ដែលបានបង្កើតឡើងដោយអង្គជំនុំជម្រះតុលាការកំពូល</u>

18. អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តតាមនីតិវិធីច្បាស់លាស់ ដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខប្រឆាំងនឹង ហ៊ុន សែន ដែលបានបកស្រាយអំពីវិធីសាស្ត្រផ្នែកនីតិវិធី ដែលត្រូវតែអនុវត្តតាម នៅពេលដែលស្ថាប័នតុលាការមួយប្រឈមមុខទៅនឹងសំណើសុំ "ដោយអនុលោមតាមវិធាន ៣៥ ដែលចែងថាអង្គជំនុំជម្រះដែលបានទទួលសំណើសុំ ត្រូវតែពិនិត្យមើលការចោទប្រកាន់ វាយតម្លៃថាតើមានមូលហេតុត្រឹមកម្រិតអប្បរមាគ្គី ដើម្បីឲ្យជឿជាក់បានថា សកម្មភាពណាមួយដែលមានចែងក្នុងវិធាន ៣៥(១) ត្រូវបានប្រព្រឹត្តឡើងឬយ៉ាងណានោះ និងសម្រេចចាត់វិធានការសមស្របដើម្បីអនុវត្ត ប្រសិនបើមាន ដោយអនុលោមតាមវិធាន ៣៥(២)[46]។

19. ដូចដែលបានឃើញច្បាស់នៅក្នុងសេចក្តីសម្រេចនេះហើយ មិនមានភស្តុតាងណាមួយដែលថាអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានពិនិត្យទៅលើការចោទប្រកាន់ទាំងនោះ ដូចដែលបានបញ្ជាក់ពីមុនរួចមកហើយ ការកត់សម្គាល់ និងអង្គហេតុដទៃទៀត ព្រមទាំងកាលៈទេសៈជុំវិញការលាលែងរបស់ចៅក្រម Kasper-Ansermet មិនត្រូវបានយកមកពិនិត្យទាល់តែសោះ នៅក្នុងសេចក្តី

---

[45] យើងប្រើប្រាស់ពាក្យមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើល ដោយសារតែគ្មាននរណាម្នាក់នៅអ.វ.ត.ក មានឆន្ទៈចាត់វិធានការប្រកបដោយប្រសិទ្ធិភាពប្រឆាំងនឹងការជ្រៀតជ្រែករបស់រដ្ឋាភិបាល ទាំងស្ថាប័នជាតិ និងអន្តរជាតិ "គាំទ្រលោកចៅក្រម Blunk ឬ Kasper-Ansermet ឡើយ ហើយយើងគ្រាន់តែអាចប៉ាន់ស្មានអំពីមូលហេតុទាំងនេះតែប៉ុណ្ណោះ។

[46] *សូមមើល* ឯកសារ **E-176/2/1/1** "បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥" ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ លេខ 00815298-00815309 "បណ្តឹងសាទុក្ខប្រឆាំងនឹង ហ៊ុន សែន" កថាខណ្ឌ ២៦។

សម្រេចនេះទេ។ មូលហេតុនេះតែមួយអាចតម្រូវឱ្យបដិសេធសេចក្តីសម្រេចនេះចោល។

20. សំខាន់ជាងនេះទៅទៀតនោះ អង្គជំនុំជម្រះសាលាដំបូង មិនបានវាយតម្លៃតាមមធ្យោបាយណាមួយថាតើមានមូលហេតុត្រឹមកម្រិតអប្បរមាក្តី ដើម្បីឱ្យជឿជាក់បានថា សកម្មភាពណាមួយដែលមានចែងក្នុងវិធាន ៣៥(១) ត្រូវបានប្រព្រឹត្តឡើងឬអត់នោះទេ។ នៅក្នុងចំណាត់របស់ខ្លួនដើម្បីច្រានសំណើសុំនេះចោល ដោយយោងទៅលើមូលដ្ឋានដែលចោទថាមានភាពច្រំដែល និងនៅក្នុងការផ្តោតការយកចិត្តទុកដាក់ទាំងងងឹតងងុលទៅលើការបំបែកសំណុំរឿង ០០២ និងសំណុំរឿង ០០៣/០០៤ អង្គជំនុំជម្រះសាលាដំបូងមិនធ្លាប់ដែលបានពិនិត្យមើលអង្គហេតុ ដែលលើកឡើងនៅក្នុងសំណើសុំរបស់មេធាវីការពារក្តីឡើយ។

21. វចនាសម្ព័ន្ធនៃសេចក្តីសម្រេចនេះកំពុងតែបង្ហាញឱ្យឃើញថា សំអាងហេតុជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូងអាចរកឃើញនៅក្នុងចំណងជើងរង "សំណើសុំឱ្យមានវិធានការ"[47]។ ច្បាស់ហើយថា នៅក្នុងការឈានទៅដល់ការសម្រេចសេចក្តីរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានផ្តោតទៅលើ *សំណើសុំ* (ដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថាជាបញ្ហាធ្ងន់ធ្ងរ) ហើយបានច្រានចោលសំណើសុំ ដោយសារតែសំណើសុំនេះឯង។ ប៉ុន្តែ នេះមិនមែនជានីតិវិធីដែលសមស្រប ដើម្បីធ្វើការវាយតម្លៃទៅលើសំណើសុំ ដោយអនុលោមតាមវិធាន ៣៥ នោះទេ៖ ដូចដែលបានលើកឡើងរួចមកហើយ ដំបូង អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចពិនិត្យទៅលើការចោទប្រកាន់ ហើយបន្ទាប់មក ត្រូវសម្រេចថាតើមានមូលហេតុឱ្យជឿបានថា មានបុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តអំពើណាមួយ ដែលជាការរំលោភទៅលើវិធាន ៣៥ ដែរឬអត់។ អង្គជំនុំជម្រះសាលាដំបូងមិនបានបំពេញកាតព្វកិច្ចទាំងពីរនេះទេ។ បន្ទាប់ពីអនុវត្តនីតិវិធីទាំងពីរនេះរួច ទើបអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចថាត្រូវចាត់វិធានការណាមួយនោះ[48]។

---

[47] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៩ ដល់ ១៤។

[48] ត្រូវកត់សម្គាល់ថា មូលហេតុដែលមានចែងក្នុងវិធាន ៣៥ ដែលជាការធានាការពារដល់សច្ចភាពនៃដំណើរការនីតិវិធី មិនអាចត្រូវបានដោះស្រាយដោយងាយៗ ដោយការបដិសេធសំណើសុំ អនុលោមតាមវិធាន ៣៥ *ដែលសម្អាងទៅលើសំណើសុំឱ្យចាត់វិធានការនោះទេ៖* នៅក្នុងស្ថានភាពដែលភាគីមួយស្នើសុំផ្អាកដំណើរការនីតិវិធី ដោយសារតែមូលហេតុនៃការជ្រៀតជ្រែកនេះ ហើយតាមពិតទៅអង្គជំនុំជម្រះសាលាដំបូងរកឃើញមូលហេតុដែលឱ្យជឿជាក់ថា មានជនណាម្នាក់បានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការផ្អាកដំណើរការនីតិវិធី គឺជាវិធានការមួយធ្ងន់ធ្ងរបំផុត។ មូលហេតុដែលមានចែងនៅក្នុងវិធាន ៣៥ អាចបញ្ជាក់ថា គំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន អង្គជំនុំជម្រះត្រូវចាត់បណ្តឹងសាទុក្ខភ្លាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

22. ត្រូវកត់សម្គាល់បន្ថែមទៀតថា សនិទានភាពនៅក្នុងវិធាន ៣៥ ដែលជាការធានាការពារដល់សុចរិតភាពនៃដំណើរការនីតិវិធី មិនស្របទៅនឹងការបដិសេធសំណើសុំ អនុលោមតាមវិធាន ៣៥ *ដោយសំអាងទៅលើសំណើសុំនោះទេ* ៖ នៅក្នុងស្ថានភាពដែលភាគីមួយសុំផ្អាកដំណើរការនីតិវិធី ដោយសារតែមូលហេតុនៃការជ្រៀតជ្រែកនេះ ហើយអង្គជំនុំជម្រះសាលាដំបូងពិតជារកឃើញមូលហេតុដែលឲ្យជឿជាក់ថា មានជនណាម្នាក់បានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការផ្អាកកិច្ចដំណើរការនីតិវិធី គឺជាវិធានការមួយធ្ងន់ធ្ងរពេក។ សនិទានភាពនៅក្នុងវិធាន ៣៥ អាចបញ្ជាក់ថា *តាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន* អង្គជំនុំជម្រះត្រូវចាត់វិធានការបន្ថែមទៀត ដូចបាន ប្រមើលមើលក្នុងវិធាន ៣៥(២)៖ ដឹកនាំការស៊ើបសួរបន្ថែម ឬបញ្ជូនបញ្ហានេះទៅឲ្យអាជ្ញាធរមានសមត្ថកិច្ច ជាជាងការបដិសេធសំណើសុំនេះចោល។ វិធាន ៣៥ មិនមែន ហើយក៏មិនអាចក្លាយ ជានីតិវិធីដែលភាគីជាអ្នកកំណត់ឡើយ។ អង្គជំនុំជម្រះសាលាដំបូងមានផលប្រយោជន៍របស់ខ្លួនស្រាប់ក្នុងការការពារដល់សុចរិតភាពនៃដំណើរការនីតិវិធី។

23. បញ្ហាដែលបានលើកឡើងនេះបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានអនុវត្តតាមការណែនាំអំពីការពិចារណាលើសំណើសុំ ដោយអនុវត្តតាមវិធាន ៣៥ ដូចដែលបានកំណត់ឡើងយ៉ាងច្បាស់នៅក្នុងករណីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនោះទេ ហើយ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គច្បាប់។ អាស្រ័យហេតុនេះ សេចក្តីស្រេចបែបនេះគួរត្រូវបានបដិសេធចោល។

24. បន្ថែមលើនេះទៅទៀត ត្រូវកត់សម្គាល់ថា មូលហេតុមួយក្នុងចំណោមមូលហេតុដែលយកមកសំអាងដើម្បីច្រានចោលសំណើសុំនេះ គឺថា អង្គជំនុំជម្រះសាលាដំបូងធ្វើការអះអាងទាំងមិនត្រឹមត្រូវ និងដូចជាលេងឆាកល្ខោន ថា មេធាវីការពារក្តីកំពុងស្នើឲ្យ "បើកកិច្ចស៊ើបសួរទូទៅ *ដោយមិនមានកំណត់*" អំពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជាទៅលើភាពត្រឹមត្រូវនៃសំណុំរឿង ០០២[49]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមយ៉ាងពិតប្រាកដ (និងយ៉ាង

---

វិធានការបន្ថែមទៀត ដូចមានចែងក្នុងវិធាន ៣៥(២)៖ ដឹកនាំការស៊ើបសួរបន្ថែម ឬ បញ្ជូនបញ្ហានេះទៅឲ្យអាជ្ញាធរមានសមត្ថកិច្ច។

[49] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៤ (មានសេចក្តីបញ្ជាក់បន្ថែម)។

យកចិត្តទុកដាក់) ដូចទៅនឹងការកំណត់ចរិតលក្ខណៈរបស់ ក.ស.ព មកលើសំណើរបស់យើងខ្ញុំ[50] ប៉ុន្តែ តាមពិតទៅ អង្គជំនុំជម្រះសាលាដំបូងលើកឡើងដោយមិនត្រឹមត្រូវនូវអ្វីដែលមេធាវីការពារក្តីបានស្នើសុំនោះ ដែលមិនមែនជាការសុំឱ្យស៊ើបសួរដោយមិនមានកំណត់នោះទេ ប៉ុន្តែ ស្នើសុំឱ្យបើកកិច្ចស៊ើបសួរមួយ*ឱ្យបានពេញលេញ* ដែលនេះជាសំណើសុំដែលពិបាកនឹងត្រូវចាត់ទុកថាជាសំណើដែលទាមទារដ៏ច្រើនលើសកំណត់ណាស់[51]។ សំណើរបស់យើងខ្ញុំប្រហែលជាអាចទទួលបានភាពប្រសើរជាងនេះឆ្ងាយណាស់ ប្រសិនបើយើងខ្ញុំបានស្នើសុំឱ្យមានកិច្ចស៊ើបសួរមួយដោយព្រាវៗ និងគ្រាន់តែបង្គ្រប់កិច្ចនោះ។ ទោះជាតាមមធ្យោបាយណាក៏ដោយ ក៏ការបកស្រាយខុសចំពោះសំណើសុំរបស់យើងខ្ញុំ ដោយប្រើភាសាដែលមានបំណងបន្តុះបង្អាប់សំណើរបស់យើង ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើនោះ ហើយបន្ទាប់មកបន្តទៅបដិសេធសំណើសុំដោយយោងទៅលើ*មូលដ្ឋាន* នៃការកំណត់ចរិតលក្ខណៈមិនត្រឹមត្រូវនេះ គឺជាការរំលោភលើឆន្ទានុសិទ្ធិហើយ។

iv <u>អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយមិនត្រឹមត្រូវថា ព្រឹត្តការណ៍នៅក្នុងសំណុំរឿង ០០៣/០០៤ មិនពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទេ</u>

25. ចំណុចដែលអង្គជំនុំជម្រះសាលាដំបូងឈានដល់ការពិភាក្សាប្រកបដោយហេតុផលទៅលើសំណើសុំនេះ គឺនៅត្រង់កថាខណ្ឌ ១០ ដោយអង្គជំនុំជម្រះសាលាដំបូងលើកឡើងថា៖ "អង្គជំនុំជម្រះក៏បានបដិសេធសំណើមុនៗស្រដៀងគ្នានេះរបស់មេធាវីការពារក្តី នួន ជា ដោយស្នើសុំឱ្យមានកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ ដោយហេតុថា មេធាវីការពារក្តីពុំបានចង្អុលបង្ហាញអំពីផលប៉ះពាល់ជាក់ស្តែងណាមួយ ដែលបានចោទប្រកាន់ទៅលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ គឺសេចក្តីសម្រេចមួយដែលបានទទួលការឯកភាពពីអង្គជំនុំជម្រះ

---

[50] *សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩-១០។

[51] តាមពិតទៅ យើងខ្ញុំមិនទាំងបានស្នើសុំឱ្យបើកកិច្ចស៊ើបសួរពេញលេញទៅលើការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជាមកក្នុងកិច្ចការរបស់ អ.វ.ត.ក (ដែលជាកិច្ចការមួយមិនអាចយកជ័យជំនះឱ្យបានទេ សូម្បីតែស្ថាប័នតុលាការដែលមានឆន្ទៈ និងមានធនធានគ្រប់គ្រាន់ក៏ដោយ)។ យើងខ្ញុំបានស្នើសុំឱ្យបើកកិច្ចស៊ើបសួរទៅលើផលប៉ះពាល់ដោយការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជាទៅលើ*ភាពត្រឹមត្រូវ*នៃសំណុំរឿង ០០២ គឺមិនមែនសំណើសុំដែលគ្មានហេតុផលនោះទេ ប្រសិនបើអ្នកណាម្នាក់កំពុងធ្វើជាតំណាងឱ្យជនជាប់សង្ស័យនៅក្នុងរឿងក្តីនេះ។

តុលាការកំពូលនៅក្នុងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ[52]។ ស្រដៀងគ្នានេះដែរ សំណើរបស់ នួន ជា នាពេលបច្ចុប្បន្នខកខានពុំបានបញ្ជាក់ ឬបង្ហាញភស្តុតាងឲ្យបានច្បាស់លាស់ អំពីផលប៉ះពាល់ទៅលើការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅក្នុងសំណុំរឿង *០០២/០១* ដោយសារតែការលាឈប់របស់ចៅក្រម Kasper-Ansermet ពីកិច្ចស៊ើបសួរតាមផ្លូវតុលាការលើសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ នោះឡើយ"[53]។

26. សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សំណើសុំដែលខកខានពុំបានបញ្ជាក់ ឬបង្ហាញភស្តុតាងឲ្យបានច្បាស់លាស់ អំពីផលប៉ះពាល់ទៅលើការជំនុំជម្រះដែលកំពុងតែប្រព្រឹត្តទៅក្នុងសំណុំរឿង *០០២/០០១* ដោយសារតែការលាឈប់របស់ចៅក្រម Kasper-Ansermet ពីកិច្ចស៊ើបសួរតាមផ្លូវតុលាការលើសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ មិនត្រឹមត្រូវឡើយ[54]។ ចាប់តាំងពីដើមដំបូងមកម្ល៉េះ មេធាវីការពារក្តីទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទូលំទូលាយនៅក្នុងបញ្ហាទាំងនេះ ហើយមានលក្ខណៈល្អប្រសើរជាងអង្គជំនុំជម្រះតុលាការកំពូល ក្នុងការវាយតម្លៃអំពីផលប៉ះពាល់នៃការចោទប្រកាន់លើផ្នែកអង្គហេតុរបស់យើង

---

[52] ត្រូវកត់សម្គាល់ថា សំណើមុនៗគឺ *មិន* "ដូចគ្នាទាំងស្រុង" ទៅនឹងសំណើសុំនាពេលបច្ចុប្បន្ន ដូចដែលអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវបែបនេះទេ។ អង្គជំនុំជម្រះសាលាដំបូងមិនយល់ពីកាលៈទេសៈដែលមិនសំខាន់ណាស់ណាដែលថា ខុសពីសំណើមុនៗ សំណើសុំនាពេលបច្ចុប្បន្ននេះមិនមែនសម្អាងតែទៅលើការលាលែងរបស់សហចៅក្រមស៊ើបអង្កេតមួយរូបនោះទេ ប៉ុន្តែ ពេលនេះ គឺយោងទៅលើការលាឈប់របស់*សហចៅក្រមស៊ើបអង្កេតអន្តរជាតិទីពីរ* ដែល*ខ្លួនគាត់ផ្ទាល់*បានរៀបរាប់ក្នុងពេលនេះថា *មានការជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់គាត់*។ *សូមមើល* ឯកសារលេខ **E-116** "សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E51/3. E82. E88 and E92)" ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១ ERN 00729330-00729339 ("សេចក្តីសម្រេចពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ") (ដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកសម្អាងនៅក្នុង សេចក្តីសម្រេចដែលរងការជំទាស់ ដើម្បីគាំទ្រដល់អំណះអំណាងរបស់ខ្លួនដែលថា ការចោទប្រកាន់ទាំងឡាយនៅក្នុងសំណើសុំគឺ "ដូចគ្នាយ៉ាងខ្លាំង" ទៅនឹងការចោទប្រកាន់ដែលអង្គជំនុំជម្រះបានដោះស្រាយរួចមកហើយ)។

[53] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១០។

[54] *សូមមើល* សំណើសុំ។ ដូចដែលបានលើកឡើងពីមុនរួចមកហើយ សំណើសុំនេះមិនបានចោទប្រកាន់ពីផលប៉ះពាល់ដោយសារតែការលាលែងរបស់ចៅក្រម Kasper-Ansermet ទៅលើសំណុំរឿង ០០២/០០១ នោះឡើយ។ ផ្ទុយទៅវិញ សំណើសុំមានលក្ខណៈទូលំទូលាយជាងនេះទៅទៀត ដែលអង្គជំនុំជម្រះសាលាដំបូងបានមើលរំលងទៅវិញនេះនោះ។ ចំណុចនេះបង្កើតបានជាមូលហេតុឯករាជ្យនៃបណ្តឹងឧទ្ធរណ៍។

ខ្ញុំទៅលើដំណើរការនីតិវិធីនៅចំពោះមុខខ្លួន[55]។ ប៉ុន្តែ មិនមានអ្នកវិនិច្ឆ័យសេចក្តីប្រកបដោយសុភវិនិច្ឆ័យណាម្នាក់ អាចមើលរំលងចំពោះសារៈសំខាន់ *ជាបឋម (prima facie)* នៃអង្គហេតុជុំវិញការលាឈប់របស់ចៅក្រម Kasper-Ansermet ទៅលើកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បានទេ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានរំលោភឆន្ទានុសិទ្ធិ ឬបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយការអនុវត្តលក្ខខណ្ឌតម្រូវនៃវិធាន ៣៥ ដោយមិនត្រឹមត្រូវ។

*សំណើសុំបានបញ្ជាក់យ៉ាងច្បាស់ថា អ.វ.ត.ក ក្នុងនាមជាស្ថាប័នមួយ ហើយជាពិសេសគឺ ក.ស.ច.ស តែម្តង ត្រូវបានធ្វើឱ្យប៉ះពាល់ដោយសារការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា*

27. សំណើសុំ *ពិតជាបានបង្ហាញ* ថាតើហេតុអ្វី និងដោយវិធីណា ដែលព្រឹត្តិការណ៍នៅក្នុងសំណុំរឿង ០០៣/០០៤ ពាក់ព័ន្ធនឹងសំណុំរឿង ០០២ ដែរនោះ[56]។ ការកត់សម្គាល់របស់ចៅក្រម Ansermet បញ្ជាក់ច្បាស់ហើយថា មន្ត្រីកម្ពុជាទាំងអស់នៅ អ.វ.ត.ក ជំពាក់គុណរាជរដ្ឋាភិបាលកម្ពុជា ហើយពួកគេមិនអាចបំពេញភារកិច្ចរបស់ខ្លួនដោយសេរី នៅក្នុងលក្ខណៈមួយឯករាជ្យពិតៗបានទេ។ មេរៀនដែលបានពីការកត់សម្គាល់របស់ចៅក្រម Ansermet បង្ហាញថា កម្រិត និងការរាលដាលនៃឥទ្ធិពលរបស់រដ្ឋាភិបាលមកលើកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក មានភាពខ្លាំងក្លា ដោយរាប់តាំងពីការបដិសេធមិនចុះហត្ថលេខាដើម្បីបើកកិច្ចស៊ើបសួរ រហូតដល់ការលាក់ត្រាជាផ្លូវការរបស់ចៅក្រមអន្តរជាតិ ពីចៅក្រមនៅថ្នាក់លើបំផុត រហូតដល់អ្នកបើកបរដែលស្ថិតនៅថ្នាក់ក្រោមបំផុត។ បុគ្គលិកទាំងអស់នេះ រួមទាំងចៅក្រម យូ ប៊ុនឡេង ផង *គឺសុទ្ធតែជាអ្នក* ដែលបានបំពេញការងារក្នុងសំណុំរឿង ០០២ ដូចគ្នា។ ដូច្នេះ មូលហេតុគឺសាមញ្ញបំផុត។ *ប្រសិនបើ* មន្ត្រីកម្ពុជាមិនមានឯករាជ្យពិតប្រាកដនៅក្នុងសំណុំរឿង ០០៣/០០៤ (ហើយយើងខ្ញុំសូមលើកឡើងថា ការកត់សម្គាល់បង្ហាញឱ្យឃើញលើសពីវិមតិសង្ស័យថា ពួកគេមិនមានឯករាជ្យទេ) មិនមានមូលហេតុជាចម្បងណាដែលអាចឱ្យសន្មតថា ពួកគេមានឯករាជ្យគ្រប់គ្រាន់នៅក្នុងសំណុំរឿង ០០២ នោះទេ។ បុគ្គលិកខ្លះអាចងាយទទួលរងការគាបពីរដ្ឋាភិបាល ឬបុគ្គលិកខ្លះអាចមិនងាយរង

---

[55] *សូមមើល* សេចក្តីសម្រេចពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ៣៣ ។

[56] *សូមមើល* សំណើសុំ កថាខណ្ឌ ១៩ ដល់ ២០។

ការគាបសង្កត់[57]។ អាចនិយាយម្យ៉ាងទៀតថា ការជាប់ពាក់ព័ន្ធនៃព្រឹត្តិការណ៍ទាំងឡាយក្នុងសំណុំរឿង ០០៣/០០៤ គឺច្បាស់ណាស់ ហើយតាមពិតទៅបានលើកឡើងនៅក្នុងសំណើសុំរួចមកហើយ។ អាស្រ័យហេតុនេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា មេធាវីការពារក្តីខកខានពុំបានបញ្ជាក់ ឬបង្ហាញផលប៉ះពាល់ឲ្យបានច្បាស់លាស់ គឺជាការយល់ខុសទាំងស្រុង និងជាការរំលោភឆន្ទានុសិទ្ធិទៀតផង[58]។

28. ជាការពិតហើយ ទោះបើជាមានការបំបែកកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នៅក្នុងសំណុំរឿងដាច់ដោយឡែកពីគ្នា កិច្ចស៊ើបសួរទាំងអស់ត្រូវបានធ្វើឡើង*ដូចៗគ្នា* ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត*តែមួយ*។ ប្រហែលជាសំខាន់ជាងនេះទៅទៀតនោះគឺថា សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ជាចៅក្រមស៊ើបអង្កេតតែម្នាក់នៅទូទាំងកិច្ចស៊ើបសួរទាំងមូល។ ការបំបែកសំណុំរឿងទៅជាផ្នែកតូចៗ គឺគ្មានអ្វីក្រៅតែពីការប្រឌិតឡើង*ឲ្យស្របតាមផ្លូវច្បាប់* តែប៉ុណ្ណោះ ។ ការប្រឌិតនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយកដោយអំណរសាទរ ប៉ុន្តែការប្រឌិតនេះមិនបានកែប្រែតថភាពពិតនៃបញ្ហាដែលបានលើកឡើងទាល់តែសោះ ដែលថាការិយាល័យដែលមានបង្ហាញថាមានភាពពុករលួយ*តែមួយ*[59] ដែលទទួលរ៉ាប់រងគ្រប់កិច្ចស៊ើបសួរ

[57] តាមការពិត *គោលបំណង*របស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងសមណុំរឿងនីមួយៗមានលក្ខណៈខុសគ្នា ប៉ុន្តែ នេះមិនទាន់និយាយដល់ពីអំណាចរបស់រដ្ឋាភិបាលដើម្បីជះឥទ្ធិពលមកលើមន្ត្រីកម្ពុជាផង ប្រសិនបើរដ្ឋាភិបាលចង់។ ពិតហើយថាដូចដែលយើងខ្ញុំបានជំទាស់គវាំជាច្រើនដង ឥទ្ធិពលរាជរដ្ឋាភិបាលកម្ពុជាមកលើសំណុំរឿង ០០២ អាច*មានលក្ខណៈល្អិតពិបាកឲ្យយល់*ជាងសំណុំរឿង ០០៣/០០៤ (ទោះបីជាពេលខ្លះគេអាចមើលឃើញច្បាស់ក៏ដោយ ដូចជាការមិនព្រមចូលខ្លួនរបស់សាក្សីនៅជួររដ្ឋាភិបាលជាដើម) ដោយសារថា សំណុំរឿង ០០២ ត្រូវបានរៀបចំឡើងឲ្យស្របតាមជំហររដ្ឋាភិបាររបស់ល ហ៊ុន សែន ដូចជា ការផ្តន្ទាទោសជនសង្ស័យតែមួយក្តាប់តូច ដោយមិនការស៊ើបអង្កេតឲ្យបានទូលំទូលាយទៅលើការទទួលខុសត្រូវរបស់ថ្នាក់ក្រោមៗ។ ទោះជាយ៉ាងណាក៏ដោយ ឥទ្ធិពលនេះបានធ្វើឲ្យសាលាក្តីមិនមានឯករាជ្យពិតៗនោះឡើយ។

[58] ដូចដែលបានបញ្ជាក់នៅក្នុងសំណើសុំរួចមកហើយ ប្រសិនបើស្វែងយល់ឲ្យបានច្បាស់លាស់ទៅ ការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជា អាច*មានលក្ខណៈល្អិតពិបាកយល់*ជាងសំណុំរឿង ០០៣/០០៤។ ដោយសារតែហេតុផលនេះហើយ ទើបមេធាវីការពារក្តីស្នើសុំឲ្យបើកកិច្ចស៊ើបសួរអំពីការជ្រៀតជ្រែកនេះ ដោយសារតែវិសាលភាពនៃការជ្រៀតជ្រែកនេះនៅតែមិនច្បាស់លាស់នៅឡើយនោះ។

[59] *សូមមើល* ការថ្លែងយោបល់គ្នារបស់ចៅក្រម Downing និងចៅក្រម Lahuis ដែលបកស្រាយលម្អិតអំពីការកែប្រកាលបរិច្ឆេទមុនក្រោយគ្នា និងការកែប្រែឯកសារច្បាប់ស្ងាត់ៗ៖ ឯកសារលេខ **D-11/2/4/4** "សាធារណៈ (ឯកសារដែលបានកោសលុប) សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក រ៉ូប៊ឺត ហាមីល (Robert Hamill)" ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០១១ បណ្តឹងសាទុក្ខភ្ជាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

នៅក្នុងសំណុំរឿងទាំងអស់នេះ។

29. "តក្កសាស្ត្រ" ដែលទាញយកពាក្យពេចន៍ពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល[60] ដែលមេធាវីការពារក្ដីបានលើកឡើងនៅក្នុងសំណើសុំ គឺមានភាពសាមញ្ញបំផុត។ ប្រសិនបើមានភស្ដុតាងរឹងមាំ ផ្ទាល់ និងមិនអាចជំទាស់បានដែលថា អង្គភាពស៊ើបអង្កេតចម្បងរបស់ស្ថាប័នមួយ ដែលបើកចំហ (និងធ្វើសកម្មភាពតាមនោះ) ឲ្យទទួលរងឥទ្ធិពលដោយផ្ទាល់ពីខាងក្រៅនៅក្នុងការបំពេញកិច្ចស៊ើបសួររបស់ខ្លួន នោះមានន័យថា រាល់កិច្ចស៊ើបសួររបស់ស្ថាប័នស៊ើបអង្កេតមួយនេះធ្វើឲ្យមានភាពមន្ទិលសង្ស័យ ជាពិសេស នៅក្នុងរឿងក្ដីដែលជាប់ពាក់ព័ន្ធទៅនឹងនយោបាយយ៉ាងខ្លាំង និងពិសេសបំផុត រឿងក្ដីដែលមានអង្គហេតុជាប់ពាក់ព័ន្ធពីម្នាក់ទៅម្នាក់យ៉ាងជិតដិតបំផុតនោះ។ (សូមមើលផងដែរ កថាខណ្ឌ ៣៨ ដល់ ៤៣ នៃបណ្ដឹងសាទុក្ខនេះ)។

30. មេធាវីការពារក្ដីសូមលើកឡើងថា អង្គហេតុដែលបានរៀបរាប់នៅក្នុងកំណត់សម្គាល់របស់ចៅក្រម Kasper-Ansermet និងនៅក្នុងសេចក្ដីប្រកាសព័ត៌មានរបស់គាត់ រួមជាមួយនឹងការចាកចេញរបស់ចៅក្រម Blunk ដោយសារតែការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលមកលើការស៊ើបអង្កេតរឿងក្ដីទាំងនេះ[61] ក៏ដូចជាមតិយោបល់ខ្វែងរបស់ចៅក្រម Lahuis និងចៅក្រម Downing ផ្ដល់ហេតុផលពេញលេញឲ្យជឿបានថា ក.ស.ច.ស យ៉ាងហោចណាស់ក៏ខាងភាគីកម្ពុជាដែរ ស្ថិតនៅក្រោមការគាបសង្កត់ពីមជ្ឈដ្ឋានខាងក្រៅជាបន្តបន្ទាប់ ជាហូរហែរ និងប្រកបដោយឥទ្ធិពល ដើម្បីឲ្យទទួលបានលទ្ធផលជាក់លាក់ ឬដើម្បីស្វែងរក ឬមិនស្វែងរក ការស៊ើបអង្កេតជាក់លាក់មួយចំនួននោះ។ កាលៈទេសៈទាំងអស់ដែលបានរៀបរាប់នៅក្នុងសំណើររបស់យើងខ្ញុំ ក៏ដូចជាសំណើមុនៗ ដោយអនុលោមតាមវិធាន ៣៥ អាចត្រូវបានយកមកបន្ថែមទៅលើការកត់សម្គាល់នេះ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ថា រាជរដ្ឋាភិបាលកម្ពុជាមិនចង់ឲ្យសំណុំរឿង ០០៣/០០៤ មានដំណើរការទៅមុខទេ ហើយនឹងចាត់វិធានការតំហ៊ុកដើម្បីសម្រេចបានលទ្ធផល

---

ERN 00748542-00748564 ("បណ្ដឹងឧទ្ធរណ៍នៅចំពោះមុខ អ.ប.ជ") កថាខណ្ឌ ១២ ដល់ ១៦។ *សូមមើលផងដែរ* "សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ" ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ (សេចក្ដីប្រកាសព័ត៌មានរបស់ចៅក្រម ប៊្លុង "Blunk" ដែលប្រកាសពីការលាឈប់របស់គាត់ដោយសារតែការជ្រៀតជ្រែកកាន់រីករាលដាលពីសំណាក់រដ្ឋាភិបាល។

[60] *សូមមើល* សេចក្ដីសម្រេចពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ៣៣។

[61] សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក ដោយសហចៅក្រមស៊ើបអង្កេតអន្តជាតិ" ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១។

នេះ ព្រមទាំងបានបោះបង់វិធីសាស្ត្រនេះទេ បើទោះជាត្រូវប្រឈមមុខដោយផ្ទាល់ជាមួយនឹងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិក៏ដោយ។ រូបភាពនេះគឺច្បាស់ហើយសម្រាប់អ្នកសង្កេតការណ៍ប្រកបដោយសុភវិនិច្ឆ័យដែលថា រាជរដ្ឋាភិបាលកម្ពុជាកំពុងតែរាំងយ៉ាងសកម្មមកលើការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣/០០៤ និងទទួលបានជោគជ័យតាមរយៈការធ្វើបែបនេះ។ សេចក្តីសន្និដ្ឋានបែបនេះ គួរតែនាំឱ្យអង្គភាពតុលាការដែលគោរពខ្លួនឯងនៅ អ.វ.ត.ក ឱ្យបំពេញកិច្ចស៊ើបសួរអំពីការជ្រៀតជ្រែកពីខាងក្រៅចូលក្នុងតុលាការរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រសិនបើមានបំណងលើកកម្ពស់ "សុចរិតភាពនៃកិច្ចដំណើរការតុលាការ"[62]។

31. តាមពិតទៅ ស្ថាប័នតុលាការទាំងអស់នៅក្នុង អ.វ.ត.ក សប្បាយនឹងការបញ្ជូនបញ្ហាចម្រូងចម្រាស់នៃការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលនេះ ទៅកាន់សហការីរបស់ពួកគេតែប៉ុណ្ណោះ[63]។ ស្ថាប័នទីមួយៗនៅ អ.វ.ត.ត ក៏ក្លាយជាមានជំនាញនៅក្នុងការពន្យល់ថាហេតុអ្វីបានជាខ្លួនមិនមែនជាអ្នកដោះស្រាយទៅលើការចោទប្រកាន់អំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលនោះដោយលាក់ទុកពីខាងក្រោយខ្នងនូវការបែងចែកសមត្ថកិច្ចតុលាការ លក្ខខណ្ឌក្នុងការពិនិត្យទៅលើបណ្តឹងឧទ្ធរណ៍ និងការស៊ើបអង្កេតគ្មានន័យជាច្រើនដងដែលត្រូវបានចាត់តាំងនោះ[64]។ *លទ្ធផលចេញ* ពីជំហរ

[62] *សូមមើល* ឯកសារលេខ **D-314/2/7** "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ក លើសំណើសុំឱ្យកោះហៅសាក្សី" ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ ERN 00527392-00527420 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស")។

[63] ឧទាហរណ៍ *សូមមើល* ឯកសារលេខ **D-314/3** "ដីកាឆ្លើយតបចំពោះសេចក្តីសម្រេចរបស់ អ.ប.ជ ទៅលើបណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យកោះហៅសាក្សី ដែលប្តឹងដោយ នួន ជា និង អៀង សារី" ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ERN 00532792-00532794កថាខណ្ឌ ៦ ( ក.ស.ច.ស "នឹងទុកលទ្ធភាពបំពេញការងារនេះឱ្យអង្គបុរេជំនុំជម្រះ ដែលមានអង្គហេតុជាឯកសារទាំងអស់ជាអ្នកសម្រេចថាតើគួរបង្គាប់ឱ្យមានកិច្ចស៊ើបសួរ ឬមិនគួរឱ្យមាន ដោយអនុលោមតាមវិធាន ៣៥(២)")។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស (ទុកបញ្ហានៃការបង្ខំសាក្សីក្នុងជួររដ្ឋាភិបាលឱ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកដោះស្រាយវិញ)។ សេចក្តីសម្រេចពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ២១ ("អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កិច្ចស៊ើបសួរដែលធ្វើឡើងអនុលោមតាមវិធាននេះ អាចនឹងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពដោយស្ថាប័នតុលាការ ដែលទទួលសំណុំ។រឿងនេះតែប៉ុណ្ណោះ។ ដោយសារក្នុងពេលបច្ចុប្បន្ន រឿងក្តីទាំងអស់នេះកំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរ ដូច្នេះ ជាដំបូង ស្ថាប័នដែលមានសមត្ថកិច្ចគឺ ស.ច.ស ហើយបន្ទាប់មក គឺ អង្គបុរេជំនុំជម្រះ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍។

[64] មូលហេតុចំពោះភាពស្មុគស្មាញបែបនេះ គឺអាចយល់បានទេ។ កិច្ចស៊ើបសួរ *ទាំងឡាយ*ដែលធ្វើឡើងដោយចៅក្រមឯករាជ្យ (ហើយ ប្រហែលជាចៅក្រមអន្តរជាតិ) អំពីការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលមកលើកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក

របស់ចៅក្រមបែបនេះ អាចព្យាករជាមុនបាន និងគួរតែឲ្យចៅក្រម និងអ្នកឃ្លាំមើលធ្វើការពិចារណា នៅពេលធ្វើការបង្ហាញស្ថិតិដែលគួរឲ្យស្រងាកចិត្ត និងគួរឲ្យអៀនខ្មាស់។ មិនមានការស៊ើបអង្កេតតាមផ្លូវតុលាការម្តងណា[65] ត្រូវបានធ្វើឡើងដោយស្ថាប័នតុលាការនៅ អ.វ.ត.ក ទៅលើការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលនេះទេ ទោះបីជាមកដល់ពេលនេះ មានចៅក្រមអន្តរជាតិពីររូបបានលាលែង ដោយសារតែបញ្ហានេះក៏ដោយ[66]។

---

នឹងចៀសមិនពីការឆ្លើយតបដោយសេរីពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលនេះនឹងបញ្ជាក់ឲ្យឃើញថា អ.វ.ត.ក មិនមែនជាស្ថាប័នឯករាជ្យនោះទេ ហើយរាជរដ្ឋាភិបាលកម្ពុជា *មិនទទួល*ខុសត្រូវចំពោះស្ថាប័នតុលាការណាមួយនោះក្នុងប្រទេសកម្ពុជា សូម្បីតែ អ.វ.ត.ក ដែលគាំទ្រដោយ អ.ស.ប ក៏ដោយ។ ចៅក្រមអន្តរជាតិនៅ អ.វ.ត.ក ដឹងអំពីបញ្ហានេះ។ ពួកគេក៏ដឹងផងដែរថាខ្លួនគ្មានអំណាចប្រឆាំងនឹង រាជរដ្ឋាភិបាលកម្ពុជានោះទេ ហើយពួកគេអាចសម្ងំនៅស្ងៀមដោយមិនបានអះអាងថា ការស៊ើបអង្កេតរបស់ខ្លួននឹងត្រូវបានរារាំងនោះទេ។ ពួកគេមិនទាន់ភ្លេចនៅឡើយទេថា សូម្បីតែ Ban Ki-Moon ក៏ត្រូវបាន ហ៊ុន សែន គំរាមកំហែងដែរ។ ហើយសូម្បីតែ អ.ស.ប ទាំងមូលក៏គ្មានអំណាចអ្វីដែរ នៅពេលដែលខ្លួនប្រឈមមុខនឹងបញ្ហានៃការជ្រៀតជ្រែកពីសំណាក់នីតិប្រតិបត្តិមកក្នុងកិច្ចការរបស់ អ.វ.ត.ក។ នៅពេលដែលយើងខ្ញុំ ដែលជាក្រុមមេធាវីការពារក្តីយល់ពីភាពស្មុគស្មាញរបស់ចៅក្រមអន្តរជាតិណាម្នាក់ការជ្រៀតជ្រែកជំទាស់តវ៉ាទៅនឹងអំណាចផ្តាច់មុខរបស់ ហ៊ុន សែន និងគណៈបក្សប្រជាជនកម្ពុជា យើងខ្ញុំជឿជាក់ថា វាមានសារៈប្រយោជន៍ក្នុងការព្យាយាមបែបនេះ។ វាជាការប្រសើរក្នុងការតស៊ូចង់បានតុលាការដែលឯករាជ្យ និងរដ្ឋាភិបាលដែលមានការទទួលខុសត្រូវ ហើយវាប្រហែលជាអាចចាញ់ តែវាគ្រាន់បើជាងធ្វើពុតថា មិនមានការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលនោះ (ឬនិយាយដោយងាយបំផុតនោះ គឺត្រូវឲ្យសហការីជាអ្នកស៊ើបអង្កេត)។ យើងខ្ញុំសូមអំពាវនាវឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើជាគំរូសម្រាប់ អ.វ.ត.ក និងជាចុងក្រោយ បើកកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ ដែលអូសបន្លាយពេលជាយូរមកហើយនោះ។

[65] ត្រូវកត់សម្គាល់ថា នៅក្នុងលិខិតលាលែងរបស់គាត់ ចៅក្រម Blunk បញ្ជាក់ថា គាត់បានផ្តួចផ្តើមដំណើរការនីតិវិធីស្តីពី "ការមាក់ងាយតុលាការ" ប្រឆាំងនឹងរដ្ឋមន្ត្រីក្រសួងព័ត៌មាន ប្រសិនបើបញ្ហានេះវាពិតជាពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ មែននោះ។ ការផ្តួចផ្តើមនេះត្រូវបានបញ្ឈប់ទៅវិញដោយសារការលាឈប់របស់ចៅក្រម Blunk។

[66] តាមពិតទៅ វាគួរឲ្យអស់សំណើចដែរ ជំហរនេះផ្ទុយគ្នានឹងការដាក់ទណ្ឌកម្មមកលើមេធាវីការពារក្តី ដែលត្រូវបានរាយការណ៍ជូនទៅគណៈមេធាវីរបស់មេធាវីម្នាក់ៗ (គ្រង់ផ្នែកខ្លះ) ចំពោះការលើកឡើងនៅក្នុងតុលាការ ពីឈ្មោះសាក្សីនៅក្នុងជួររដ្ឋាភិបាលដែលមិនបានមកបង្ហាញខ្លួន ទោះបីជាពួកគេត្រូវបានកោះហៅតាមផ្លូវច្បាប់ក៏ដោយ។ *សូមមើល* ឯកសារលេខ E-214/1 "កំហុសវិជ្ជាជីវៈរបស់មេធាវី ដែលបានចុះបញ្ជីជាមួយគណៈមេធាវីរបស់លោក/លោកស្រី" ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២ ទំ ERN 00821219-00821229 ព័រ ៣។ គួរកត់សម្គាល់ថា ឥរិយាបថរបស់សាក្សីគឺជា*ការរំលោភដោយផ្ទាល់*ជាក់ស្តែងទៅលើដីការបស់ចៅក្រម ហើយហេតុដូច្នេះ វាពិតជាស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃវិធាន ៣៥។ *សាក្សីទាំងនេះ*មិនត្រូវបានដាក់ទណ្ឌកម្មតាមរូបភាពណាមួយ ឬសូម្បីតែមិនបានគំរាមថានឹងដាក់ទណ្ឌកម្មផង តែផ្ទុយទៅវិញ ការប្រឹងប្រែងរបស់មេធាវីការពារក្តីដើម្បីលើកបញ្ហានេះឡើង បែរជាមានការដាក់បណ្តឹងទៅគណៈមេធាវីរបស់យោងខ្ញុំទៅវិញ។ សារដែលអង្គជំនុំបណ្តឹងសាទុក្ខភ្ជាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

*កំណត់សម្គាល់នេះ បង្កើតបានជាលំនាំពាក់ព័ន្ធមួយ*

32. កំណត់សម្គាល់នេះ ក៏មានសារៈសំខាន់សម្រាប់មូលហេតុមួយផ្សេងទៀតដែរ។ វាជួយដល់ការបង្កើត*គំរូមួយ* ដែលភ្ជាប់សំណុំរឿង ០០២ និងសំណុំរឿង ០០៣/០០៤។ មេធាវីការពារក្ដីបានប្រកាន់យកជំហរនេះជាយូរមកហើយថា រាជរដ្ឋាភិបាលកម្ពុជាកំពុងតែជ្រៀតជ្រែកចូលមកក្នុងកិច្ចការរបស់ អ.វ.ត.ក ហើយបុគ្គលិកកម្ពុជា រួមទាំង ចៅក្រម និងសហព្រះរាជអាជ្ញាផង ពិតជាបានទទួលរងឥទ្ធិពលពីសំណាក់សកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការបង្ហាញឱ្យឃើញយ៉ាងច្បាស់ក្រឡែតមួយក្នុងចំណោមការលាតត្រដាងជាច្រើននៃហេតុការណ៍នេះគឺថា មន្ត្រីកម្ពុជាមិនដែលបដិសេធ ឬរារាំងដល់ជំហរច្បាស់ក្រឡែតរបស់រាជរដ្ឋាភិបាលចំពោះបញ្ហានយោបាយម្ដងណាឡើយ។ មេធាវីការពារក្ដីបានបង្ហាញឱ្យឃើញជាច្រើនដងមកហើយថា បុគ្គលិកកម្ពុជានឹងធ្វើយ៉ាងណាឱ្យកិច្ចការតុលាការ និងសកម្មភាពជាក់ស្ដែងរបស់ពួកគេ ពីពេលមួយទៅពេលមួយមាន*ភាពស្របគ្នាឥតខ្ចោះ* ទៅនឹងជំហររបស់រដ្ឋាភិបាលកម្ពុជាដែលបានលើកឡើង។ នេះគឺជា*គំរូមួយ* ហើយវាជាគំរូដែលគេអាចឃើញនៅក្នុងរឿងក្ដីទាំងអស់ ដែលកំពុងតែត្រូវបានស៊ើបអង្កេតនៅចំពោះមុខសាលាក្ដីនេះ។ មូលហេតុដូចគ្នានេះផងដែរ ការគាំទ្រដល់រឿងប្រឌិតដែលថា មានការញែកដាច់ពីគ្នាពាក់ព័ន្ធនឹងផ្លូវច្បាប់រវាងសំណុំរឿង ០០២ និងសំណុំរឿង ០០៣/០០៤ គឺជាការព្រងើយកន្តើយដោយមានចេតនា ចំពោះការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលមកក្នុងកិច្ចការរបស់ អ.វ.ត.ក។ វាអាចជារឿងប្រឌិតមួយដែលមានលក្ខណៈងាយស្រួលសម្រាប់អង្គជំនុំជម្រះ តែវាក៏មិនមានមូលដ្ឋាននៅក្នុងតថភាពពិតទេ[67]។ ត្រង់ចំណុចនេះហើយដែលកំណត់សម្គាល់នេះ

---

ជម្រះសាលាដំបូងចង់បញ្ជូនទៅនេះ គឺច្បាស់លាសហើយ។ ប៉ុន្តែ វាមិនមែនជាសារដែលកម្ពុជាចង់ស្ដាប់ឮពីតុលាការមួយដែលមានលក្ខណៈអន្តរជាតិ ដូចជា អ.វ.ត.ក នេះឡើយ។

[67] ឧទាហរណ៍ រដ្ឋាភិបាលមានជំហរថា សាក្សីក្នុងជួររដ្ឋាភិបាលទាំងប្រាំមួយរូប មិនគួរមកផ្ដល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក នោះទេ តាមពិតទៅ នៅក្នុងស្ថាប័នតុលាការកម្ពុជា*ទាំងអស់*ដែលមានការប៉ះពាល់ (ជា លាង, យូ ប៊ុនឡេង និងចៅក្រមនៃ អ.ប.ជ) បានសម្របសម្រួលសកម្មភាពរបស់ពួកគេដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នាឥតខ្ចោះជាមួយនឹងជំហររបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងរបៀបដូចគ្នាបេះបិទនេះដែរ ចៅក្រម និងព្រះរាជអាជ្ញាកម្ពុជា បានជំទាស់ទៅនឹងការស៊ើបអង្កេតបន្ថែមទៅលើជនសង្ស័យក្នុងសំណុំរឿង ០០៣/០០៤ ដោយការសម្របសម្រួលសកម្មភាពរបស់ពួកគេ ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នាឥតខ្ចោះជាមួយនឹងជំហររបស់រាជរដ្ឋាភិបាលកម្ពុជា។ ប្រសិនបើការសម្របសម្រួល ឬការធ្វើឱ្យស៊ីសង្វាក់គ្នាបែបនេះពីសំណាក់បុគ្គលិកកម្ពុជា ជាមួយនឹងរដ្ឋាភិបាលកើតឡើងម្ដង នោះគេអាចអាចជំទាស់តវ៉ាថា វាកើតមានឡើងដំណាលគ្នា (ទោះបីវាមិនធ្លាប់កើតឡើងដំណាលគ្នាក៏ដោយ)។ ប៉ុន្តែ ប្រសិនបើវា កើមានឡើងជាញឹកញាប់ នោះវាកាន់តែពិបាកខ្លាំងមែនទែនក្នុងការលើកឡើងបណ្ដឹងសាទុក្ខភ្ជាមប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

បង្ហាញឱ្យឃើញយ៉ាងជាក់ច្បាស់។ វា *បង្ហាញឱ្យឃើញច្បាស់* លើសពីវិមតិសង្ស័យថា លំនាំទាំងឡាយដែលមេធាវីការពារក្តីបានយកមកបង្ហាញនៅក្នុងសំណើមុនៗរបស់ខ្លួន គឺពិតជាសញ្ញាណនៃដំណើរការអំពើពុករលួយដូចដែលបានលើកឡើងមែន។ ចៅក្រមកម្ពុជា និងបុគ្គលិករបស់ខ្លួន នឹងធ្វើអ្វីដែលចាំបាច់បំផុត ដើម្បីធានាថា ពួកគេនឹងមិនងាកចេញពីបន្ទាត់នយោបាយរបស់រដ្ឋាភិបាល ដែលបានកំណត់ឡើងនោះឡើយ និងកំពុងតែមានឆន្ទៈចូលរួមក្នុងការជ្រៀតជ្រែកយ៉ាងសកម្មមកលើកិច្ចការរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បីសម្រេចបានគោលបំណងទាំងនោះថែមទៀតផង។ អាចនិយាយម្យ៉ាងទៀតបានថា កំណត់សម្គាល់នេះ *បញ្ជាក់*ថា មេធាវីការពារក្តីបានលើកឡើងយ៉ាងត្រឹមត្រូវទាំងអស់។ រាជរដ្ឋាភិបាលកម្ពុជា *ពិតជា* ជ្រៀតជ្រែកមកលើកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ហើយបុគ្គលិកកម្ពុជា *ងាយទទួលរង* ការជ្រៀតជ្រែកបែបនេះណាស់ ហើយជាការពិត ពួកគេបានសម្របសម្រួលកិច្ចការរបស់ខ្លួនដើម្បីបំពេញបំណងរបស់រដ្ឋាភិបាល។ ដូច្នេះ ការយល់ឃើញទាំងនេះ ធ្វើឱ្យសំណើរមុនៗរបស់មេធាវីការពារក្តីទៅលើបញ្ហាទាំងអស់នេះស្ថិតក្នុងបរិបទពាក់ព័ន្ធមួយ ដោយសារការយល់ឃើញទាំងនេះជួយពង្រឹងដល់សញ្ញាណនៃលំនាំបែបនេះបន្ថែមទៀត ដូច្នេះ វាផ្តល់ការគាំទ្រដល់សំណើមុនៗទាំងនេះ។

*កំណត់សម្គាល់នេះចោទប្រកាន់មកលើចៅក្រម យូ ប៊ុនឡេង*

33. ជាការពិត កំណត់សម្គាល់នេះក៏ជាប់ពាក់ព័ន្ធនៅក្នុងន័យថា វាជាការចោទប្រកាន់ខ្លាំងៗមកលើចៅក្រម យូ ប៊ុនឡេង។ កំណត់សម្គាល់នេះរៀបរាប់អំពី "ការបែងចែកជាទូទៅនៅ អ.វ.ត.ក[68]" រវាងមន្ត្រីខាងភាគីជាតិ/ខាងភាគីអន្តរជាតិ ហើយដាក់ការចោទប្រកាន់ចំពោះការបែងចែងនេះទៅ

---

ទាំងមុខស្មើថា បុគ្គលិកកម្ពុជាកំពុងតែធ្វើប្រតិបត្តិការក្នុងរបៀបមួយដែលឯករាជ្យនោះ។ ដោយសារតែ *មូលហេតុនេះ*ផងដែរ សកម្មភាព និងការស្តែងចេញពីសំណុំរឿង ០០៣/០០៤ គឺមានការជាប់ពាក់ព័ន្ធ នៅពេលធ្វើការវាយតម្លៃការអះអាងថាមានការជ្រៀតជ្រែកខាងនយោបាយមកក្នុងសមណុំរឿង ០០២ នោះ។ សកម្មភាពទាំងនោះ *ជួយបង្កើន*ដល់គំរូបែបនេះ និងផ្តល់នូវបរិបទមួយ ដែលអាចយកមកវាយតម្លៃទៅលើសកម្មភាពមុនៗក្នុងសំណុំរឿង ០០២ បាន។

[68] កំណត់សម្គាល់៖ យោងតាមបទពិសោធន៍របស់គាត់ *ក្នុងចំណោមបទពិសោធន៍ជាច្រើនទៀត* ជាមួយ WESU ចៅក្រម Kasper-Ansermet និយាយពី អ.វ.ត.ក ទាំងមូលដែលត្រូវបានបែងចែកខ្សែរយៈខាងជាតិ និងខ្សែរយៈខាងអន្តរជាតិ ជាជាងមាន ក.ស.ច.ស តែមួយទៅវិញ។ មេធាវីការពារក្តីសូមចែករំលែកទស្សនៈរបស់ចៅក្រម Kasper-Ansermet ទៅលើបញ្ហានេះ។

លើចៅក្រម យូ ប៊ុនឡេង ផ្ទាល់តែម្តង[69]។ ចៅក្រម យូ ប៊ុនឡេងបាន "ជំទាស់គ្រប់វិធានការដែលសមភាគីរបស់គាត់បានព្យាយាមអនុវត្តដើម្បីបន្តកិច្ចស៊ើបសួរ"[70]។ ចៅក្រម Kasper-Ansermet លើកឡើងដោយចំៗបន្ថែមថា ចៅក្រម យូ ប៊ុនឡេង "ជាប្រភពដើមនៃការបរិសេធមិនសហការជាមួយការស៊ើបអង្កេត [ដែលផ្តួចផ្តើមឡើងដោយវិធាន ៣៥ ជាធរមាន]" អំពីការជ្រៀតជ្រែកមកលើការស្វែងរកយុត្តិធម៌ឱ្យបានត្រឹមត្រូវនៅក្នុងករិយាល័យរបស់គាត់។ នេះមិនមែនជាការចោទប្រកាន់មួយដែលបានលើកឡើងយ៉ាងសាមញ្ញពីសំណាក់ចៅក្រមម្នាក់ប្រឆាំងនឹងចៅក្រមម្នាក់ទៀតនោះទេ។ លើសពីនេះទៅទៀត ទាក់ទងនឹងការបន្តជំទាស់របស់ចៅក្រម យូ ប៊ុនឡេង ប្រឆាំងនឹងការតែងតាំងចៅក្រម Kasper-Ansermet ឱ្យកាន់តួនាទីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិពេញសិទ្ធិនោះ កំណត់សម្គាល់របស់ចៅក្រម Kasper-Ansermet លើកឡើងអំពីការមន្ទិលសង្ស័យចំពោះអនាគតិភាពរបស់ចៅក្រម យូ ប៊ុនឡេង[71]។ ចៅក្រម Kasper-Ansermet យល់ឃើញថា យោបល់របស់ចៅក្រម យូ ប៊ុនឡេង "មិនមានមូលដ្ឋានគតិយុត្តិឡើយ"[72] ហើយការជំទាស់យ៉ាងសកម្មរបស់ចៅក្រម យូ ប៊ុនឡេង "ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីទាំងអស់"[73]។

34. កំណត់សម្គាល់បង្ហាញថា ចៅក្រម យូ ប៊ុនឡេង គឺជាមនុស្សម្នាក់ដែលមានបេសកកម្ម គឺបេសកកម្មជំទាស់នឹងសកម្មភាពរបស់ចៅក្រម Kasper-Ansermet និងរារាំងមិនឱ្យមានការស៊ើបអង្កេតទៅលើសំណុំរឿង ០០៣/០០៤ តាមមធ្យោបាយណាមួយដែលចាំបាច់។ តាមពិតទៅ នេះមិនមែនជាលើកទីមួយដែលមានភាពចម្រូងចម្រាស់ជុំវិញបុគ្គលរូបនេះទេ។ កាលពីខែ តុលា ឆ្នាំ ២០១១ ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានរកឃើញយ៉ាងច្បាស់ក្រឡែតថា គាត់បានចុះកាលបរិច្ឆេទត្រឡប់ថយក្រោយ និងបានកែប្រែឯកសារច្បាប់យ៉ាងសម្ងាត់[74] ដែលជាអំពើបាបយ៉ាងធ្ងន់ធ្ងរសម្រាប់អ្នកមានវិជ្ជាជីវៈច្បាប់ និងជាឥរិយាបទមិនគឹកស្មានដល់សម្រាប់ចៅក្រម

---

[69] *សូមមើល* កំណត់សម្គាល់ ត្រង់កថាខណ្ឌ ៥០។

[70] *សូមមើល* កំណត់សម្គាល់ ត្រង់កថាខណ្ឌ ១៣។

[71] *សូមមើល* កំណត់សម្គាល់ ត្រង់កថាខណ្ឌ ១៦ (ទាក់ទងទៅនឹងតួនាទីរបស់ចៅក្រម យូ ប៊ុនឡេង នៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរបស់ប្រទេសកម្ពុជា ដែលមានអំណាចសម្រេចទៅលើការតែងតាំងចៅក្រម Kasper-Ansermet)។

[72] *សូមមើល* កំណត់សម្គាល់ ត្រង់កថាខណ្ឌ ១៧។

[73] *សូមមើល* កំណត់សម្គាល់ ត្រង់កថាខណ្ឌ ១៧។

[74] *សូមមើល* បណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.ប.ជ (យោបល់ខ្វែងរបស់ចៅក្រម Lahuis និងចៅក្រម Downing)។

មួយរូប។ ជាភាសាដែលងាយយល់ ចំណុចនេះអាចបកស្រាយថា គាត់ជាមនុស្សដែលមិនអាចឲ្យទុកចិត្តបាន។ តាមពិតទៅ បើទោះជាមេធាវីការពារក្ដីទទួលយក និងសង្កត់ធ្ងន់ថា សំណើនេះ *មិនមែនជា*បណ្ដឹងជំទាស់ជំនុំជម្រះចៅក្រម យូ ប៊ុនឡេងក្ដី ការជាប់ពាក់ព័ន្ធនឹងភាពមិនស្មោះត្រង់របស់ចៅក្រម យូ ប៊ុនឡេង គឺពិបាកនឹងនិយាយបំផ្លើសណាស់។ សរុបសេចក្ដីមក គាត់ជាមនុស្សដែលបានគ្រប់គ្រង និងរៀបចំការស៊ើបអង្កេតរឿងក្ដីរបស់ នួន ជា។ គាត់ជាមនុស្សម្នាក់ដែលបានចូលរួមសម្រេចទៅលើសំណើទាំងអស់របស់យើងខ្ញុំ ដែលសុំឲ្យបំពេញកិច្ចស៊ើបសួរ ហើយគាត់ក៏ជាមនុស្សម្នាក់ដែលបានចូលរួមសម្រេចថាតើសាក្សីណាខ្លះដែលត្រូវកោះហៅ និងវិធីសាស្ត្រសួររបៀបណាដែលត្រូវអនុវត្តនោះ។ ភស្តុតាងទាំងអស់នៅចំពោះមុខលោកលោកស្រីចៅក្រម មាននៅក្នុងកំណត់សម្គាល់ នៅក្នុងសម្រេចរបស់ អ.ប.ជ និងបានសង្ខេប ឬរៀបរាប់នៅក្នុងសំណើសុំនេះ គឺថា គាត់ជាមនុស្សដែលមិនអាចឲ្យទុកចិត្តបាន ហើយក្រមសីលធម៌វិជ្ជាជីវៈរបស់គាត់មានការមន្ទិលសង្ស័យ[75]។ ពិតហើយថា កង្វះក្រមសីលធម៌វិជ្ជាជីវៈ រួមនឹងនិន្នាការរបស់គាត់ទោរទន់ទៅរកការគាបសង្កត់របស់រាជរដ្ឋាភិបាលកម្ពុជា គឺជាចំណោទបញ្ហា*ជាបឋម ទាំង* សម្រាប់សំណុំរឿង ០០៣/០០៤ និងសំណុំរឿង ០០២ ផង។ អាស្រ័យហេតុនេះ ជំហររបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសម្រេចនៅក្នុងសំណុំរឿង ០០៣/០០៤ មិនធ្វើឲ្យប៉ះពាល់ដល់សំណុំរឿង ០០២ នោះ មិនអាចយកជាការបានឡើយ។ អង្គហេតុដែលងាយបំផុតនោះគឺថា ភាពមិនស្មោះត្រង់របស់ចៅក្រមមួយរូប ដែលត្រូវបានបង្ហាញឲ្យឃើញដោយ (ចៅក្រមអន្តរជាតិដែលមានឯករាជ្យ) គឺពាក់ព័ន្ធ បើផ្អែកលើនិយមន័យហើយ ដោយមិនចាំបាច់និយាយថា គាត់មិនស្មោះត្រង់ជាមួយ"សំណុំរឿងមួយណានោះទេ"។

35. ស្រដៀងគ្នានេះ កំណត់សម្គាល់នេះបង្ហាញប្រាប់យើងអំពីមុខមាត់ដ៏គួរឲ្យខ្លាចរបស់ចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ដែលចៅក្រម Kasper-Ansermet បានចោទប្រកាន់គាត់អំពី "ភាពលម្អៀងជាក់ស្ដែង" និងបានផ្ដួចផ្ដើមនីតិវិធីនៃបណ្ដឹងជំទាស់ជំនុំជម្រះចំពោះរូបគាត់។ សារៈសំខាន់នៃវិធានការនេះគឺមានពិតប្រាកដ៖ ចៅក្រមមួយរូបដែលចាប់ផ្ដើមនីតិវិធីនៃបណ្ដឹងជំទាស់ជំនុំជម្រះចំពោះ

---

[75] ដើម្បីបញ្ជាក់ឲ្យបានច្បាស់ គឺថា នេះមិនមែនជាការអះអាងរបស់*ក្រុមមេធាវីការពារក្ដី*ដែលថា យូ ប៊ុនឡេង មានភាពមិនស្មោះត្រង់ និងកំពុងតែជ្រៀតជ្រែកមកលើការចាត់ចែងយុត្តិធម៌ឲ្យបានត្រឹមត្រូវនោះទេ។ វាជាជំហរដែលបានសម្រេចឡើងដោយចៅក្រមអន្តរជាតិទាំងឡាយ មានដូចជា ចៅក្រម Kasper-Ansermet ដែលមានសរសេរនៅក្នុងកំណត់សម្គាល់របស់គាត់ ចៅក្រម Downing និងចៅក្រម Lahuis នៅក្នុងមតិខ្វែងរបស់ពួកគាត់។

ចៅក្រមមួយរូបទៀត គឺពិតជាករណីដ៏កម្រមួយ ហើយជាវិធានការមួយដែលមិនត្រូវបានដោះស្រាយដោយងាយៗឡើយ។ ប្រការសំខាន់នោះគឺថា ចៅក្រមរូបនោះគឺជាចៅក្រមតែមួយដែលកំពុងធ្វើជាប្រធាន អ.ប.ជ នៅពេលដែល អ.ប.ជ បានឈានដល់ "ការពុំអាចសេចក្ដីសម្រេច" របស់ខ្លួនលើសំណើរបស់យើងដោយអនុលោមតាមវិធាន ៣៥ នៅក្នុងដំណាក់កាលស៊ើបសួរ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាល[76]។ ពុំត្រឹមតែមានការសន្និដ្ឋានថា ការសន្មតអំពីភាពពុំលម្អៀង និងភាពវិជ្ជាជីវៈ ត្រូវបានធ្វើឲ្យប្រឡាក់ ប្រឡូសដោយជៀសមិនផុត តាមរយៈកំណត់ហេតុនេះឡើយ (និងដោយសំអាងហេតុរបស់ចៅក្រម Downing និងចៅក្រម Lahuis នៅក្នុងយោបល់ជំទាស់របស់ពួកគាត់)[77] ឯកសារទាំងនេះក៏បង្ហាញច្បាស់ថា ចៅក្រមរូបនេះគ្រាន់តែអនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះ។ ហេតុដូច្នេះ សេចក្ដីសម្រេចរបស់ អ.ប.ជ *ទាំងអស់* នៅក្នុងដំណាក់កាលបុរេវិនិច្ឆ័យមានវិការៈ *តាមរយៈការវាយតម្លៃជាបឋម* ប៉ុន្តែ ចំណុចនេះមានភាពត្រឹមត្រូវ *ជាពិសេស* ចំពោះការចូលរួមរបស់គាត់ នៅក្នុងការបដិសេធសំណើដោយអនុលោមតាមវិធាន ៣៥។ និយាយម្យ៉ាងទៀត កំណត់សម្គាល់នេះពិតជាពាក់ព័ន្ធ *ផងដែរ* អំពីភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២[78]។

36. ហេតុដូច្នេះ ក្រៅពី និងបន្ថែមពីលើការបញ្ជាក់អំពីលំនាំមួយ កំណត់សម្គាល់នេះមានសារៈសំខាន់ត្រង់ថា វាផ្ដល់ការយល់ដឹងដល់អ្នកអានអំពីការងារ និងសំខាន់ជាងនេះទៀត គឺ *ការខកខាន* របស់ (ភាគីជាតិនៃ) ការិយាល័យ ក.ស.ច.ស (ព្រមទាំង អ.ប.ជ)។ និយាយបែបសាមញ្ញគឺថា

---

[76] *សូមមើល* ឯកសារលេខ D314/1/12 "សាលដីកាលើកទីពីរលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី", ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០, ERN: 00600748-00600774 ("សាលដីកាលើកទីពីរ")។

[77] *សូមមើល* បណ្ដឹងឧទ្ធរណ៍ អ.ប.ជ (យោបល់ជំទាស់របស់ចៅក្រម Lahuis និងចៅក្រម Downing)។

[78] ជាមួយគ្នានេះ កំណត់សម្គាល់បង្ហាញថាចៅក្រមម Kasper-Ansermet បានផ្ដួចផ្ដើមកិច្ចដំណើរការនីតិវិធីដោយអនុលោមតាមវិធាន ៣៥ ប្រឆាំងនឹងមន្ត្រីបុគ្គលជាតិចំនួន ៤ រូប ដើម្បីស៊ើបអង្កេតអំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការដែលត្រូវបានចោទប្រកាន់។ ជាថ្មីម្ដងទៀត សារៈសំខាន់នៃទង្វើទាំងអស់នេះ គឺពិបាកនឹងបញ្ជាក់ឲ្យហួសពីការពិត។ ចៅក្រមមួយដែលបំពេញកិច្ចស៊ើបសួរអំពីជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលតុលាការពីសំណាក់មន្ត្រីបុគ្គលិកនៃស្ថាប័នយុត្តិធម៌នេះ (ក.ស.ច.ស) គឺពិតជាពុំមែនជាការកើតមានជារៀងរាល់ថ្ងៃឡើយ និង *តាមការពិនិត្យជាបឋម* វាមានសារៈសំខាន់នៅពេលធ្វើការវាយតម្លៃអំពីសុចរិតភាពជាទូទៅនៃការិយាល័យនោះ។

ប្រសិនបើការិយាល័យមួយមានភាពពុករលួយ ការិយាល័យនោះច្បាស់ជាត្រូវបានដកចេញនូវការសន្មតអំពីភាពមិនលម្អៀង និងការអនុវត្តតាមបទដ្ឋានសីលធម៌វិជ្ជាជីវៈ ហើយច្បាស់ណាស់ពុំអាចមានការសន្មតថាមាន "មហាកំផែងចិន" រវាងសំណុំរឿង ០០៣/០០៤ និងសំណុំរឿង ០០២ ឡើយ។ ប្រសិនបើនៅក្នុងសំណុំរឿងមួយ ចៅក្រមជាតិ និងមន្ត្រីបុគ្គលិករបស់គាត់ មានឆន្ទៈអនុវត្តដោយពុំស្របច្បាប់ ដើម្បីបន្ទុចបង្អាក់ការងាររបស់ចៅក្រមអន្តរជាតិនោះ ដូច្នេះនៅក្នុងសំណុំរឿងមួយទៀតដែលជាប់ទាក់ទងគ្នាខ្លាំងនោះ ពុំមានហេតុផលណាដែលថាពួកគាត់មិនធ្វើដូចគ្នានេះនៅក្នុងសំណុំរឿងមួយទៀតដែលទាក់ទងគ្នាឡើយ។ ចំណុចនេះត្រូវតែបង្កើតបានជាកម្មវត្ថុនៃកិច្ចស៊ើបសួរដ៏ត្រឹមត្រូវមួយដោយអនុលោមតាមវិធាន ៣៥។ សេចក្តីសម្រេចពុំផ្តួចផ្តើមកិច្ចស៊ើបសួររបស់អង្គជំនុំជម្រះសាលាដំបូងគឺជាការបំពានឆន្ទានុសិទ្ធិ។

37. ដើម្បីជាប្រយោជន៍នៃការលើកទឡ្ហីករណ៍ បើទោះបីជាយើងសន្មតថា សកម្មភាពនៃការជ្រៀតជ្រែកដែលត្រូវបានពិភាក្សានេះ ពុំ "ផ្តល់ផលអាក្រក់" ដល់ នួន ជា ដែលឧទាហរណ៍ដូចជា ក្នុងន័យថា ភស្តុតាងដោះបន្ទុកពុំត្រូវបានប្រមែប្រមូលក៏ដោយ[79] ក៏ នួន ជា នៅមានផលប្រយោជន៍យ៉ាងសាមញ្ញ ដោយផ្ទាល់ និង *ជាបឋម* ក្នុងការទទួលបានកិច្ចស៊ើបសួរមួយដោយស្ថាប័នស៊ើបសួរឯករាជ្យពិតប្រាកដ ដែលប្រកាន់ខ្ជាប់នូវបទដ្ឋានក្រមសីលធម៌ខ្ពស់បំផុតផងដែរ។ ជាការពិត ការទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យគឺជា *សិទ្ធិមួយក្នុងចំណោមសិទ្ធិជាសារវ័ន្តបំផុត* ដែលជនជាប់ចោទមាន។ ហេតុដូច្នេះ នៅពេលមានភាពច្បាស់លាស់ថា ការិយាល័យនេះ *ខ្វះ* នូវឯករាជ្យភាព ឬក្រមសីលធម៌ជាចាំបាច់ នួន ជា មានផលប្រយោជន៍ និងសិទ្ធិ ដើម្បីឲ្យមានការស៊ើបសួរឲ្យបានត្រឹមត្រូវលើបញ្ហានេះ និងដោះស្រាយបញ្ហានេះជាផ្នែកមួយនៃកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥។ យើងខ្ញុំសូមលើកឡើងថា កំណត់សម្គាល់នេះ ព្រមជាមួយភស្តុតាងទាំងអស់ផ្សេងទៀតដូចមានរៀបរាប់ក្នុងសំណើនេះ និងយោបល់ជំទាស់របស់ចៅក្រម Downing និងចៅក្រម Lahuis[80] ធ្វើឲ្យមានភាពច្បាស់លាស់ថា ភាគីកម្ពុជានៃ ក.ស.ច.ស ទាំងមូល និងពិសេសចៅក្រម យូ ប៊ុនឡេង ខ្វះឯករាជ្យភាព និងក្រមសីលធម៌ជាចាំបាច់[81]។ សិទ្ធិរបស់ នួន ជា

---

[79] *សូមមើល* កថាខណ្ឌ ៤២-៤៣, *ខាងក្រោម* សម្រាប់ការពិភាក្សាអំពីបញ្ហានេះ។

[80] *សូមមើល* បណ្តឹងឧទ្ធរណ៍ អ.ប.ជ (យោបល់ជំទាស់របស់ចៅក្រម Lahuis និងចៅក្រម Downing)។

[81] ជាងនេះទៀត ទោះបីទឡ្ហីករណ៍របស់យើងខ្ញុំមិនទាន់សម្រេចក៏ដោយ ក៏គេគួរពិចារណាថា សកម្មភាពមួយចំនួនដែលលោកចៅក្រម យូ ប៊ុនឡេង បានធ្វើក្នុងសំណុំរឿង ០០៣ និង០០៤ ដូចជា "ការលុបហត្ថលេខា" លើដីកាដោះហៅ បានកើតឡើង*ក្នុង* បណ្តឹងសាទុក្ខភ្លាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

ក្នុងការទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ មានន័យថា ត្រូវតែមានការស៊ើបសួរឲ្យបានគ្រប់គ្រាន់អំពីបញ្ហានេះ ដែលជាផ្នែកមួយនៃកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥។

*សំណុំរឿង ០០៣/០០៤ និងសំណុំរឿង ០០២ ត្រូវបានភ្ជាប់ទំនាក់ទំនងដែលមិនអាចកាត់ផ្តាច់បានតាមរយៈជនសង្ស័យ ឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្ម*

38. មានហេតុផលលើសពីនេះដែលនាំទៅដល់ការសន្និដ្ឋានថា អង្គហេតុ និងកាលៈទេសៈជុំវិញការលាលែងពីមុខតំណែងរបស់ចៅក្រម Kasper-Ansermet មានភាពពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២។ បើទោះបីជាសំណុំរឿង ០០៣/០០៤ និង សំណុំរឿង ០០២ មានលេខសំណុំរឿងខុសគ្នាក៏ដោយ ក៏សំណុំរឿងទាំងនេះមិនអាចបំបែកចេញពីគ្នាបានឡើយ ពាក់ព័ន្ធនឹងអង្គហេតុជាមូលដ្ឋាន។ សូម្បីតែការពិនិត្យមើលលំៗទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ ក៏បង្ហាញអំពីចំណុចនេះដែរ។ ត្រង់ចំណុចពាក់ព័ន្ធ ដីកានេះសរសេរថា [redacted] »82។

---

*អំឡុងពេល*ស៊ើបអង្កេតក្នុងសំណុំរឿង ០០២។ ប្រសិនបើគេសន្មតថា លោកចៅក្រម យូ ប៊ុនឡេង ធ្វើបែបនេះ ដោយសារតែរងសម្ពាធពីរដ្ឋាភិបាល ដូចដែលមេធាវីការពារបានសន្មតនោះ (ដែលបានបង្ហាញជំហរគាំទ្រក្រោយកើតមានហេតុការណ៍ នៅក្នុងកំណត់សម្គាល់របស់ខ្លួន ដែលបានបង្ហាញថា លោកចៅក្រម យូ ប៊ុនឡេង បានសម្រេចចិត្តគួរឲ្យកត់សម្គាល់ ក្នុងការទប់ស្កាត់មិនឲ្យមានការស៊ើបអង្កេតបន្ថែម ហេតុនេះគាត់បានភ្ជាប់ខ្លួនយ៉ាងច្បាស់ជាមួយនឹងជំហររបស់រាជរដ្ឋាភិបាល) គេត្រូវសន្និដ្ឋានថា លោកចៅក្រម យូ ប៊ុនឡេង ទទួលរងឥទ្ធិពលពីសម្ពាធរបស់រដ្ឋាភិបាល ក្នុងអំឡុងពេលស៊ើបអង្កេតក្នុងសំណុំរឿង ០០២ នោះជាការពិចារណាមួយដែលពាក់ព័ន្ធ។ ចៅក្រមត្រូវមានក្រមសីលធម៌វិជ្ជាជីវៈ ឬមួយគាត់មិនមានទេ។ ចៅក្រមត្រូវឯករាជ្យ ឬមួយគាត់មិនឯករាជ្យទេ។ ការពិតបង្ហាញថា លោកចៅក្រម យូ ប៊ុនឡេង មិនមានទាំងអស់ហ្នឹង។ នេះជាមូលហេតុសម្រាប់បង្ហាញពីកង្វល់ ហើយបានផ្តល់នូវគ្រប់គ្រាន់ក្នុងការចូលរួមការស៊ើបអង្កេតតាមវិធាន ៣៥។

[82] *សូមមើល* "ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសម្រាប់សំណុំរឿង ០០៣", កថាខណ្ឌ ៥ (គូសបញ្ជាក់បន្ថែម)។ កំណត់សម្គាល់៖ ទោះបីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ ជាឯកសារសម្ងាត់ក៏ដោយ ក៏សាធារណជនអាចរកបណ្តឹងសាទុក្ខភ្លាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

39. លើសពីនេះទៀត សំណុំរឿងនីមួយៗមានចំណុចទាក់ទងផ្សេងទៀតដែលពាក់ព័ន្ធគ្នាខ្លាំង។ ជាឧទាហរណ៍ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសម្រាប់សំណុំរឿង ០០៣ [redacted][83] ដែលក្នុងនោះ [redacted] ជនសង្ស័យក្នុងសំណុំរឿង ០០៣) គឺជាសមាជិកជាន់ខ្ពស់។ នួន ជា ត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២ អំពីការទទួលខុសត្រូវរបស់ថ្នាក់លើ (ដូចជា ឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តដោយមនុស្សក្រោមបង្គាប់របស់គាត់ រួមទាំង [redacted]) និងសហឧក្រិដ្ឋកម្មរួម (ដូចជា [redacted] បញ្ចូលទាំង [redacted])។ ជាក់ស្តែង យើងមិនអាចវាយតម្លៃអំពីសកម្មភាព និងការទទួលខុសត្រូវរបស់ [redacted] និង [redacted] ដោយពុំវាយតម្លៃអំពីសកម្មភាព និងការទទួលខុសត្រូវរបស់ នួន ជា បានឡើយ *ហើយយើងក៏មិនអាចវាយតម្លៃអំពីសកម្មភាព និងការទទួលខុសត្រូវរបស់ នួន ជា ដោយពុំវាយតម្លៃអំពីសកម្មភាព និងការទទួលខុសត្រូវរបស់* [redacted] *បានដែរ*។

40. ជាការពិត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ រៀបរាប់យ៉ាងច្រើនអំពីការ [redacted] ត្រូវបានដាក់ឱ្យទទួលខុសត្រូវ[84] និងត្រូវបានចាត់ទុកជា ' [redacted] ប្រការសំខាន់ [redacted] *ដដែល* អស់ទាំងនេះ គឺជាផ្នែកមួយនៃការចោទប្រកាន់ទៅលើ នួន ជា នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២[85]។

---

មើលបានដែរ។ មេធាវីការពារក្តីបានចូលមើលឯកសារនេះនៅលើគេហទំព័រ [redacted] នាពេលថ្មីៗនៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១២ ("IS 003")។ មេធាវីការពារក្តីសូមដាក់ឯកសារនេះទៅក្នុងបណ្តឹងសាទុក្ខនោះ ដោយពិចារណាថា ដោយសារវាជាប្រយោជន៍ផ្ទាល់របស់លោក នួន ជា ហេតុនេះយើងខ្ញុំសូមប្រើព័ត៌មានដែលនៅក្នុងឯកសារនេះ។

[83] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣។

[84] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៣៧។

[85] *សូមមើល* ឯកសារលេខ D427. "ដីកាដំណោះស្រាយ", ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, ERN: 00604508-00605246 ("ដីកាដំណោះស្រាយ") កថាខណ្ឌ [redacted]។

41. បន្ថែមពីលើនេះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នួន ជា ត្រូវបានលើកឡើងថាជាអ្នក [redacted] ដែល នួន ជា ក៏ត្រូវបានចោទប្រកាន់ថាជាសមាជិកមួយរូបផងដែរ។ ជាចុងក្រោយ ផ្នែកដ៏សំខាន់មួយទៀតនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ [redacted] ដែល នួន ជា ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវ។ ផ្ទុយមកវិញ យើងអាចយល់អំពីលំនាំដែលនេះ គឺថា ទាំង [redacted] និង [redacted] សុទ្ធតែត្រូវបានលើកឡើងជាច្រើនលើកច្រើនសានៅក្នុងដីកាដំណោះស្រាយប្រឆាំងនឹង នួន ជា[89]។ ឧទាហរណ៍ គឺកថាខណ្ឌ [redacted] ដែលសរសេរថា៖ [redacted] "រូបភាពផ្ទុះបញ្ចាំង" អំពីហេតុការណ៍នេះ មានសរសេរនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣៖ [redacted] ’[90]។ និយាយម៉្យាងទៀត អង្គហេតុដែលថា នួន ជា [redacted] និង [redacted] ត្រូវបានចោទប្រកាន់ ជាប់ទាក់ទងគ្នា ពាក់ព័ន្ធគ្នា និងជួនកាលដូចគ្នាទៀតផង[91]។

---

[86] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៨៦។

[87] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៩៣។

[58] *សូមមើល* ដីកាដំណោះស្រាយ, កថាខណ្ឌ [redacted]

[89] *សូមមើល* ដីកាដំណោះស្រាយ, កថាខណ្ឌ [redacted] និងជើងទំព័រ [redacted]

[90] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣, កថាខណ្ឌ ៩៣។

[91] ភាពខុសគ្នាតែម្យ៉ាងគត់គឺថាទាក់ទងនឹងអង្គហេតុទាំងនេះ នួន ជា នឹងរមែងត្រូវបានចាត់ទុកជាអ្នកទទួលខុសត្រូវ ហើយ [redacted] និង [redacted] នឹងត្រូវបានចាត់ទុកជាអ្នកអនុវត្តតាមការណែនាំ និង/ឬ ជាអ្នករាយការណ៍ទៅ នួន ជា ប៉ុន្តែអង្គហេតុទាំងនេះពាក់ព័ន្ធគ្នាទៅវិញទៅមក។

ហេតុដូច្នេះ ពុំមានភាពខុសគ្នាជាគោលការណ៍ក្នុងការបែងចែករវាងសំណុំរឿង ០០៣/០០៤ និងសំណុំរឿង ០០២ ទេ។ អង្គហេតុជាមូលដ្ឋាន និងជនសង្ស័យទាំងអស់ បង្កើតបានជាផ្នែកមួយនៃកិច្ចស៊ើបសួរកាន់តែទូលំទូលាយអំពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ។

42. *ដោយសារតែ* សំណុំរឿងទាំងនេះមានភាពត្រួតជាន់គ្នា និងភាពពុំអាចផ្ដាច់ចេញពីគ្នាបាន ទើបការជ្រៀតជ្រែកក្នុងសំណុំរឿង ០០៣/០០៤ តាមនិយមន័យ មានតម្លៃស្មើទៅនឹង ឬត្រូវបានបកស្រាយថាជាការជ្រៀតជ្រែកចូលក្នុងសំណុំរឿង០០២[92]។ ជាបឋម ការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០៣/០០៤ រាំងស្ទះដល់ការវាយតម្លៃអង្គហេតុនានានៅក្នុងសំណុំរឿង ០០៣/០០៤ និងការវាយតម្លៃអង្គហេតុទាំងឡាយដែលជាផ្នែកមួយនៃសំណុំរឿង ០០២ ទៀតផង។ ប៉ុន្តែ ប្រការសំខាន់ជាងនេះទៀត ការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០៣/០០៤ រាំងស្ទះ *ការវាយតម្លៃឱ្យបានត្រឹមត្រូវអំពីកម្រិតនៃស្វ័យភាព* នៃមនុស្សថ្នាក់ក្រោម ដូចជា [redacted] និង [redacted] ជាដើម ហើយវាក៏រាំងស្ទះដល់ការវាយតម្លៃការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២ ផងដែរ។ សរុបសេចក្ដី និងនិយាយឱ្យងាយយល់ ប្រសិនបើមានការរកឃើញ (ដោយ ក.ស.ច.ស) ថា មនុស្សថ្នាក់ក្រោមមានស្វ័យភាពកាន់តែច្រើន ជនជាប់ចោទក្នុងសំណុំរឿង ០០២ ច្បាស់ជាត្រូវបានសន្មតថាមានការទទួលខុសត្រូវកាន់តែតិចចំពោះទង្វើរបស់មនុស្សថ្នាក់ក្រោមទាំងនេះ។ ហើយជាចុងក្រោយ ការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០៣/០០៤ រាំងស្ទះការវាយតម្លៃឱ្យបានត្រឹមត្រូវអំពីប្រព័ន្ធទំនាក់ទំនងការងាររវាងថ្នាក់លើ និងថ្នាក់ក្រោម និងរារាំងការវាយតម្លៃឱ្យបានត្រឹមត្រូវអំពីខ្សែបណ្ដាញនៃការបញ្ជា។ ការជ្រៀតជ្រែកនេះប៉ះពាល់ដោយផ្ទាល់ទៅដល់អង្គហេតុទាំងឡាយនៃសំណុំរឿង ០០២។

43. សារៈសំខាន់នៃចំណុចនេះគឺមានពិតប្រាកដណាស់។ គោលជំហរសំខាន់មួយក្នុងចំណោមគោលជំហរសំខាន់នានារបស់មេធាវីការពារក្ដីក្នុងសំណុំរឿង ០០២ ជានិច្ចកាលគឺថា មន្ត្រីថ្នាក់ក្រោមមានស្វ័យភាពច្រើនក្នុងការអនុវត្ត ជាងអ្វីដែលត្រូវផ្ទុះបញ្ចាំងក្នុងដីកាដំណោះស្រាយ ហើយមន្ត្រីថ្នាក់ក្រោមទាំងនេះ បានរាយការណ៍កាន់តែមិនសូវញឹកញាប់ (និងដោយពុំមានសេចក្ដីលម្អិត) ត្រឡប់មកខ្សែបណ្ដាញ ជាងអ្វីដែលគេបានជឿជាទូទៅ។ មេធាវីការពារក្ដីសូមលើកឡើងថាការស៊ើបសួរ*ដ៏ត្រឹមត្រូវ* អំពីទង្វើ ស្វ័យភាព និងការអនុវត្តការរាយការណ៍របស់មន្ត្រីថ្នាក់ក្រោម និង

[92] យ៉ាងហោចណាស់ វាជាប្រភេទនៃការជ្រៀតជ្រែកផ្នែកនយោបាយក្នុងសំណុំរឿង ០០៣/០០៤ ដែលយើងបានឃើញ។

ផ្ទុះបញ្ជាំងអំពីចំណុចនេះ និងជាភស្តុតាង *ដោះបន្ទុក* ដោយផ្ទាល់។ បើទោះបីជាយ៉ាងណាក៏ដោយ ការជ្រៀតជ្រែកចូលសំណុំរឿង ០០៣/០០៤ រាំងស្ទះដោយផ្ទាល់ និងប៉ះពាល់ដល់កិច្ចស៊ើបសួរលើសំណុំរឿងនេះ ដោយហេតុថា វាបានរាំងស្ទះ (យ៉ាងហោចណាស់ រហូតមកដល់ និងទាល់តែដល់ពេលមានការដាក់សំណើនេះ) កិច្ចស៊ើបសួរ *ប្រកបដោយប្រសិទ្ធភាពនានាទាំងអស់* អំពីតួនាទី និងទង្វើរបស់មន្ត្រីថ្នាក់ក្រោមសំខាន់ៗមួយចំនួន។ ហេតុដូច្នេះ ការជ្រៀតជ្រែកចូលសំណុំរឿង ០០៣/០០៤ ប៉ះពាល់ដោយផ្ទាល់ និងតាមនិយមន័យ ទៅដល់សិទ្ធិរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ ដោយហេតុថា មេធាវីការពារក្តីអះអាងថា ការជ្រៀតជ្រែកនេះរាំងស្ទះដល់ការស្វែងរកភស្តុតាងពាក់ព័ន្ធ និងភស្តុតាងដោះបន្ទុក[93]។ ជាការពិត កំណត់សម្គាល់នេះធ្វើឱ្យមានភាពច្បាស់លាស់ (ហើយសារៈសំខាន់របស់វាមួយផ្នែកគឺស្ថិតនៅត្រង់ការពិតនេះ) ដែលថា ការជ្រៀតជ្រែកពុំមានទំហំតូចឡើយ ឧទាហរណ៍ ពុំមែនទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម ឬសាក្សីជាក់លាក់មួយចំនួនតូចឡើយ ប៉ុន្តែជាការជ្រៀតជ្រែកទាំងស្រុង និងមានវិសាលភាពធំធេង។ ការជ្រៀតជ្រែកនេះមានចេតនាបន្ទុចបង្អាក់កិច្ចស៊ើបសួរទាំងអស់ និងកិច្ចស៊ើបសួរនានាអំពីអង្គហេតុទាំងនេះ។ តាមសំអាងហេតុនោះ យើងមិនអាចជៀសផុតឡើយពីការសន្និដ្ឋានថា ការជ្រៀតជ្រែកនេះបានប៉ះពាល់ដល់កិច្ចស៊ើបសួរអំពីអង្គហេតុ សាក្សី និងកាលៈទេសៈនានា ដែលអាចពាក់ព័ន្ធ[94] ក្នុងសំណុំ

---

[93] មេធាវីការពារក្តីកត់សម្គាល់ឃើញថា ជានិច្ចកាលយើងខ្ញុំមានជំហរថា សម្រាប់ហេតុផលនយោបាយ រាជរដ្ឋាភិបាលនៅតែចង់ឱ្យ *ត្រឹមតែ* ជនជាប់ចោទដែលកំពុងស្ថិតក្រោមការជំនុំជម្រះក្នុងសំណុំរឿង ០០២ នេះជាអ្នកទទួលខុសត្រូវ ហើយប្រជាជននៅទូទាំងប្រទេសនៅតែជនរងគ្រោះទន់ខ្សោយដដែល។ យើងខ្ញុំបានលើកឡើងថា ផែនការនេះត្រូវបានរៀតណាមយកមកអនុវត្តមុនពេលនៅដើមឆ្នាំ ១៩៧៩ ហើយនៅតែមាន និងបានវិវត្តចាប់តាំងពីពេលនោះមក។ ការពិត មូលហេតុមួយក្នុងចំណោមមូលហេតុនានាដើម្បីគាំទ្រជំហរនោះគឺថា មន្ត្រីមួយចំនួនធំដែលកំពុងបម្រើការងារក្នុងជួររដ្ឋាភិបាលបច្ចុប្បន្ន ធ្លាប់ជាមន្ត្រីជាន់ខ្ពស់ ឬថ្នាក់កំពូលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនៅមានភស្តុតាងបង្ហាញថា ពួកគេនៅមានបាតដៃប្រឡាក់ឈាមនៅឡើយ (*សូមមើល* ឯកសារលេខ **E190.1.398**, “ការវាយតម្លៃឡើងវិញអំពីតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ និងមន្ត្រីថ្នាក់មូលដ្ឋានចំពោះឧក្រិដ្ឋកម្មទាំងឡាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ” លេខ ERN 00661455-00661491 (ភាសាអង់គ្លេស))។ ហេតុនេះ រដ្ឋាភិបាលមានប្រយោជន៍យ៉ាងធំធេងក្នុងការគ្រប់គ្រងផែនការនោះនៅ អ.វ.ត.ក និងរក្សាទុករឿងនេះឱ្យអស់ពីសមត្ថភាព ដោយធ្វើយ៉ាងណាឱ្យមានតែជនជាប់ចោទក្នុងសំណុំរឿង ០០២ ប៉ុណ្ណោះដែលសក្តិសមយកមកជំនុំជម្រះ។

[94] សម្រាប់ជាគោលបំណងរបស់សំណើនេះ មេធាវីការពារក្តីមិនទាំងចាំបាច់ចោទប្រកាន់ថា ការស៊ើបអង្កេតនោះមិនបានស្វែងរកភស្តុតាង*ដោះបន្ទុក*នោះផងទេ (ទោះបីជាបានស្វែងភស្តុតាងដោះបន្ទុកនោះក៏ដោយ)។ ការពិតគឺថា គ្រាន់តែភស្តុតាង*ពាក់ព័ន្ធ* និងមាន*តម្លៃជាភស្តុតាង* សម្រាប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ដែលមិនត្រូវបានស៊ើបអង្កេតនេះក៏គ្រប់គ្រាន់សម្រាប់លើកសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរតាមវិធាន ៣៥ បានហើយ។

រឿង ០០២។

44. ជាចុងក្រោយ ពាក់ព័ន្ធនឹងការវាយតម្លៃអំពីឥទ្ធិពលខាងក្រៅ ការបំបែកសំណុំរឿងទាំងនេះចេញពីគ្នាជាដាច់ខាត គឺពុំសមហេតុផលឡើយ ដោយហេតុថា ការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០៣/០០៤ ប៉ះពាល់ដោយផ្ទាល់ទៅលើកិច្ចស៊ើបសួរ និងសិទ្ធិរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២។ ហេតុដូច្នេះ សេចក្តីសម្រេចនេះគឺជាការបំពានឆន្ទានុសិទ្ធិ ឬមានកំហុសអង្គច្បាប់។

v. <u>ការជ្រៀតជ្រែកដោយផ្ទាល់ចូលក្នុងសំណុំរឿង ០០២</u>

45. ថ្វីបើចំណុចខាងលើធ្វើឲ្យមានភាពច្បាស់លាស់ថា ការជ្រៀតជ្រែកក្នុងសំណុំរឿង ០០៣/០០៤ គឺពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ក៏ដោយ ក៏យើងត្រូវតែចង្អុលទៅសញ្ញាច្បាស់លាស់ដែលបង្ហាញអំពីការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០២។ ដូចដែលមេធាវីការពារក្តីបានបញ្ជាក់ សារៈសំខាន់នៃកំណត់សម្គាល់នេះ និងកាលៈទេសៈជុំវិញការលាលែងមុខតំណែងរបស់ចៅក្រម Kasper-Ansermet ស្ថិតនៅត្រង់ថា ចំណុចទាំងនេះផ្តល់ *បរិបទ* ពាក់ព័ន្ធមួយ ដើម្បីពិនិត្យមើលសញ្ញានៅដើមដំបូងដែលបង្ហាញអំពីការជ្រៀតជ្រែក ដែលតាមរយៈនេះ វាបានធ្វើឲ្យសារណាមុនៗកាន់តែមានអំណះអំណាងរឹងមាំបន្ថែមទៀត។

46. អាស្រ័យហេតុនេះ នៅមុនពេលយើងត្រូវបានចោទប្រកាន់អំពីការជំទាស់ជាថ្មីទៅនឹងបញ្ហាជាក់លាក់មួយចំនួន ឬអំពីការដាក់សំណើច្រំដែល ត្រូវតែមានការបញ្ជាក់ច្បាស់លាស់ពីដើមដំបូងអំពីចំណុចមួយដែលថា ថ្វីបើជាការពិតដែលថា អង្គហេតុទាំងឡាយដែលត្រូវបានពិភាក្សាខាងក្រោមគឺជាផ្នែកមួយនៃសារណាមុនៗរបស់មេធាវីការពារក្តីក៏ដោយ ក៏អង្គហេតុទាំងនោះត្រូវបានដាក់នៅក្នុង*បរិបទ* ពាក់ព័ន្ធ *ទៅតាមព័ត៌មានដែលមាននៅក្នុងកំណត់សម្គាល់របស់ចៅក្រម Kasper-Ansermet* (និងក្នុងលិខិតលាលែងពីមុខតំណែងរបស់ចៅក្រម Blunk)។ និយាយជាសាមញ្ញ អង្គហេតុនានាដែលមិនតម្រូវឲ្យមានការសន្និដ្ឋានថា ការជ្រៀតជ្រែករបស់រដ្ឋាភិបាលបានកើតឡើងនៅដំណាក់កាលដំបូង អាចមានសារៈសំខាន់គតិយុត្តិបន្ថែម តាមរយៈហេតុការណ៍ដែលកើតមានឡើងក្រោយអង្គហេតុទាំងអស់នោះ។ នេះពុំមែនជាបញ្ហានៃការជំទាស់ជាថ្មីទៅនឹងបញ្ហាទាំងនេះឡើយ។ នេះគឺជាបញ្ហានៃការបញ្ជាក់អះអាងអំពីសំណើនាពេលបច្ចុប្បន្នតាមរយៈអង្គហេតុនានា

ដែលបាននាំឲ្យមានសំណើនេះ[95]។ គួរកត់សម្គាល់ផងដែរថា នៅដើមដំបូង អង្គហេតុទាំងឡាយដូចមានរៀបរាប់ខាងក្រោមពុំធ្លាប់ត្រូវបាន *ជំទាស់* ដោយភាគីណាមួយឡើយ។ ហេតុដូច្នេះ មេធាវីការពារក្តីពុំមានហេតុផលក្នុងការពុំលើកឡើងអំពីអង្គហេតុដែលពុំត្រូវបានជំទាស់ទាំងនេះ ដើម្បីគាំទ្រ (សំអាងហេតុនៃ) សំណើនេះបន្ថែមទៀតឡើយ។

---

[95] ទោះបីការពិតគឺថា អង្គហេតុជាច្រើនដែលមានក្នុងសំណើនេះបានបង្ហាញពីកម្មវត្ថុនៃរឿងក្តីនៅដំណាក់កាលមុនការជំនុំជម្រះក៏ដោយ ក៏វាជាការសំខាន់ដែលត្រូវមើលទៅលើអ្វីដែលបានកើតឡើងនៅក្នុងរឿងក្តីនោះគឺថា៖ មេធាវីការពារក្តីបានដាក់សំណើចំនួនពីរតាមវិធាន ៣៥ ដែលពាក់ព័ន្ធនឹងការជ្រៀតជ្រែករបស់រដ្ឋាភិបាល។ សំណើលើកទី១ ត្រូវបាន ក.ស.ច.ស ពិចារណាថា *អនុវត្តមិនត្រឹមត្រូវ* ទៅតាមបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ដែលបើតាម អ.ប.ជ យល់ថា សំអាងហេតុនោះបានរារាំងផលសេចក្តីសម្រេចរបស់ ក.ស.ច.ស។ និយាយម្យ៉ាងទៀតគឺថា ត្រូវតែយកទៅពិចារណាខុសពីអ្វីដែល ក.ស.ច.ស បានវាយតម្លៃទាំងស្រុង។ (*សូមមើល* សេចក្តីសម្រេចលើកទី២) ចុងក្រោយ បណ្តឹងឧទ្ធរណ៍ដែលពាក់ព័ន្ធនឹងសំណើដដែលនោះត្រូវបាន អ.ប.ជ បដិសេធ *ដោយសារតែអង្គជំនុំជម្រះនេះមិនអាចចេញសេចក្តីសម្រេចដោយចៅក្រមមតិភាគច្រើន* ដែលតម្រូវដោយវិធាន។ ចំណុចនេះមានន័យថា អង្គហេតុនានាដែលជាមូលដ្ឋាននៃសំណើនោះ មិនត្រូវបានដោះស្រាយតាមអង្គហេតុ និងជាស្ថាពរទេ តែតាមរយៈបណ្តឹងឧទ្ធរណ៍ អ.ប.ជ ត្រឹមតែមិនអាចសម្រេចទៅលើបញ្ហាដែលបានលើកឡើងប៉ុណ្ណោះ។ (ហើយការពិត ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខភ្លាមៗចៅក្រមអន្តរជាតិបានសន្និដ្ឋាននូវសំអាងហេតុពេញលេញដើម្បីជឿបានថា មានមនុស្សបានជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះទៅហើយ ខណៈដែលចៅក្រមជាតិមិនបានសន្និដ្ឋានបែបនោះ ដោយអនុវត្តនូវការបង្ហាញសំអាងហេតុតាមផ្លូវច្បាប់តាមន័យចង្អៀត)។ ចំពោះសំណើលើកទី២ តាមវិធាន ៣៥ វិញ ជាថ្មីម្តងទៀត ក.ស.ច.ស ខកខានមិនបានវាយតម្លៃសំណើនោះទៅតាមអង្គហេតុទេ ក្រៅតែពីបដិសេធសំណើនោះដោយសារបញ្ហាបច្ចេកទេសទៅវិញ ដែលធ្វើឲ្យសេចក្តីសម្រេចនេះត្រូវបាន អ.ប.ជ រារាំងសាជាថ្មី។ ជាថ្មីម្តងទៀត អង្គហេតុនានាដែលបានចោទប្រកាន់មិនត្រូវបាន ក.ស.ច.ស ដែលជាស្ថាប័នស្វែងរកអង្គហេតុ យកមកវាយតម្លៃទេ។ ពេលនេះ អ.ប.ជ ពិតជាបានវាយតម្លៃទៅលើសំណើនោះ តែមិនបានបញ្ចូលការពិចារណាចំពោះសកម្មភាពរបស់លោកចៅក្រម យូ ប៊ុនឡេង និងលោកស្រី ជា លាង ទេ។ ហេតុនេះ ជាថ្មីម្តងទៀត អង្គហេតុដែលពាក់ព័ន្ធគ្រាន់តែមិនត្រូវបានយកមកពិចារណាទេ នៅពេលសម្រេចទៅលើសំណើសុំលើកទី២ តាមវិធាន ៣៥ របស់យើងខ្ញុំ ក្នុងដំណាក់កាលស៊ើបអង្កេត។ (*សូមមើល* ឯកសារលេខ **D384/5/2**, "សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើលើកទី២ របស់លោក នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ (វិធាន ៣៥)", ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១២០, លេខ ERN 00608821-0060883 (ភាសាអង់គ្លេស))។ សម្រាប់តែសំអាងហេតុនេះមួយគឺថា អង្គហេតុទាំងនេះអាចជាមូលដ្ឋានសម្រាប់សំណើ និងបណ្តឹងសាទុក្ខនេះបាន។ ទោះតាមវិធីណាក៏ដោយ ទោះបីគេសន្និដ្ឋានថា អង្គហេតុទាំងនេះ "ត្រូវបានដោះស្រាយយ៉ាងល្អិតល្អន់" នៅក្នុងដំណាក់កាលស៊ើបអង្កេតក៏ដោយ ក៏ពុំមានសំអាងហេតុណាមួយដែលថាអង្គហេតុទាំងនោះមិនអាចលើកយកមកសំអាងដើម្បីគាំទ្រសំណើថ្មីនេះដែរ ដោយផ្អែកលើការវិវត្តន៍ថ្មីៗ ដែលអាចជួយបំភ្លឺលើបញ្ហានានាដែលបានកើតឡើងពីអតីតកាល។ ដូចបានលើកឡើងរួចមកហើយគឺថា អង្គហេតុនេះមិនធ្លាប់ត្រូវបានគេតវ៉ាពីមុនមកទេ ហើយបើតាមលក្ខណៈរបស់វា អង្គហេតុទាំងនេះក៏មិនអាចតវ៉ាបានដែរ (ដូចជាអង្គហេតុដែលថា សាក្សីផ្ទៃក្នុងមិនធ្លាប់មកផ្តល់សក្ខីកម្មមិនត្រូវបានបង្ហាញឈ្មោះទេ តែជាឧទាហរណ៍មួយ)។

47. អង្គហេតុខាងក្រោមគឺជាអង្គហេតុពាក់ព័ន្ធ នៅពេលវាយតម្លៃថាតើមាន "មូលហេតុដែលអាចឲ្យជឿបាន" ដែរឬទេថាបុគ្គលណាម្នាក់បានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលដ៏ត្រឹមត្រូវរបស់តុលាការនៅចំពោះមុខ អ.វ.ត.ក និងពិសេសជាងនេះទៀត គឺការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០២។

- ក្នុងសំណុំរឿង ០០២ ចៅក្រម យូ ប៊ុនឡេង បានបដិសេធពុំចុះហត្ថលេខារួមគ្នាលើដីកាកោះហៅសាក្សីផ្ទែក្នុងចំនួន ៦ រូប។

- ក្នុងសំណុំរឿង ០០២ សាក្សីផ្ទៃក្នុងចំនួន ៦ រូប ពុំបានចូលខ្លួនមកផ្តល់សក្ខីកម្មឡើយ បើទោះបីជាពួកគាត់ត្រូវបានកោះហៅយ៉ាងត្រឹមត្រូវក៏ដោយ។

- ក្នុងសំណុំរឿង ០០២ យ៉ាងហោចណាស់សាក្សីផ្ទៃក្នុងមួយរូបក្នុងចំណោមសាក្សីផ្ទៃក្នុងនានា បានអះអាងថា គាត់ពុំបានបង្ហាញខ្លួន បន្ទាប់ពីត្រូវបានកោះហៅ ដោយហេតុថាមានតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូបប៉ុណ្ណោះដែលបានចុះហត្ថលេខាលើដីកាកោះហៅទាំងនោះ[96]។

- ក្នុងសំណុំរឿង ០០២ សហព្រះរាជអាជ្ញាជាតិ ជា លាង ពុំបានចូលរួមជាមួយសមភាគីអន្តរជាតិរបស់គាត់ក្នុងការកោះហៅសាក្សី ដែលត្រូវបានកោះហៅ ដែលត្រូវបង្ខំឲ្យបង្ហាញខ្លួន ក្នុងករណីចាំបាច់ឡើយ។

- ក្នុងសំណុំរឿង ០០២ ចៅក្រមជាតិនៃ អ.ប.ជ ដែលបានបោះឆ្នោត*ប្លុក* (*en block*) បានសម្រេច (នៅក្នុងការសម្រេចខុសទំនងមួយ) ថា "ពុំមានហេតុផលអាចឲ្យជឿបាន" ថាមានអ្នកណាម្នាក់បានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលដ៏ត្រឹមត្រូវរបស់តុលាការឡើយ ទាក់ទងជាមួយការមិនបង្ហាញខ្លួនរបស់សាក្សីក្នុងជួររដ្ឋាភិបាល ដែលជាការសម្រេចមួយដែលខុសស្រឡះពីការសម្រេចរបស់សហសេវិកអន្តរជាតិរបស់ពួកគាត់។

- *ក្នុងអំឡុង* កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ ចៅក្រម យូ ប៊ុនឡេង បានចុះហត្ថលេខា

[96] នេះពិតជាសញ្ញាបង្ហាញដ៏ច្បាស់លាស់មួយអំពីបទពិសោធន៍ដែលចៅក្រម Kasper-Ansermet នឹងពើបប្រទះនៅពេលប៉ុន្មានឆ្នាំក្រោយទៀត។

និងបន្ទាប់មកបានលុបបាត្តលេខានោះវិញលើដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលអនុញ្ញាតឲ្យមានកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣/០០៤។ និយាយម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេតជាតិរូបនេះបានអនុវត្តចំណាត់ការគតិយុត្តិគួរឲ្យមន្ទិល[97]នៅពេលដែលគាត់កំពុងបំពេញតួនាទីជាចៅក្រមស៊ើបអង្កេតមួយរូបក្នុងសំណុំរឿង ០០២។

- នៅក្នុងសំណុំរឿង ០០២ រាជរដ្ឋាភិបាលកម្ពុជាបានបំផ្លាញដោយជោគជ័យចំពោះការប៉ុនប៉ងរបស់ ក.ស.ច.ស ក្នុងការឲ្យមានការស្តាប់សក្ខីកម្មរបស់នរោត្តម សីហនុ។

48. ពាក់ព័ន្ធនឹងបញ្ហានេះ ហេតុការណ៍ទាំងនេះបានកើតឡើងនៅក្នុងបរិបទនៃសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់តំណាងរាជរដ្ឋាភិបាលកម្ពុជាអំពីគោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជាស្តីអំពីបញ្ហានេះ[98]។ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់គឺថា មន្ត្រីកម្ពុជានៅ អ.វ.ត.ក ជានិច្ចកាលបានសម្រប*យ៉ាងល្អឥតខ្ចោះ* នូវជំហររបស់ពួកគាត់ជាមួយគោលជំហររបស់រដ្ឋាភិបាលរបស់ពួកគាត់ដោយឥតមានការខកខានឡើយ។ មេធាវីការពារក្តីសូមលើកឡើងថា សកម្មភាពទាំងនេះរបស់ចៅក្រម និងព្រះរាជអាជ្ញាកម្ពុជា ប៉ុន្តែពិសេសនៅពេលយើងលើកយកមកពិចារណាក្នុងបរិបទនៃរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយស្តីពីគោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហានេះ ផ្តល់ "មូលហេតុអាចឲ្យជឿបាន" ថាការជ្រៀតជ្រែកពិតជាបានកើតមាន[99]។ ដូចដែលបានគូសបញ្ជាក់

---

[97] ស្ថានភាពនេះនឹងត្រូវបានបញ្ជាក់អះអាងឡើងវិញតាមរយៈហេតុការណ៍នានាដែលនឹងមានក្នុងសំណុំរឿង ០០៣/០០៤។

[98] យើងយោងទៅលើសំណើនេះ ព្រមទាំងសំណើរបស់យើងមុនៗដោយអនុលោមតាមវិធាន ៣៥ នៅក្នុងដំណាក់កាលស៊ើបសួរ សម្រាប់ការពិភាក្សាឲ្យបានកាន់តែលម្អិតថាតើហេតុអ្វីបានជាការជ្រៀតជ្រែករបស់រដ្ឋាភិបាល ត្រូវតែបានទទួលការសន្មតទាក់ទងនឹងបញ្ហាទាំងនេះ។

[99] ចំពោះសំណួរថាតើ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាទៅលើសកម្មភាពរបស់លោកចៅក្រម យូ ប៊ុនឡេង នោះជាសំខាន់ត្រូវយល់ថា៖ អ.ជ.ត.ក បានសម្រេចរួចមកហើយថា "ចៅក្រមយ៉ាងហោចណាស់ស្ថិតនៅក្នុងយុត្តាធិការនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងដែលបានចែងថា ការប្រព្រឹត្តរបស់ចៅក្រមឈានទៅដល់កម្រិតនៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ យោងតាមខ្លឹមសារនៃវិធាននេះ"។ *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខរបស់ អៀង សារី, កថាខណ្ឌ ១៤។ អ.ជ.ត.ក ក៏បានយោងទៅដល់ជំហររបស់ អ.ប.ជ ដែលថា "ការប្រព្រឹត្តដែល*ជាក់ពាក់ព័ន្ធ*នឹងចៅក្រមអាចជាកម្មវត្ថុនៃការស៊ើបអង្កេតផ្អែកតាមវិធាន ៣៥ ទោះបីជាអង្គជំនុំជម្រះមិនមានយុត្តាធិការក្នុងការស៊ើបអង្កេត ឬការដាក់ទណ្ឌកម្មលើចៅក្រមក៏ដោយ" (*ដូចខាងលើ* កថាខណ្ឌ ១៦)។ គេគួរកត់សម្គាល់ថា សម្រាប់ជាគោលបំណងនៃបណ្តឹងសាទុក្ខនេះ អ.ប.ជ បានសម្រេចថា "សកម្មភាព" របស់លោកចៅក្រម យូ ប៊ុនឡេង លោកស្រី ជា លាង និងចៅក្រមជាតិនៅ អ.ប.ជ ដែលបានលើកឡើងខាងលើ "មិនអាចទទួលយកបានទេ" សម្រាប់ជាគោលបំណងនៃការវាយតម្លៃលើសំណើលើកទី១ របស់ នួន ជា បណ្តឹងសាទុក្ខភ្លាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

ការជឿជ្រួះបាន *កើតឡើង* តាមរយៈការលាតត្រដាងនៅក្នុងកំណត់សម្គាល់នេះ។ ការផ្សំបញ្ចូលគ្នានៃអង្គហេតុដែលត្រូវបានលើកឡើងខាងដើម ជាមួយលំនាំដែលត្រូវបានបញ្ជាក់អះអាងជាថ្មី

---

តាមវិធាន ៣៥ ដោយសារ ទាំង ក.ស.ច.ស ទាំង អ.ប.ជ សុទ្ធតែមិនមាន "យុត្តាធិការក្នុងការសម្រេចថា តើសកម្មភាពរបស់លោកចៅក្រម យូ ប៊ុនឡេង [ឬលោកស្រី ជា លាង ឬចៅក្រមជាតិនៅ អ.ប.ជ] បំពេញតាមលក្ខខណ្ឌដើម្បីបើកកិច្ចស៊ើបសួរតាមវិធាន ៣៥(២)(ខ) នៃវិធានផ្ទៃក្នុងទេ"។ *សូមមើល* ឯកសារលេខ **D384/5/2**. "សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើលើកទី២ របស់លោក នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរ (វិធាន ៣៥)", ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១២, លេខ ERN 00608821-00608839 (ភាសាអង់គ្លេស)) កថាខណ្ឌ ៣១, ៣៤, ៣៥ (គូសបញ្ជាក់បន្ថែម)។ ហេតុនេះ ជាការសំខាន់ដែលត្រូវសង្កត់ធ្ងន់ថា សំណើនេះ *មិនបាន*សុំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា តើសកម្មភាពរបស់លោកចៅក្រម យូ ប៊ុនឡេង លោកស្រី ជា លាង និង/ឬ ចៅក្រមជាតិនៅ អ.ប.ជ បានបំពេញ ឬមិនបំពេញតាមលក្ខខណ្ឌដើម្បីបើកកិច្ចស៊ើបសួរនោះទេ។ តាមពិត យើងខ្ញុំបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ពិចារណាឱ្យបានច្បាស់ទៅលើទិដ្ឋភាព *ទាំងមូល* ដែលបង្ហាញនូវសញ្ញាណនៃការជ្រៀតជ្រែករបស់រដ្ឋាភិបាល និងដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការវាយតម្លៃរបស់ខ្លួនទៅលើ រូបភាពពាក់ព័ន្ធ *បឋម* និងឱ្យបានទូលំទូលាយ។ ដើម្បីធ្វើឱ្យប្រាកដថា៖ ពុំមានសំអាងហេតុគ្រប់គ្រាន់ដែលថា សកម្មភាពរបស់ចៅក្រម ទោះបីជាសកម្មភាពតាមផ្លូវតុលាការក៏ដោយ ក៏មិនអាចផ្តល់ភស្តុតាងគាំទ្របានទេ នៅពេលវាយតម្លៃចំពោះការអះអាងថា មានការជ្រៀតជ្រែកពីខាងក្រៅ។ តាមរយៈឧទាហរណ៍ថា៖ ប្រសិនបើចៅក្រមត្រូវបានបុគ្គលណាម្នាក់បង្ខំឱ្យចេញសេចក្តីសម្រេចដោយខុសច្បាប់ *ឧ.* ការលើកលែងការចោទប្រកាន់គួរឱ្យភ្ញាក់ផ្អើលដល់ជនសង្ស័យមួយចំនួននោះ ពុំមានសំអាងហេតុណាមួយបញ្ជាក់ថា អត្ថិភាពនៃការលើកលែងការចោទប្រកាន់គួរឱ្យភ្ញាក់ផ្អើលនោះមិនអាចត្រូវបានយកទៅប្រើដើម្បីគាំទ្រដល់ការសន្និដ្ឋានថាការជ្រៀតជ្រែកពិតជាបានកើតឡើងនោះទេ។ ស្រដៀងគ្នាដែរ ប្រសិនបើលោកចៅក្រម យូ ប៊ុនឡេង បានចូលរួមក្នុងសកម្មភាពតុលាការ និងបានចេញសម្រេចដែលបង្ហាញ ឬបញ្ជាក់ពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលនោះ ពុំមានសំអាងហេតុពេញលេញណាមួយថា មិនត្រូវពិចារណាលើសេចក្តីសម្រេចទាំងនេះទេ នៅពេលវាយតម្លៃថាតើមាន ឬមិនមាន "មូលហេតុអាចឱ្យជឿបាន" ថាការជ្រៀតជ្រែកបានកើតឡើងនោះ។ ការពិត អ.ជ.ត.ក បានយល់ស្របនឹងជំហរនោះដែរ។ *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខរបស់ អៀង សារី។ ជាការពាក់ព័ន្ធដែលត្រូវយកចិត្តទុកដាក់ចំពោះចំណុចទាំងនេះ៖ ទីបំផុត ដោយសារតែ អ.ប.ជ បានផ្តល់សំអាងហេតុផ្លូវការលើបញ្ហានេះហើយនោះ សកម្មភាពតាមផ្លូវតុលាការរបស់ចៅក្រម និងសហព្រះរាជអាជ្ញាជាតិ *មិនបានវាយតម្លៃលើអង្គហេតុ* ដែលជាផ្នែកនៃសំណើតាមវិធាន ៣៥ ទេ។ ទោះជាយ៉ាងណាក្តី ពាក់ព័ន្ធនឹងការផ្តល់សំអាងហេតុរបស់ អ.ជ.ត.ក លើបញ្ហានេះ គួរតែថា៖ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងឯកសារលេខ E137/5/1/3, ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ (ហេតុនេះហើយ សូម្បីនៅមុនពេលដាក់សំណើនេះក៏ដោយ) មានពាក្យពេចន៍ច្បាស់ៗពាក់ព័ន្ធនឹងករណីនោះ ហើយអង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចតាមផ្លូវច្បាប់ដើម្បីគោរពទៅតាមការណែនាំទាំងនោះ និងត្រូវបញ្ចូលសកម្មភាពពីមុនៗរបស់លោកចៅក្រម យូ ប៊ុនឡេង ដែលបានយោងទៅក្នុងសំណើរនេះ ក្នុងការវាយតម្លៃរបស់ខ្លួន ជាអ្វីដែលការិយាល័យផ្សេងទៀតនៅ អ.វ.ត.ក មិនបានយល់ថាជាការចាំបាច់ដែលត្រូវធ្វើបែបនេះទេ នោះហើយជាលទ្ធផលដែលនាំឱ្យមានការយល់ខុសចំពោះលក្ខខណ្ឌចាំបាច់នៃវិធាន ៣៥។

ដោយកំណត់សម្គាល់នេះ ពិតជានាំឲ្យមានការសន្និដ្ឋានថា មានមូលហេតុអាចឲ្យជឿបានថាមានមនុស្សបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលដ៏ត្រឹមត្រូវរបស់តុលាការ និងគួរតែបាននាំឲ្យអង្គជំនុំជម្រះសាលាដំបូងបំពេញកិច្ចស៊ើបសួរមួយដោយអនុលោមតាមវិធាន ៣៥។ អង្គជំនុំជម្រះសាលាដំបូងបានបំពានទៅលើឆន្ទានុសិទ្ធិរបស់ខ្លួនដោយពុំបានបើកកិច្ចស៊ើបសួរនោះ។

*ការមិនព្រមគោរពតាមដីកានេះឯង (per se) បង្កើតទៅជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ*

49. បើទោះជាអង្គជំនុំជម្រះសាលាដំបូងពុំជឿជាក់តាមការលើកឡើងរបស់ក្រុមមេធាវីការពារក្ដីថា ការជ្រៀតជ្រែកពីខាងក្រៅដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានេះហើយទើបបានជាបណ្ដាលឲ្យសាក្សីពុំចូលខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងគួរតែផ្ដួចផ្ដើមបើកការស៊ើបអង្កេតអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដោយគ្រាន់តែផ្អែកលើករណីសាក្សីមិនបង្ហាញខ្លួនដូច្នេះ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងប្រឈម (សារជាថ្មី) នឹងបញ្ហានេះនៅក្នុងសំណើសុំ។ អង្គជំនុំជម្រះតុលាការកំពូល ទើបតែ *ក្នុងពេលថ្មីៗនេះ* បានលើកឡើងអំពីមតិយោបល់របស់ខ្លួនលើករណីដែលសាក្សីមិនព្រមគោរពតាមដីកាទាំងនេះ នៅពេលអង្គជំនុំជម្រះតុលាការកំពូលបានឯកភាពទៅតាមការលើកឡើងរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃសាលាក្ដី ICTY ថា៖ "ការបំពានណាមួយទៅលើដីកាគឺមានលក្ខណៈជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលតុលាការសម្រាប់គោលបំណងនៃការផ្ដន្ទាទោសចំពោះការប្រមាថ។ ពុំមានការតម្រូវឲ្យមាននូវភ័ស្ដុតាងបន្ថែមអំពីព្យសនកម្មទៅលើកិច្ចការរដ្ឋបាលតុលាការរបស់តុលាការអន្តរជាតិឡើយ"[100]។ យើងអាចនិយាយម្យ៉ាងទៀតថា តាមហេតុផលនេះ ការមិនព្រមគោរពតាមដីកានេះឯងរបស់ចៅក្រមគឺជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតែម្ដង។ មិនថាមានទស្សនៈយ៉ាងណាលើអង្គហេតុនៃសំណុំរឿង ០០២ នេះ ចំណុចមួយដែលច្បាស់មិនអាចប្រកែកបាននោះគឺថា៖ សាក្សីជាមន្ត្រីរដ្ឋាភិបាលទាំង ៦ រូបនេះ *មិនព្រមគោរពតាម*ដីការបស់សហចៅក្រមស៊ើបអង្កេត[101]។

---

[100] *សូមមើល* ឯកសារលេខ **E-176/2/1/4** "សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ERN 00847628-00847662 កថាខណ្ឌ ៣៥ លេខយោងជើងទំព័រ ៩៥។

[101] តាមពាក្យសំដីរបស់ចៅក្រម Lemonde ៖ "ដូច្នេះយើងមើលឃើញយ៉ាងច្បាស់ថា បុគ្គលទាំងនោះបានបដិសេធក្នុងការមកផ្ដល់សក្ខីកម្ម។ យើងហាក់ដូចជាមានការសោកស្ដាយចំពោះរឿងនេះ ដោយហេតុថា សមាជិកនៃគណបក្សនយោបាយកាន់បណ្ដឹងសាទុក្ខភ្លាមប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

50. *ហេតុដូច្នេះ* តាមហេតុផលដដែលរបស់អង្គជំនុំជម្រះតុលាការកំពូល សាក្សីទាំងនេះបានជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការនេះ[102]។ មកទល់ពេលបច្ចុប្បន្ន *គ្មានការិយាល័យ ឬ អង្គជំនុំជម្រះណាមួយ* នៅ អ.វ.ត.ក ក្លាហានប៊ានចាត់វិធានការឱ្យមានប្រសិទ្ធភាពដើម្បីតបតទៅនឹងឥរិយាបទបែបនេះទេ[103]។ ដោយពុំគិតអំពីករណីដែលថា សាក្សីទាំងនេះមានព័ត៌មានដោះបន្ទុក

---

អំណាច ឬ សមាជិកនានានៃរដ្ឋាភិបាល ដែលជាអ្នកដែលបានផ្តួចផ្តើមបង្កើតឱ្យមាន អ.វ.ត.ក បែរទៅជាបដិសេធមិនព្រមធ្វើការសហការជាមួយ អ.វ.ត.ក និងបដិសេធក្នុងការជួយសម្រួលដល់ដំណើរប្រព្រឹត្តទៅនៃតុលាការនេះទៅវិញ។ ទង្វើនេះជាការប្រព្រឹត្តដោយរំលោភលើមាត្រា ២៥ នៃកិច្ចព្រមព្រៀងចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣"។ *សូមមើល* ឯកសារលេខ **D-301** "ដីកាសម្រេច" ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ERN 00455446-00455449 ទំព័រ ៣។

[102] មិនថាសាក្សីទាំងនេះពុំព្រមចូលខ្លួនតាមការស្ម័គ្រចិត្តរបស់ខ្លួន ឬ ដោយសារសាក្សីទាំងនេះបានទទួលរងសម្ពាធមិនឱ្យចូលខ្លួន គឺវាពុំពាក់ព័ន្ធនឹងបញ្ហាចោទនៅចំពោះមុខអង្គជំនុំជម្រះនោះទេ ដោយពិចារណាលើមុខតំណែង(យ៉ាង)ជាន់ខ្ពស់របស់សាក្សីនេះម្នាក់ៗ នៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជា (*ឧ.* ជា ស៊ីម និង ហេង សំរិន ត្រូវបានគេទទួលស្គាល់ជាទូទៅថាមានតំណែងលេខ ២ និងលេខ ៣ នៅក្នុងរបបបច្ចុប្បន្ននេះ)។ សកម្មភាពរបស់មន្ត្រីទាំងនេះត្រូវបានចាត់ទុកថាជាសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ឬ តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើសាក្សីត្រូវបាន*ដាក់សម្ពាធ*យ៉ាងមានប្រសិទ្ធភាពមិនឱ្យមកបង្ហាញខ្លួន វាបង្ហាញច្បាស់ថា ការបង្គាប់បញ្ជាបែបនេះអាចកើតចេញពីអំណាចកណ្តាលនៃរាជរដ្ឋាភិបាលកម្ពុជាជាក់ជាមិនខាន។ ដូច្នេះ មិនថាករណីណាមួយនោះទេ ស្ថាប័នដែលធ្វើការជ្រៀតជ្រែក និងជាកម្មវត្ថុនៃការស៊ើបអង្កេតតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងគឺរាជរដ្ឋាភិបាលកម្ពុជា។

[103] ក្រុមមេធាវីការពារក្តីគឺបានដឹងយ៉ាងច្បាស់ថា ការមិនចូលខ្លួនរបស់សាក្សីទាំងនេះបង្កើតជាផ្នែកមួយនៃសំណើសុំដំបូងរបស់យើងខ្ញុំតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារលេខ **D-254** "សំណើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ERN 00410838-00410848)។ ដោយហេតុថាអង្គបុរេជំនុំជម្រះមិនអាចចេញសេចក្តីសម្រេចមួយបានលើបញ្ហានេះពីព្រោះតែអង្គជំនុំជម្រះនេះមានមតិខ្វែងយោបល់គ្នា (*សូមមើល* សាលដីកាលើកទីពីរ) បញ្ហានេះមិនទាន់ត្រូវបានសម្រេចដាច់ណាត់នៅឡើយ។ ហេតុដូច្នេះ បញ្ហានេះត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃសំណើសុំនេះ (កថាខណ្ឌ ២ និងកថាខណ្ឌ ២៤)។ លើសពីនេះ ដីកាសម្រេចបានតម្កល់សារជាថ្មីម្តងទៀតលើការផ្អាកដោយលើកឡើងថា ចៅក្រម យូ ប៊ុនឡេង បានបំពេញភារងារតុលាការរបស់ខ្លួនទៅតាមបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលកម្ពុជា។ ករណីនេះ វាបានបង្ហាញជាពន្លឺថ្មីមួយលើកិច្ចរបស់ចៅក្រមរូបនេះជុំវិញករណីសាក្សីរណុកក្នុងទាំង ៦ រូប នៅពេលដែលលោកចៅក្រមបានសម្របកិច្ចរបស់ខ្លួនឱ្យស្របយ៉ាងល្អឥតខ្ចោះទៅតាមជំហររបស់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហានេះ។ ក្នុងន័យម្យ៉ាងទៀត យើងមិនមែនប្តឹងលើបញ្ហានេះសារជាថ្មីម្តងទៀតនោះទេ។ យើងគ្រាន់តែគូសបញ្ជាក់ថា ដីកាសម្រេចបានបង្ហាញចេញនូវព័ត៌មានពាក់ព័ន្ធថ្មីៗស្រឡាងដែលត្រូវយកមកពិចារណាលើពេលឆ្លើយតបទៅនឹងករណីធំៗជាងនេះ ពោលគឺ ថាតើយើងមានហេតុផលគួរឱ្យជឿជាក់ថាបុគ្គលណាម្នាក់បានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការដែរឬទេ។ អ្វីដែលសំខាន់ជាងនេះគឺ ក្នុងពេលថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចរបស់ខ្លួនដោយបានបញ្ជាក់ច្បាស់ថា ការមិនព្រមគោរពតាមដីកាតុលាការគឺជាការបណ្តឹងសាទុក្ខភ្ជាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

និងថាចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា វាពុំមានភាពយុត្តិធម៌ក្នុងការដកហូតឱកាសរបស់ក្រុមមេធាវីការពារក្តីមិនឲ្យស្តាប់សក្សីទាំងនេះ នៅតែមានផលប្រយោជន៍តាមផ្លូវច្បាប់សម្រាប់ នួន ជា ក្នុងការទទួលការជំនុំជម្រះដោយស្ថាប័នមួយដែលប្រកាន់ភ្ជាប់នូវសុចរិតភាពរបស់ខ្លួន និងពុំទទួលយកការមិនចូលខ្លួនរបស់សាក្សីបែបនេះបានទេ ដែលសាក្សីទាំងនេះត្រូវបានកោះហៅទៅតាមសំណើ*របស់ក្រុមមេធាវីការពារក្តី* តាំងពីដំបូងមក[104]។ ការព្រួយបារម្ភទាំងនេះគឺវាពាក់ព័ន្ធនឹងសុចរិតភាពនៃស្ថាប័នមួយដែលធ្វើការជំនុំជម្រះ នួន ជា ហើយ នួន ជា ក៏ដូចជាភាគីផ្សេងទៀតទាំងអស់នៅក្នុងកិច្ចដំណើរការនីតិវិធី មានសិទ្ធិទទួលបាននូវការការពារចំពោះសុចរិតភាពនេះឲ្យបានពិតប្រាកដដែរពីសំណាក់អង្គភាពតុលាការដែលពាក់ព័ន្ធ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនធ្វើការស៊ើបអង្កេត ភាពមន្ទិលសង្ស័យដ៏ច្បាស់

---

ជ្រៀតជ្រែកមួយ*តែម្តង*។ អង្គជំនុំជម្រះសាលាដំបូងគួរកត់សម្គាល់លើការវិវឌ្ឍផ្នែកគតិយុត្តនេះ និងបំពេញកិច្ចទៅតាមករណីនេះ។

[104] បើទោះជាករណីខាងក្រោមនេះមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងផលប្រយោជន៍របស់ នួន ជា យើងត្រូវចងចាំថា ការមិនចូលខ្លួនរបស់មន្ត្រីរដ្ឋាភិបាលនៅពេលកោះហៅ និងការមិនទទួលខុសត្រូវរបស់មន្ត្រីទាំងនេះនៅចំពោះមុខតុលាការ គឺជាការព្រួយបារម្ភដែលកំពុងតែនៅបន្តកើតឡើងក្នុងប្រទេសកម្ពុជានាពេលសព្វថ្ងៃ។ *សូមមើល* ក្នុងចំណោមឯកសារបោះពុម្ពផ្សាយជាច្រើនក្នុងនោះរួមមាន៖ "ប្រាប់ពួកគេទៅថាខ្ញុំចង់សម្លាប់ពួកគេ ពីរទសវត្សរ៍នៃនិទណ្ឌភាពនៅក្នុងរបប ហ៊ុន សែន ក្នុងប្រទេសកម្ពុជា" អង្គការឃ្លាំមើលសិទ្ធិមនុស្ស៖ "មន្ត្រីជាន់ខ្ពស់មិនត្រូវបានចាប់ឲ្យទទួលខុសត្រូវនៅក្រោមច្បាប់" (ទំព័រ ៥)។ "នៅដើមឆ្នាំ ១៩៩៥ អ្នកតំណាងពិសេសនៃ អ.ស.ប Michael Kirby បានផ្តល់អនុសាសន៍ថា គណកម្មាធិការអន្តរនាយកដ្ឋានជាន់ខ្ពស់ត្រូវបានបង្កើតឡើងដើម្បីស៊ើបអង្កេត និងធ្វើរបាយការណ៍ស្តីពីបណ្តឹងតុលាការពាក់ព័ន្ធនឹងការបដិសេធ និងការខកខានរបស់មន្ត្រីយោធា នគរបាល ឬ មន្ត្រីផ្សេងទៀត មិនព្រមអនុវត្តដីកាតុលាការបង្គាប់លើមន្ត្រីយោធា នគរបាល ឬ ឥស្សរជននយោបាយ ឬ សមាជិកនៃគ្រួសាររបស់ពួកគេ។ ពីរឆ្នាំក្រោយមក គ្មានការវិវឌ្ឍរីកចម្រើនណាមួយបានបង្ហាញឲ្យឃើញជាភស្តុតាងជាក់ស្តែងឡើយ ហើយអ្នកតំណាងដែលមកបន្តបំពេញភារកិច្ច Thomas Hammarberg បានអំពាវនាវឲ្យចាត់វិធានការម៉ឺងម៉ាត់ដោះស្រាយលើបញ្ហានិទណ្ឌភាព"។ អ្នកតំណាងដែលមកបន្តភារកិច្ចពី Thomas Hammarberg [...] បានអំពាវនាវដូច្នេះជាច្រើនដងសារជាថ្មីទៀត។ អ្នកតំណាងទាំងនេះមិនត្រឹមតែពុំទទួលជោគជ័យលើការអំពាវនាវទាំងនេះនោះទេ ហ៊ុន សែន បានឆ្លើយតបទៅវិញជាញឹកញាប់ចំពោះការចោទប្រកាន់របស់អ្នកតំណាងទាំងនេះដោយធ្វើការវាយប្រហារទាំងខឹងសម្បារលើអត្តចរិតរបស់អ្នកតំណាង (ទំព័រ ៦៤)(http://www.hrw.org/sites/default/files/reports/cambodia1112webwcover_1.pdf)។ ការលើកលែងការចោទប្រកាន់ថ្មីៗលើករណីអភិបាលក្រុងបាវិត ឈូក បណ្ឌិត ("តុលាការបានទម្លាក់ចោលបទចោទបាញ់ប្រហារ ៣ បទចោទលើអភិបាលក្រុងបាវិត" កាសែតឌឹឃែមបូឌៀដេលី ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២ សរសេរឡើងដោយ ឃួន ណារីម និង Dene-Hern Chen) គឺជាហេតុការណ៍ថ្មីបំផុតតែមួយគត់នៅក្នុងបញ្ជីបិទបាំងបុគ្គលមានអំណាច។ កេរ្តិ៍តំណែលមួយផ្នែកដែល អ.វ.ត.ក បានបន្សល់ទុក យ៉ាងហោចណាស់ គួរតែជា*ការញុះញង់*តបតទៅនឹងបាតុភាពដ៏ជូរចត់នេះ។

អំពីសុចរិតភាពនៃ ក.ស.ច.ស និង អ.វ.ត.ក ជារួមមក បង្កើតជាការបំពានលើធន្ទានុសិទ្ធិ។

*លទ្ធភាពនៃការស្តាប់ចម្លើយសាក្សីទាំងនេះនៅក្នុងអំឡុងពេលជំនុំជម្រះ គឺមិនមានភាពពាក់ព័ន្ធទេ*

51. សេចក្តីសម្រេចនេះសរសេរយោងដោយសង្ខេបអំពីសាក្សីទាំង ៦ រូប ដែលជាមន្ត្រីជាន់ខ្ពស់។ សេចក្តីសម្រេចបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងធ្លាប់បាន "គូសបញ្ជាក់អំពីតម្រូវការដើម្បីថ្លឹងថ្លែងរវាងសិទ្ធិរបស់ភាគីទាំងអស់នៅក្នុងការស្តាប់សក្ខីកម្មរបស់បុគ្គលនានាជាមួយនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស"[105]។ ជំហរនៃអង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចនេះបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានវាយតម្លៃលើគោលបំណងនៃការមិនចូលខ្លួនរបស់សាក្សីដូចបានបង្ហាញនៅក្នុងសំណើសុំ[106]។ តម្លៃភស្តុតាងនៃសាក្សីរដ្ឋាភិបាលទាំងនេះ និងសំខាន់ជាងនេះ ភស្តុតាងដោះបន្ទុកដែលសាក្សីទាំងនេះអាចផ្តល់បាន[107] រួមទាំង សិទ្ធិជាមូលដ្ឋានក្នុងការតវ៉ាលើសក្ខីកម្មណាដែលឆ្លើយដាក់បន្ទុក[108] គឺជាបញ្ហាសំខាន់យ៉ាងពិតប្រាកដ ហើយក្រុមមេធាវីការពារក្តីនឹងបន្តគូសបញ្ជាក់ចំណុច

---

[105] គេអាចសង្ឃឹមថា មកត្រឹមពេលនេះ ការិយាល័យតុលាការ និងអង្គជំនុំជម្រះទាំងអស់នៅ អ.វ.ត.ក នឹងយល់ថា សិទ្ធិទទួលបានការជំនុំជម្រះឱ្យបានឆាប់រហ័សនោះមិនអាចយកមកអនុវត្ត*ប្រឆាំង*នឹងជនជាប់ចោទដើម្បីច្រានចោលសំណើសុំរបស់ក្រុមមេធាវីការពារក្តីនោះទេ។ បញ្ហានេះត្រូវបានលើកឡើងលម្អិត និងជាច្រើនលើកច្រើនសារនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។ *សូមមើល* ឯកសារលេខ D-314/2/6 "សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្តីបង្គាប់ឱ្យដាក់ការឆ្លើយតប" ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០ ERN 00492902-00492904 កថាខណ្ឌ ៧០ ("សហមេធាវីការពារក្តីសម្រាប់ជនជាប់ចោទទាំងពីរពិតជាត្រឹមត្រូវនៅពេលពួកគេអះអាងថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយពុំមានការពន្យារពេលយូរនោះគឺជាសិទ្ធិរបស់ជនជាប់ចោទ មិនមែនរបស់សហចៅក្រមស៊ើបអង្កេតនោះទេ"។ បញ្ហានេះទំនងជាអាចមិនបានពិចារណាឱ្យបានហ្មត់ចត់ ប៉ុន្តែ ការពិតនោះថា តុលាការក្នុងស្រុកក្នុងប្រទេសកម្ពុជាមានចិត្តចង់សិក្សាពីច្បាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក ហើយនឹងមានបំណងចង់ខិបក្រសោបការប្រើប្រាស់គោលការណ៍អន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌នេះដើម្បីច្រានចោលសំណើសុំរបស់ក្រុមមេធាវីការពារក្តីដែលត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ។ ប្រសិនបើសម្រាប់គោលបំណងនៃកេរ្តិ៍តំណែលមែននោះ វានឹងជាការល្អប្រសិនបើ អ.វ.ត.ក យ៉ាងហោចណាស់យល់ទស្សនទាននេះឱ្យបានត្រឹមត្រូវ)។

[106] *សូមមើល* សំណើសុំ កថាខណ្ឌ ២ និង ២៣។

[107] ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា សាក្សីទាំងអស់ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងភស្តុតាងដោះបន្ទុក។ ចំពោះ ហេង សំរិន ករណីនេះនឹងត្រូវបានផ្តល់មូលដ្ឋានបន្ថែមនៅក្នុងញត្តិមួយដែលនឹងត្រូវដាក់នាពេលខាងមុខ។

[108] មិនមែនថាគ្រប់គ្នាបានដឹងថា សេចក្តីប្រកាសរបស់ ជា ស៊ីម ហេង សំរិន និង ហោ ណាំហុង ពិតជាបានដាក់បញ្ចូលនៅក្នុងសំណុំរឿងនោះទេ ហើយត្រូវបាន ក.ស.ព យកមកធ្វើជាភស្តុតាងថែមទៀត។ អ្វីដែលច្បាស់នោះគឺ បុគ្គលទាំងនេះត្រូវមកផ្តល់បណ្តឹងសាទុក្ខភ្ជាប់ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

សំខាន់នេះនៅក្នុងឯកសារដែលបានដាក់ និងនៅក្នុងតុលាការ។ ទោះបីជាយ៉ាងនេះក្តី ខ្លឹមសារសំខាន់នៃសំណើសុំអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង មានភាពខុសគ្នាទាំងស្រុងតែម្តងពោលគឺថា *វិធាននេះមានគោលបំណងរកឱ្យឃើញការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ* [109]។ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង រួមជាមួយនឹងសេចក្តីពន្យល់របស់អង្គជំនុំជម្រះតុលាការកំពូលអំពីលក្ខខណ្ឌនីតិវិធីនៃវិធាននេះ[110] អង្គជំនុំជម្រះសាលាដំបូងមានភារកិច្ចវាយតម្លៃថាតើមាន "ហេតុផលគួរឱ្យជឿជាក់" ថាបុគ្គលណាមួយបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការដែរឬអត់។ *តម្លៃនៃភស្តុតាង* របស់សាក្សី ឬក៏ថាតើសាក្សីទំនងជាអាចត្រូវបានកោះហៅនៅក្នុងដំណាក់កាលក្រោយដែរឬទេ ពុំមានការពាក់ព័ន្ធលើការវាយតម្លៃនេះទេ[111]។ នៅពេលខកខានមិនបានវាយតម្លៃដូច្នេះ វាបានន័យថាអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តវិធាន ៣៥

---

សក្ខីកម្មដើម្បីតទល់ និង/ឬ ផ្ទៀងផ្ទាត់សេចក្តីប្រកាសរបស់ពួកគេ។ (ក្រុមមេធាវីការពារក្តីពុំមែនមិនដឹងនោះទេ ពោលគឺ ខ្លួនទាយថា លទ្ធផលនៅពេលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីនេះគឺសាក្សីទាំងនេះនឹងមិនត្រូវបានកោះហៅនោះឡើយ ហើយកំណត់ហេតុជាលាយលក្ខណ៍នៃសេចក្តីប្រកាសរបស់ពួកគេនឹងមិនត្រូវបានប្រើប្រាស់ជាភស្តុតាងប្រឆាំងនឹងកូនក្តីរបស់យើងនោះទេ។ មនុស្សមួយចំនួនអាចហៅករណីនេះថាជាស៊ីលដោះស្រាយមួយ។ ក្រុមមេធាវីការពារក្តីហៅករណីនេះថាជាការអនុវត្តតាមស្ថានភាពជាក់ស្តែងនៃនយោបាយកម្ពុជា និងការរួមគ្នាមិនទទួលខុសត្រូវរបស់ឥស្សរជនមានអំណាច និងការបំផ្លិចបំផ្លាញលើនីតិរដ្ឋដែលកំពុងវិវឌ្ឍរីកចម្រើន)។

[109] និយាយតាមបែបសាមញ្ញទៅ៖ ប្រសិនបើសាក្សីដែលត្រូវបានកោះហៅត្រូវបានរារាំងមិនឱ្យមកផ្តល់សក្ខីកម្មដោយតតីយជនណាម្នាក់នោះ វាពុំពាក់ព័ន្ធទាំងស្រុងនៅពេលវាយតម្លៃថាតើ "មានហេតុផលគួរឱ្យជឿជាក់" ថា បុគ្គលណាម្នាក់បានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលដែរឬទេ ហើយថាតើតម្លៃនៃភស្តុតាងរបស់សាក្សីនោះមានតម្លៃយ៉ាងដូចម្តេច និងថាតើក្រុមមេធាវីការពារក្តីអាច ឬ ពុំអាចទទួលបាន "ការប៉ះប៉ូវ" តាមរយៈមធ្យោបាយផ្សេងដែរឬទេ។ ការជ្រៀតជ្រែកគឺជាការជ្រៀតជ្រែក។ ជាការពិត ការឆ្លើយតបរបស់តុលាការនេះអាចអាស្រ័យលើតម្លៃនៃភស្តុតាង ពោលគឺ វាត្រឹមត្រូវក្នុងការដាក់ទណ្ឌកម្មលើបុគ្គលណាម្នាក់ដែលជ្រៀតជ្រែកចូលក្នុងសាក្ខីកម្មរបស់សាក្សីតូចតាចនៅក្នុងទណ្ឌកម្មមួយស្រាលជាការជ្រៀតជ្រែកលើសាក្សីសំខាន់មួយ។ ប៉ុន្តែ បញ្ហាចោទនេះគឺនឹងបង្ហាញឱ្យឃើញជារូបភាពនៅក្រោយពេលវាយតម្លៃលើ "ហេតុផលដែលអាចឱ្យជឿជាក់បាន"។

[110] *សូមមើល* ឯកសារលេខ **E-176/2/1/4** "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ERN 00847628-00847662 កថាខណ្ឌ ៣៩-៤២។

[111] ជាការពិតទៅ បញ្ហាទាំងនេះ*អាច*មានឥទ្ធិពលលើការដាក់ទណ្ឌកម្ម ឬ ការឆ្លើយតបដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកប្រើប្រាស់។ នេះជាបញ្ហាចោទដែលបង្ហាញចេញជារូបភាពនៅក្នុងដំណាក់កាលក្រោយប៉ុណ្ណោះ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថាខ្លួនមានហេតុផលគួរឱ្យជឿជាក់ថាការជ្រៀតជ្រែកមួយបានកើតឡើងមែន។

នៃវិធានផ្ទៃក្នុង ដោយមិនត្រឹមត្រូវ ដូច្នេះនេះគឺកំហុសអង្គច្បាប់មួយ[112]។ ហេតុដូច្នេះ ត្រូវបដិសេធសេចក្តីសម្រេចនេះចោល។

## គ. លិខិតព្រមានដែលត្រូវបានចេញ គ្មានមូលដ្ឋាន និងបង្កឲ្យមានព្យសនកម្ម

52. ពាក់ព័ន្ធនឹងលិខិតព្រមានមួយច្បាប់ដែលបង្កើតជាផ្នែកសំខាន់មួយនៃសេចក្តីសម្រេចនោះ អង្គជំនុំជម្រះសាលាដំបូងបានចោទប្រកាន់ក្រុមមេធាវីការពារក្តីថាបានដាក់ឯកសារច្រំដែលម្តងហើយម្តងទៀត។ បញ្ហានៃការដាក់ឯកសារច្រំដែលម្តងហើយម្តងទៀតនេះត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥-១៦ ខាងលើ។ កថាខណ្ឌទាំងនេះបង្ហាញច្បាស់ថា នៅក្នុងលិខិតព្រមាននេះពុំមានភស្តុតាងឲ្យជឿនោះទេសូម្បីតែបន្តិចក៏ដោយ។

53. ចំណុចដែលបង្កជាបញ្ហាខ្លាំងជាងនេះគឺការចោទប្រកាន់របស់អង្គជំនុំជម្រះសាលាដំបូងថា ក្រុមមេធាវីការពារក្តីកំពុងដាក់ឯកសារដោយមានការរើសអើង។ សេចក្តីសម្រេចនេះលើកឡើងថា ក្រុមមេធាវីការពារក្តីធ្វើការចោទប្រកាន់អង្គចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង "ដោយផ្អែកលើសញ្ជាតិតែប៉ុណ្ណោះ" ហើយបានព្រមានថា ការចោទប្រកាន់ចំពោះភាពពុំសមរម្យ "ដោយឈរលើមូលដ្ឋាននៃការរើសអើងដូច្នេះ" អាចនាំឲ្យអង្គជំនុំជម្រះមានអំណាចដាក់ទណ្ឌកម្មអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង។ ការចោទប្រកាន់ដោយអង្គជំនុំជម្រះបែបនេះមាន លក្ខណៈធ្ងន់ធ្ងរ គឺជាការបង្ខូចឈ្មោះ ហើយបើនិយាយដោយត្រង់ទៅគឺជាការមាក់ងាយតែម្តង។ អំពើរើសអើងដោយផ្អែកលើសញ្ជាតិ គឺជាបញ្ហាធ្ងន់ធ្ងរមួយខ្លាំងណាស់ ហើយជាការពិតទៅ វាជាការអនុវត្តដ៏អាម៉ាស់មួយ។ ដោយសារហេតុផលនេះ ហើយទើបសន្ធិសញ្ញាអន្តរជាតិជាច្រើនបានហាមឃាត់អំពើរើសអើង ហើយអំពើនេះគឺជាបទល្មើសព្រហ្មទណ្ឌមួយនៅស្ទើរតែគ្រប់បណ្តាប្រទេសដែលមានអារ្យធម៌។ សម្រាប់ស្ថាប័នតុលាការមួយ ដូចជា អង្គជំនុំជម្រះសាលាដំបូងនេះ ការចេញលិខិតព្រមានមួយដើម្បីចោទប្រកាន់ក្រុមមេធាវីការពារក្តីថាអនុវត្តបែបនេះ គឺមិនអាចទទួលយកបាននោះទេ។

---

[112] ជាការពិតទៅ ជំហររបស់អង្គជំនុំជម្រះសាលាដំបូងផ្ទុយនឹងសិទ្ធិជាមូលដ្ឋានមួយក្នុងចំណោមសិទ្ធិជាមូលដ្ឋានភាគច្រើនដែលជនជាប់ចោទមាន គឺ សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាក្តីឯករាជ្យមួយ។ ប្រសិនបើមានភស្តុតាងបង្ហាញថា (ស្ថាប័នណាមួយ) នៅក្នុងសាលាក្តីមិនឯករាជ្យនោះ ការសងសំណង ឬ ការប៉ះប៉ូវពុំអាចធ្វើឡើងតាមរយៈការចាត់វិធានការតាមនីតិវិធីនោះទេនៅក្នុងដំណាក់កាលជំនុំជម្រះក្តី។

54. ដើម្បីឲ្យកាន់តែច្បាស់តែម្តងនោះ ក្រុមមេធាវីការពារក្តីពុំបាន និងក៏នឹងមិនធ្វើការចោទប្រកាន់បុគ្គលណាមួយ "ដោយឈរមូលដ្ឋានលើសញ្ជាតិរបស់បុគ្គលទាំងនោះឡើយ"។ ការលើកឡើងដូច្នេះនោះពុំមានលក្ខណៈសមហេតុផលឡើយ។ វាក៏កាន់តែគួរឲ្យចង់សើចទៅទៀតបើធ្វើការពន្យល់លើចំណុចនេះ ក៏ប៉ុន្តែដំហាររបស់អង្គជំនុំជម្រះសាលាដំបូងលើចំណុចនេះហើយដែលបង្ខំឲ្យយើងខ្ញុំធ្វើការពន្យល់លើបញ្ហានេះ។ ដើម្បីជាការកត់ចូលកំណត់ហេតុ អ្នកវិជ្ជាជីវច្បាប់កម្ពុជាមានសមត្ថភាពវិជ្ជាជីវច្បាប់ ដូចអ្នកច្បាប់ផ្សេងទៀតមកពីតាមបណ្តាប្រទេសនានាដែរ។ អ្នកវិជ្ជាជីវៈច្បាប់កម្ពុជាមានក្រមសីលធម៌ និងមានសេចក្តីស្មោះត្រង់ ដូចអ្នកវិជ្ជាជីវៈច្បាប់ផ្សេងទៀតមកពីតាមបណ្តាប្រទេសនានាផងដែរ។ បញ្ហាសញ្ជាតិរបស់អ្នកច្បាប់កម្ពុជា ពុំមានការពាក់ព័ន្ធនឹងភាពស្មោះត្រង់ ឬវិជ្ជាជីវៈ*អ្វីទាល់តែសោះ* ។ ជាការពិត យើងជឿជាក់ថា អ្នកច្បាប់កម្ពុជាជាច្រើននាក់បានព្យាយាមបោះជំហានទៅរកការមានក្រមសីលធម៌ និងមានវិជ្ជាជីវៈ។

55. ជាការពិត ការព្រួយបារម្ភរបស់ក្រុមមេធាវីការពារក្តីគឺខុសពីនេះស្រឡះ។ យើងខ្ញុំធ្លាប់ កំពុង និងនៅតែប្រកាន់ជំហរថា *អ្នកវិជ្ជាជីវៈច្បាប់ដែលកំពុងធ្វើការងារនៅក្នុងប្រព័ន្ធតុលាការកម្ពុជា* និងជាពិសេស អ្នកដែលរស់នៅ និងធ្វើការនៅក្នុងប្រទេសកម្ពុជា និងអ្នកដែលត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា (ទោះដោយផ្ទាល់ ឬ ដោយប្រយោលក្តី) មិនអាចគេចផុតពីអំណាច និងការឥទ្ធិពលរបស់រាជរដ្ឋាភិបាលឡើយ។ ពួកគេជំពាក់គុណរាជរដ្ឋាភិបាលកម្ពុជា ហើយពួកគេមិនមានសេរីភាពតវ៉ាលើបញ្ហាទាំងឡាយដែលរដ្ឋាភិបាលមានផលប្រយោជន៍នៅក្នុងហ្នឹងនោះទេ។ ពួកគេនឹងប្រឈមនឹងផលវិបាកជាក់ជាមិនខាន ប្រសិនបើហ៊ានតវ៉ានោះ។ ក្នុងករណីមិនធ្ងន់ធ្ងរ វានឹងប៉ះពាល់ដល់ការងាររបស់ពួកគេ ហើយនឹងអាចប៉ះពាល់ដល់អាជីព និងជីវិតរបស់សមាជិកគ្រួសាររបស់ពួកគេទៀត។ ចំណុចនេះមិនមានអ្វីជាការភ្ញាក់ផ្អើលសម្រាប់មនុស្សគ្រប់គ្នានោះទេ ពោលគឺប្រទេសកម្ពុជាគឺជាប្រទេសផ្តាច់ការ។ ប្រទេសនេះ*គ្មាន* នីតិរដ្ឋដ៏មានប្រសិទ្ធភាពអ្វីឡើយ។ ចៅក្រម និងព្រះរាជអាជ្ញាគ្មានជម្រើសអ្វីក្រៅពីគោរពតាមរដ្ឋាភិបាលទេ។ ករណីនេះវាកើតមានចំពោះអ្នកវិជ្ជាជីវៈច្បាប់ដែលធ្វើការងារនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក ហើយវាក៏ដូចគ្នាទៅនឹងអ្នកវិជ្ជាជីវៈច្បាប់ដែលធ្វើការងារនៅ អ.វ.ត.ក ដែរ។

56. ជាការពិត នៅគ្រប់ និងរាល់ពេលដែលយើងចោទប្រកាន់ថា បុគ្គលមួយចំនួនងាយនឹងរងសម្ពាធរបស់រដ្ឋាភិបាល ក្រុមមេធាវីការពារក្តីហៅបុគ្គលទាំងនោះថា "ជាអ្នកវិជ្ជាជីវៈតុលាការដែលកំពុងបម្រើការងារនៅក្នុងប្រព័ន្ធតុលាការកម្ពុជា និងជាពិសេស អ្នកដែលរស់នៅ និងធ្វើការនៅ

ក្នុងប្រទេសកម្ពុជា និងអ្នកដែលត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា (ទោះដោយផ្ទាល់ ឬ ដោយប្រយោលក្តី) ដោយមិនគិតអំពីសញ្ជាតិឡើយ"។ ទោះបីជាយ៉ាងនេះក្តី បុគ្គល *ទាំងឡាយណា* ដែលត្រូវនឹងការពិពណ៌នានេះគឺសំដៅលើអ្នកវិជ្ជាជីវៈច្បាប់*កម្ពុជា* មិនមែនសំដៅលើអ្នកវិជ្ជាជីវៈច្បាប់ដែលមានសញ្ជាតិផ្សេងនោះទេ។ ដូច្នេះ ក្រុមមេធាវីការពារក្តីជ្រើសរើសប្រើប្រាស់ខ្លី និងងាយស្រួលមួយ គឺពាក្យ "កម្ពុជា" ដើម្បីសំដៅលើអ្នកវិជ្ជាជីវៈច្បាប់ដែលជំពាក់គុណ និងងាយនឹងគោរពតាមរដ្ឋាភិបាល[113]។ ក្រុមមេធាវីគ្មានចេតនាណាមួយធ្វើការរើសអើងដោយសារមូលហេតុសញ្ជាតិនោះទេ ហើយ តាមពិតទៅ ករណីនេះក៏មិនអាចធ្វើការសន្និដ្ឋានដូច្នេះបានឡើយ។ គេអាចមិនយល់ស្រប ឬមិនជឿជាក់ទៅតាមការលើកឡើងរបស់យើងខ្ញុំអំពីវិសាលភាពនៃការជ្រៀតជ្រែករបស់រដ្ឋាភិបាលចូលក្នុងកិច្ចការរបស់ អ.វ.ត.ក ឬអំពីករណីដែលអ្នកវិជ្ជាជីវៈច្បាប់កម្ពុជាគោរពទៅតាមរាជរដ្ឋាភិបាល ប៉ុន្តែ ការលើកឡើងថា យើងខ្ញុំបានរើសអើងដោយឈរលើមូលដ្ឋានសញ្ជាតិនេះដូច្នេះ គឺវាពុំទំនងសោះ[114]។

57. យើងខ្ញុំគួរគួសបញ្ជាក់បន្ថែមទៀតថា ក្រុមមេធាវីការពារក្តីពុំមែនចេះតែធ្វើការចោទប្រកាន់អំពីកង្វះឯករាជ្យភាពនៃចៅក្រម និងព្រះរាជអាជ្ញាកម្ពុជានោះទេ[115]។ ប្រសិនបើអានឯកសារទាំងឡាយដែលយើងខ្ញុំបានដាក់នោះ នោះធ្វើឱ្យដឹងថា យើងបានផ្អែកការចោទប្រកាន់របស់យើងខ្ញុំលើរបាយការណ៍លម្អិត និងពិស្តារមកពីបណ្តាអង្គការមិនមែនរដ្ឋាភិបាលល្បីៗ របាយការណ៍ អ.ស.ប និងរបាយការណ៍របស់អ្នករាយការណ៍ពិសេសឯករាជ្យជាច្រើននាក់ផ្សេងៗគ្នា ដែលរបាយការណ៍ទាំងអស់នេះបញ្ជាក់ថា ប្រព័ន្ធតុលាការកម្ពុជានៅក្រោមរបប ហ៊ុន សែន មិនដែលធ្លាប់ ហើយមិនបានដំណើរការដោយមិនរួចផុតពីឥទ្ធិពលនៃរាជរដ្ឋាភិបាលកម្ពុជានោះទេ ជាពិសេស នៅក្នុងរឿងក្តី

---

113 ដើម្បីឱ្យប្រាកដ៖ ពាក្យកាត់នេះត្រូវបានប្រើប្រាស់នៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ដែលបញ្ញត្តិបែងចែកយ៉ាងតឹងរ៉ឹងនៅ អ.វ.ត.ក រវាង "កម្ពុជា" និង "បរទេស"។ ជាការពិត "ការរើសអើងដោយសារមូលហេតុសញ្ជាតិ" នេះ គឺជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ចំបងនានានៅ អ.វ.ត.ក។

114 វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងទំនងជាមានបំណងបំបាក់ទឹកចិត្តក្រុមមេធាវីការពារក្តីកុំឱ្យដាក់ញត្តិណាផ្សេងទៀតពាក់ព័ន្ធនឹងការជ្រៀតជ្រែករបស់រដ្ឋាភិបាល។

115 ឬ "អ្នកវិជ្ជាជីវតុលាការកំពុងបម្រើការងារនៅក្នុងប្រព័ន្ធតុលាការកម្ពុជា និង ជាពិសេស អ្នកដែលរស់នៅ និងធ្វើការនៅក្នុងប្រទេសកម្ពុជា និងអ្នកដែលត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា (ទោះដោយផ្ទាល់ ឬ ដោយប្រយោលក្តី) ដោយមិនគិតអំពីសញ្ជាតិ"។ *សូមមើល* សំណើសុំ។

រសើបៗពាក់ព័ន្ធនឹងនយោបាយ[116]។ ការកាត់ទោស ម៉ម សូណង់ដូ ក្នុងពេលថ្មីៗនេះ ផ្តល់ជាឧទាហរណ៍ថ្មីបំផុតមួយអំពីការកាត់ទោសដោយសារបញ្ហានយោបាយ។ មកទល់ពេលនេះ អ.វ.ត.ក ខកខានមិនបានលើកកម្ពស់ទស្សនទាននៃតុលាការឯករាជ្យពិតប្រាកដមួយនៅក្នុងប្រទេសកម្ពុជាទេ។ សំណើសុំស៊ើបអង្កេតជាសាធារណតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឧទាហរណ៍ ដូចជា សំណើសុំរបស់ក្រុមមេធាវីការពារក្តី នឹងអាចជាកេរតំណែលដ៏សំខាន់នៃ អ.វ.ត.ក បើទោះបីជាវាមានការរារាំងពីរាជរដ្ឋាភិបាលកម្ពុជាក៏ដោយ យ៉ាងហោចណាស់ វានឹងបង្ហាញឱ្យប្រជាពលរដ្ឋកម្ពុជាមើលឃើញថា អ.វ.ត.ក បានពិចារណាលើទស្សនៈនៃតុលាការឯករាជ្យមួយបានយ៉ាងល្អិតល្អន់ ដោយពុំខ្លាចនឹងប្រឈមជាមួយនឹងអង្គនីតិប្រតិបត្តិ ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ។

58. ចំពោះការចោទប្រកាន់របស់អង្គជំនុំជម្រះសាលាដំបូងថា ការចោទប្រកាន់របស់យើងខ្ញុំពុំមានមូលដ្ឋានគាំទ្រដោយប្រតិចារឹករបស់តុលាការនោះ[117] ជាថ្មីម្តងទៀត យើងអាចត្រឹមតែសន្មតបានថា អង្គជំនុំជម្រះសាលាដំបូងពុំបានអានសេចក្តីសន្និដ្ឋានជាច្រើនរបស់យើងខ្ញុំស្តីអំពីការជ្រៀតជ្រែកផ្នែកនយោបាយឱ្យបានលម្អិតនោះទេ កុំថាឡើយបានពិនិត្យមើលទៅរបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ន អ.ស.ប ដែលត្រូវបានភ្ជាប់ជូននោះ។ ហេតុដូច្នេះ យើងខ្ញុំ

---

[116] ប្រសិនបើ ក.ស.ព យកចិត្តទុកដាក់ជំទាស់នឹងការពិតនេះ ក្រុមមេធាវីការពារក្តីសូមដាក់ភស្តុតាង។ យើងទាយស្មានថា នៅពេលធ្វើសំណើ យើងអាចដាក់របាយការណ៍ឯករាជ្យច្រើនជាង ៥០ ដែលបានរិះគន់យ៉ាងចាស់ដៃលើកង្វះឯករាជ្យភាពនៃប្រព័ន្ធតុលាការកម្ពុជា ជាពិសេស នៅក្នុងករណីរសើបផ្នែកនយោបាយ។ ដើម្បីជាការសន្សំសំចៃដល់តុលាការ យើងនឹងដកស្រង់ប្រភពមួយ (១) ពីកម្ពុជា៖ កង្វះឯករាជ្យនៅក្នុង “ប្រព័ន្ធតុលាការកម្ពុជា” នៅតែជាកត្តាសំខាន់មួយក្នុងចំណោមកត្តាសំខាន់ៗបំផុតជាច្រើនដែលបានរារាំងប្រទេសកម្ពុជាពីការបង្កើតសង្គមមួយដែលយុត្តិធម៌ និងត្រឹមត្រូវ ដោយផ្អែកលើនីតិរដ្ឋ។ របាយការណ៍ចុះខែកញ្ញា ឆ្នាំ ២០១០ ដោយអ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា Surya Subedi បានរកឃើញថា “អំពើពុករលួយទំនងជាកើតមាននៅពាសពេញតុលាការគ្រប់ជាន់ថ្នាក់” ចំណែកសេចក្តីសម្រេចចុះខែ តុលា ឆ្នាំ ២០១០ របស់សភាសហភាពអ៊ឺរ៉ុបបានពិណ៌នាប្រព័ន្ធតុលាការថា “បានធ្វើទៅតាមឥទ្ធិពលនយោបាយ”។ ការគ្រប់គ្រងផ្នែកនយោបាយ និងសេដ្ឋកិច្ចលើប្រព័ន្ធតុលាការបានបន្តដុតបញ្ឆេះនិទណ្ឌភាពចំពោះឧក្រិដ្ឋកម្មធំៗ និងបានបន្តរារាំងប្រជាជនកម្ពុជាមិនឱ្យទទួលបានសិទ្ធិទទួលបានដីធ្លី និងសិទ្ធិលំនៅដ្ឋានដោយយុត្តិធម៌ និងការទទួលស្គាល់ ព្រមទាំងការការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ (សេចក្តីប្រកាសព័ត៌មាន ចុះឆ្នាំ ២០១១ “ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា” ចេញដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា)។

[117] *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៦។

សូមលើកឡើងចំណុចនេះសារជាថ្មីឡើងវិញថា ចាប់តាំងពីពេលដែល អ.វ.ត.ក បានកកើតឡើង គ្មានចៅក្រម ឬ ព្រះរាជអាជ្ញា*ណាម្នាក់* ធ្លាប់បានចេញសេចក្តីសម្រេចប្រឆាំងនឹងជំហររបស់រាជរដ្ឋាភិបាលកម្ពុជានោះឡើយ *កុំថាឡើយតែមួយផងនោះ* [118]។ ការយល់ឃើញបែបនេះ *រួមទាំង* សម្រាប់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងផងដែរ ពោលគឺ ចៅក្រមទាំងនោះ ពុំ*ធ្លាប់* ចេញសេចក្តីសម្រេចផ្ទុយនឹងជំហររបស់រាជរដ្ឋាភិបាលកម្ពុជាឡើយ។ *ចំណុចនេះ* ហើយ ជាប្រតិចារឹកតុលាការដែលយើងខ្ញុំយកមកធ្វើជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ។

59. ជាការពិត គ្មាននរណាអាច (ហើយនឹងមិនអាច) ច្រានចោលលទ្ធភាពដែលថា ចៅក្រមអង្គជំនុំជម្រះសាលាដំបូងទាំងបីរូបនេះ អាចជា ក្នុងកាលៈទេសៈថៃជន្យ ចៅក្រមដែលបម្រើការងារនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដែលអាចដំណើរការ និងចេញសេចក្តីសម្រេចដោយពុំទទួលរងឥទ្ធិពលរបស់រាជរដ្ឋាភិបាលកម្ពុជាឡើយ ហើយគាត់អាច និងបន្តធ្វើជាបដិបក្ខនឹងរាជរដ្ឋាភិបាលដែរឬទេនៅក្នុងពេលអនាគត ប្រសិនបើផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើបែបនេះនោះ។ ករណីនេះអាចកើតមានដែរ។ ប៉ុន្តែ មកទល់សព្វថ្ងៃនេះ យើងមិនដែលឃើញសញ្ញាបញ្ជាក់*ណាមួយ* បង្ហាញអំពីឯករាជ្យភាពបែបនេះឡើយ។ មិនខុសពីទ្រឹស្តីវិទ្យាសាស្ត្រ ក្រុមមេធាវីការពារក្តីសូមបង្ហាញជំហរថា ចៅក្រម*ទាំងអស់* នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ធ្វើទៅតាមរាជរដ្ឋាភិបាលកម្ពុជា រួមទាំង ចៅក្រមអង្គជំនុំជម្រះសាលាដំបូងផងដែរ។ ជំហរនេះអាចបំភ្លៃការពិតបានយ៉ាងងាយ និងយ៉ាងច្បាស់

---

[118] ប្រហែលជាមានចំណុចមួយដែលគួរបញ្ជាក់បំភ្លឺ។ ជំហររបស់ក្រុមមេធាវីការពារក្តីគឺ និងមិនដែលធ្លាប់លើកឡើងថា រាជរដ្ឋាភិបាលគ្រប់គ្រង និងបង្គាប់លើគ្រប់ទិដ្ឋភាពការងាររបស់មន្ត្រីច្បាប់កម្ពុជានៅ អ.វ.ត.ក គ្រប់នាទីនោះទេ។ ក្រុមមេធាវីការពារក្តីក៏ពុំបានលើកឡើងថា រាជរដ្ឋាភិបាលនឹងប្រកាន់ជំហរលើគ្រប់ និងរាល់បញ្ហានយោបាយសំខាន់ៗនោះដែរដើម្បីដឹកនាំកាច់ចង្កូតបុគ្គលិកកម្ពុជា។ ជាការពិត កំណត់ហេតុបានបង្ហាញច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជាគឺពេញចិត្តនឹងទុកឲ្យបញ្ហា*មួយចំនួន*ដំណើរការទៅមុខដោយរលូនទៅ ហើយ/ឬទុកឲ្យអ្នកវិជ្ជាជីវច្បាប់កម្ពុជានៅ អ.វ.ត.ក ដោះស្រាយ។ ជាការពិត នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសំណើសុំ ក.ស.ព បានរៀបរាប់សេចក្តីសម្រេចមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហាដែលអាចត្រូវបានចាត់ទុកថា "វសើប" ដែលចៅក្រមកម្ពុជាឃុបឃិតជាមួយនឹងចៅក្រមអន្តរជាតិ។ ប៉ុន្តែ ករណីនេះពុំមានន័យថា ចៅក្រមកម្ពុជា *នៅចុងក្រោយ* មិនឆ្លើយតបទៅតាមរាជរដ្ឋាភិបាលកម្ពុជានោះទេ។ វាគ្រាន់តែមានន័យថា រាជរដ្ឋាភិបាលកម្ពុជា ដែលខ្លួនបានដឹងដោយខ្លួនឯងហើយនោះ ពុំមានផលប្រយោជន៍គ្រប់គ្រាន់លើលទ្ធផលនៃបញ្ហាទាំងនេះដែលខ្លួនបានកាច់ចង្កូតលើកិច្ចដំណើរការនីតិវិធី។ ក្នុងន័យម្យ៉ាងទៀត រាជរដ្ឋាភិបាលកម្ពុជានឹងតែងតែជាអ្នកសម្រេច*ចុងក្រោយ*លើជោគវាសនារបស់ អ.វ.ត.ក ទោះដោយផ្ទាល់ ឬ ដោយប្រយោលក្តី បើទោះជាខ្លួនបានជ្រើសរើសផ្តល់សេរីភាពមួយចំនួនដល់ចៅក្រម និងព្រះរាជអាជ្ញាជាតិលើបញ្ហាមួយចំនួនដែលខ្លួនបានជ្រើសរើសទុកហើយក៏ដោយក្តី។

តាមរយៈភស្តុតាងផ្ទុយណាមួយជាក់ជាមិនខាន។ សម្រាប់ប្រទេសកម្ពុជានេះ យើងសង្ឃឹមថា ជំហាររបស់ខ្ញុំមិនយូរមិនឆាប់នឹងត្រូវបានគេបំភ្លៃដូចគ្នា។ រហូតមកដល់ពេលនោះ យើងនៅតែរក្សាជំហាររបស់យើងដដែល។

## ឃ. អង្គជំនុំជម្រះតុលាការកំពូល ពុំមែនអង្គជំនុំជម្រះសាលាដំបូងនោះទេ ដែលគួរចាត់ការលើបញ្ហានេះ

60. ដូចអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចនៅពេលមុនរួចហើយថា "[វា] ជា [...]ការសំខាន់ណាស់ដែលថា នៅពេលកិច្ចដំណើរការនីតិវិធីទាំងមូល ចៅក្រមមានអំណាចចាត់វិធានការចាំបាច់ដើម្បីធានានូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ដែលជាមូលដ្ឋានរក្សានូវការគោរពចំពោះយុត្តិធម៌"[119]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានសម្រេចដែរថា "មានកាលៈទេសៈតិចតួច ដែលក្នុងនោះការទាមទារប្រសិទ្ធភាព និងភាពឥតលម្អៀងនៅក្នុងការពិនិត្យទៅលើការចោទប្រកាន់អំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលអាចមានអាទិភាពលើការបែងចែកជារួមនៃសមត្ថកិច្ចនៅក្នុងចំណោមស្ថាប័ននានារបស់ អ.វ.ត.ក។ អង្គជំនុំជម្រះតុលាការកំពូលបន្តទៀតថា ស្ថាប័នណាមួយនៃអង្គជំនុំជម្រះដែលទទួលសំណុំរឿង - ដែលបច្ចុប្បន្នគឺជាអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២ - គ្មានជម្រើសអ្វីក្រៅតែពីការអនុវត្តអំណាចដែលមាន ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ដោយមិនគិតថារឿងរ៉ាវដែលត្រូវបានចោទប្រកាន់អំពីការជ្រៀតជ្រែកបានកើតឡើងនៅពេលណានោះទេ"[120]។ ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា នៅក្នុងករណីនេះ ជាការល្អ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលធ្វើការស៊ើបអង្កេត ដោយហេតុថា អង្គជំនុំជម្រះតុលាការកំពូលមានសមត្ថភាពល្អបំផុតក្នុងការដោះស្រាយលើការចោទប្រកាន់អំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលដូចបានលើកឡើងនៅក្នុងសំណើសុំរបស់ក្រុមមេធាវីការពារក្តី។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញយ៉ាងច្បាស់នូវឆន្ទៈរបស់ខ្លួនក្នុងការដោះស្រាយបញ្ហានេះទេ ដោយបន្តធ្វើជាពិនិត្យទៅលើសារណារបស់ក្រុមមេធាវីការពារក្តី។ ក្រោយពីដោះស្រាយលើសំណើសុំផ្អាកដែលមានហេតុផលត្រឹមត្រូវ ដែលសំណើសុំនេះផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់អំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលដោយចៅក្រមអន្តរជាតិមួយរូបនៅក្នុងអនុស្សរណៈមួយទំព័រដែលពុំមានសំអាងហេតុ នៅក្នុងពេលនេះ អង្គជំនុំជម្រះសាលាដំបូង

---

[119] ភាពយុត្តិធម៌នៃកិច្ចស៊ើបសួររបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៣០។

[120] ភាពយុត្តិធម៌នៃកិច្ចស៊ើបសួររបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៣១។

បានបង្ហាញយ៉ាងច្បាស់នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ថា អង្គជំនុំជម្រះមិនខ្វល់នឹងការប្រកាន់ខ្ជាប់អំពីសុចរិតភាពនៃស្ថាប័នមួយដែលខ្លួនត្រូវជំរុញនោះ[121]។

## V. សេចក្តីសន្និដ្ឋាន និងសំណើសុំ

61. យោងតាមហេតុផលទាំងនេះ ក្រុមមេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល៖

ក) ទទួលយកបណ្តឹងសាទុក្ខនេះ។

ខ) ច្រានចោលសេចក្តីសម្រេចដែលត្រូវបានជំទាស់។

គ) បើកការស៊ើបអង្កេតដូចបានស្នើសុំនៅក្នុងសំណើ។ បើពុំដូច្នោះទេ ក្រុមមេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការស៊ើបអង្កេត។

សហមេធាវីការពារក្តី នួន ជា

Michiel PESTMAN Andrew IANUZZI Jasper PAUW

[121] យើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមវិធីសាស្ត្រមួយដែលបានស្នើឡើងដោយចៅក្រមអន្តរជាតិនៃ អ.ប.ជ។ នៅក្នុងមតិយោល់ខ្វែងគ្នានោះ ចៅក្រមបានលើកឡើងថា "ចំណាត់ការដែលសមស្របជាងគេបង្អស់នោះគឺអង្គបុរេជំនុំជម្រះគួរត្រូវដឹកនាំកិច្ចស៊ើបអង្កេតនោះ។ នោះគឺដោយសារតែ ក.ស.ច.ស ដែលជាអង្គភាពស៊ើបសួររបស់ អ.វ.ត.ក បានបដិសេធម្តងហើយម្តងទៀត មិនស៊ើបអង្កេតលើបញ្ហានេះ ហើយនៅក្នុងស្ថានភាពនេះ ក.ស.ច.ស ប្រហែលជាមិនមែនជាអង្គភាពសមស្របជាងគេបង្អស់ដើម្បីដឹកនាំកិច្ចស៊ើបអង្កេតទៅលើការចោទប្រកាន់ថាមានការជ្រៀតជ្រែកនោះឡើយ"។ សេចក្តីសម្រេចលើកទីពីរ (មតិខ្វែងយោបល់) កថាខណ្ឌ ៨។ មិនខុសពីការរកឃើញនេះ យើងខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការស៊ើបអង្កេតដូចបានស្នើសុំនៅក្នុងសំណើសុំ ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញបំណងរបស់ខ្លួនយ៉ាងច្បាស់ថាមិនចង់ធ្វើការស៊ើបអង្កេត។